ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក

CHIEF BANK

របាយការណ៍ប្រចាំឆ្នាំ ANNUAL REPORT

២០១៩

2019

សេវាបើកប្រាក់បៀវត្ស
គណនីកុមារ
INTEREST RATE UP TO
3.7
% p.a.
CHIEF MOBILE
Accounts
Payments
Transfers
Notifications
CHIEF MOBILE
គណនាទាន
ATM 24/7
CHIEF BANK
CARDHOLDER NAME
CSS
ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ
គណនីបញ្ញើ

តារាងមាតិកា

០១	សារស្វាគមន៍ពី ប្រធានក្រុមប្រឹក្សាភិបាល	២
០២	សារស្វាគមន៍ពី ប្រធាននាយកប្រតិបត្តិធនាគារ	៣-៤
០៣	ក្រុមប្រឹក្សាភិបាល	៥-៧
០៤	ប្រធាននាយកប្រតិបត្តិ	៨
០៥	រចនាសម្ព័ន្ធ	៩-១០
០៦	ព័ត៌មានសង្ខេបអំពីធនាគារ	១១
០៧	ផលិតផល និង សេវា	១២-១៣
០៨	ព័ត៌មានសង្ខេបអំពី Chief Group	១៤
០៩	ព័ត៌មានសង្ខេបអំពី ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក	១៥-១៦
១០	វប្បធម៌ការងារ	១៧
១១	ការបំពេញចិត្តអតិថិជន	១៨
១២	ទិសដៅយុទ្ធសាស្រ្ត ឆ្នាំ២០១៩	១៩-២០
១៣	ការពង្រីកអាជីវកម្ម	២១
១៤	បណ្តាញសាខា	២២
១៥	របាយការណ៍ក្រុមប្រឹក្សាភិបាល	២៥-២៨
១៦	របាយការណ៍សវនករឯករាជ្យ	២៩-១០៥

សារស្វាគមន៍ពី ប្រធានក្រុមប្រឹក្សាភិបាល

“ (ទីណាមានមនុស្ស ទីនោះមាន ឈីហ្វ, The Chief Way) ទស្សនៈអាជីវកម្មតែមួយ វាគឺជាមធ្យោបាយមួយ ដើម្បីបង្កើតនូវទំនុកចិត្តអោយគ្នាទៅវិញទៅមក និង ទំនាក់ទំនងជាដៃគូរ ជាមួយអតិថិជនរបស់យើង, ជាមធ្យោបាយទៅរកការរីក ចំរើនថ្កុំថ្កើន និង ជាផ្លូវដែរអាជីវកម្មរបស់យើងត្រូវបានបង្កើត ឡើងដោយភាពស្មោះត្រង់ និង សីលធម៌។ ”

Mr. CHAU Chung Kai Peter
ស្ថាបនិក និង ប្រធានក្រុមប្រឹក្សាភិបាល

សារស្វាគមន៍ពី ប្រធានក្រុមប្រឹក្សាភិបាល

កំណើនសេដ្ឋកិច្ចព្រះរាជាណាចក្រកម្ពុជានៅតែរក្សាបានកំណើនដ៏រឹងមាំដែលនៅក្នុងអំឡុងឆ្នាំ ២០១៩ ដែលទាំងនេះបង្ហាញឲ្យឃើញច្បាស់តាមរយៈការផ្លាស់ប្តូរមុខមាត់ថ្មីយ៉ាងឆាប់រហ័សកំណើនវិស័យធនាគារនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការរីកចម្រើន។ ធនាគារឈីហ្វក្នុងឆ្នាំនេះផងដែរយើងមានការមមាញឹកក្នុងការរៀបចំខ្លួនដើម្បីក្លាយជា ធនាគារពាណិជ្ជដោយមានផលិតផលសម្បូរបែបអត្រាការប្រាក់សន្សំថេរគួរឱ្យទាក់ទាញ ហើយយើងជឿជាក់ថាឆាប់ៗនេះប្រព័ន្ធធនាគារចល័ត និង ប្រព័ន្ធដកប្រាក់ស្វ័យប្រវត្តិចេញនូវផលិតផលថ្មីៗជាច្រើនទៀត។ យើងក៏មានទីតាំងល្អប្រសើរជាងមុនដែរងាយស្រួលសម្រាប់អតិថិជន មិត្តភក្រ័នឹងអតិថិជនថ្មីៗបន្ថែមទៀតផងដែរ។

នៅពេលដែលយើងធ្វើការពង្រីកអាជីវកម្មរបស់យើងជាសកលធនាគារយើងត្រូវបានបញ្ចូលនូវគំរូអាជីវកម្មមួយដោយធ្វើការផ្តោតលើអតិថិជនជាមួយបច្ចេកវិទ្យាទំនើបក្នុងគោលបំណងផ្តល់នូវដំណោះស្រាយធំទូលំទូលាយផ្នែកហិរញ្ញវត្ថុ ព្រមទាំងដំណើរការប្រត្តិបត្តិតាមដែលមានលក្ខណៈប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។ បន្ថែមពីនេះទៀតយើងផ្តល់អោយបុគ្គលិករបស់យើងនូវវិជ្ជាជីវៈគ្រប់គ្រាន់ នឹង វគ្គបណ្តុះបណ្តាលថ្មីៗដើម្បីទទួលយកនូវភាពជាអ្នកដឹកនាំគ្រប់ពេលវេលា។ យុទ្ធសាស្ត្ររបស់យើងគឺត្រូវបានបង្ហាញដោយភាពជោគជ័យការកើនឡើងយ៉ាងឆាប់រហ័ស និងជាទំលាប់សម្រាប់ទស្សវត្សន៏ចុងក្រោយនេះ។

បច្ចុប្បន្នក្រុមរបស់យើង ជ្រើសរើសបុគ្គលិកក្នុងស្រុកប្រកបដោយវិជ្ជាជីវៈនិងការជួយជ្រោមជ្រែងពីសំណាក់ក្រុមហ៊ុនមេដែលមានទីតាំងនៅទីក្រុងហុងកុង។ធនាគារឈីហ្វ គឺជាផ្នែកមួយនៃមូលដ្ឋានទំនាក់ទំនងវប្បធម៏នៅក្នុងគោលការណ៍សុចរិតភាព ប្រុងប្រយ័ត្ន និងតម្លាភាព។

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក សូមស្វាគមន៍។

Mr. CHAU Chung Kai Peter
ស្ថាបនិក និង ប្រធានក្រុមប្រឹក្សាភិបាល
Chief Group

សារស្វាគមន៍ពី ប្រធាននាយកប្រតិបត្តិធនាគារ

“ ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក គឺធនាគារពាណិជ្ជ ដែលទើបតែបង្កើតថ្មី ក៏ប៉ុន្តែពោរពេញទៅដោយសក្តានុពលខ្ពស់ ដោយប្រើប្រាស់នូវគំរូអាជីវកម្មផ្តោតសំខាន់ទៅលើ ការបំពេញតម្រូវការអោយបានល្អប្រសើរដល់អតិថិជនទូទៅនៅក្នុងប្រទេសកម្ពុជា ”

ឧកញ៉ា បណ្ឌិត សឿង ម៉ូរ៉ារិទ្ធ
ប្រធាននាយកប្រតិបត្តិ

សូមស្វាគមន៍មកកាន់ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក

លទ្ធផលកាលពីឆ្នាំមុនគឺមានស្ថេរភាពនិងមានអត្ថន័យណាស់សម្រាប់ធនាគារពាណិជ្ជឈីហ្វ ឆ្ពោះទៅគោលដៅដែលយើងបានដាក់នៅក្នុងផែនការអាជីវកម្មនិងអភិវឌ្ឍន៍ក្នុងឆ្នាំ២០១៩។ កំណើនប្រាក់ចំណេញដែលយើងរក តាមរយៈដើមទុនរបស់ភាគទុនិក ប្រាក់បញ្ញើរបស់អតិថិជន និងលើសពីនេះទៅទៀតយើងប្តេជ្ញាចិត្តដោយដើរលើពីយុទ្ធសាស្ត្ររបស់យើង។ យើងបានជំរុញកំណើនប្រាក់ចំណូលតាមរយៈអតិថិជនជាចំបងប្រកបដោយចិរភាពដោយធ្វើអោយទំនាក់ទំនងរបស់យើងកាន់តែស៊ីជម្រៅជាមួយអតិថិជន និងចាប់យកអតិថិជនថ្មីៗទៅតាមគោលដៅទីផ្សារ។យើងបានប្រើប្រាស់នូវគម្រូអជីវកម្មនិងពង្រឹងនូវបច្ចេកវិទ្យាដែលមានស្រាប់ដើម្បីលើកកម្ពស់សមត្ថភាពធនាគារយើងដើម្បីកាត់បន្ថយការចំណាយនិងបម្រើអតិថិជនអោយកាន់តែប្រសើរ។ យើងបានធ្វើអោយប្រសើរឡើងនូវមូលដ្ឋានដើមទុនរបស់យើងដោយប្រុងប្រយ័ត្នក្នុងការគ្របគ្រងប្រតិបត្តិការនិងវិនិយោគ។ ចុងក្រោយយើងបន្តផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងនិងការគ្រប់គ្រងហានិភ័យដើម្បីធានាថាធនាគារឈីហ្វមានស្ថេរភាពរឹងមាំនៅក្នុងវិស័យធនាគារដែលកំពុងរីកចម្រើននេះ។

សមិទ្ធិផលរបស់យើងក្នុងឆ្នាំកន្លងទៅអាចកើតមានឡើងបានតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់ដែលបានបង្ហាញពីភាពអត់ធន់ ការប្តេជ្ញាចិត្ត និងពលិកម្មក្នុងការងារ និងតាមរយៈ ការដឹកនាំប្រកបដោយចក្ខុវិស័យ និងទស្សនៈវិស័យ យ៉ាងច្បាស់លាស់របស់ធនាគារ និងដោយភាពជាអ្នក ដឹកនាំបែបយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធិភាព និងការយកចិត្តទុកដាក់ពីសំណាក់ប្រធានក្រុមប្រឹក្សាភិបាល លោក Chau សមាជិកក្រុមប្រឹក្សាភិបាល និងក្រុមប្រឹក្សាភិបាលឯករាជ្យទាំងអស់របស់ធនាគារ។

ដោយសារតែប្រតិបត្តិការធនាគារឈីហ្វទទួលបានជោគជ័យជាបន្តបន្ទាប់ក្នុងរយៈពេល៦ឆ្នាំមកនេះធនាគារពាណិជ្ជ ឈីហ្វ(ខេមបូឌា)ម.ក ត្រូវបានរៀបចំយ៉ាងល្អប្រសើរដើម្បីបំពេញនូវរាល់តម្រូវការទាំងអស់របស់ធនាគារជាតិនៃកម្ពុជាហើយបានចាប់ផ្តើមផ្តល់ជូននូវផលិតផលនិងសេវាកម្មធនាគារពាណិជ្ជឈីហ្វជាច្រើនរួមមាន គណនីចរន្ត គណនីសន្សំ គណនីប្រាក់បញ្ញើមានកាលកំណត់ព្រមទាំងគណនីប្រាក់បញ្ញើសន្សំថេរ ឥណទានសម្រាប់បុគ្គលិក ឥណទានសំរាប់ក្រុមហ៊ុន ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ សេវាកម្មផ្ទេរប្រាក់ក្នុងស្រុកនិងសេវាហិរញ្ញប្បទានពាណិជ្ជកម្មជាច្រើនទៀត ប្រកបដោយលក្ខណៈពិសេសគួរឲទាក់ទាញ និងច្នៃប្រឌិត។លើសពិនេះទៀតយើងកំពុងចាប់ ផ្តើមនូវប្រតិបត្តិការសេវាកម្មផ្ទេរប្រាក់ សេវាកម្មធនាគារតាមទូរស័ព្ទចល័ត ប្រព័ន្ធCSS (Central Share Swift) សេវាកម្មផ្ទេរប្រាក់អ៊ីនធ័រណេត (Internet Banking) និងផលិតផលកាតឥណទាន និងឥណពន្ធ និងផលិតផលជាច្រើនទៀតនៅក្នុងអនាគតដ៏ខ្លីខាងមុខ។

ធនាគារពាណិជ្ជឈីហ្វ(ខេមបូឌា)ម.កបេជ្ញាចិត្តដើម្បីបំពេញនូវតម្រូវការហិរញ្ញវត្ថុរបស់អតិថិជននិងជួយអាជីវកម្មពួកគាត់ឲ្យមានភាពជោគជ័យ។ធនាគារក៏នៅតែបន្តការប្តេជ្ញាចិត្តយ៉ាងខ្លាំងដើម្បីក្លាយជាធនាគារបរទេសមួយដែលប្រកបដោយភាពច្នៃប្រឌិតនិងមានប្រសិទ្ធិភាពខ្ពស់បំផុតដោយផ្តល់នូវការគាំទ្រយ៉ាងពេញលេញចំពោះសសរស្តម្ភទាំងបួនរបស់ប្រទេសកម្ពុជាដែរជាកត្តាជំរុញឲ្យមានកំណើនសេដ្ឋកិច្ចរួមមានការនាំចេញវិស័យទេសចរណ៍ កសិកម្ម និងផ្នែកអចលនទ្រព្យ។ ធនាគារឈីហ្វផ្តល់នូវសេវាកម្មលំដាប់ស្តង់ដារពិភពលោកទៅដល់អតិថិជនរបស់ខ្លួនក្នុងប្រទេសកម្ពុជាដែរជាប្រទេសតូចមួយក្នុងតំបន់អាស៊ីអាគ្នេយ៍ដែរទទួលបាននូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់លើសពី៧%ក្នុងមួយឆ្នាំជាបន្តបន្ទាប់។ទាំងនេះក៏ដោយសារតែស្ថិរភាពនយោបាយនិងម៉ាក្រូសេដ្ឋកិច្ចដែលជាគ្រឹះមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍ។ សេដ្ឋកិច្ចរបស់កម្ពុជាកើនឡើងរហូតដល់៧.៥%ក្នុងឆ្នាំ២០១៨ជាមួយអតិផរណាទាប។ ទាំងនេះត្រូវបានរំពឹងថាទស្សនវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជាសម្រាប់ឆ្នាំ២០២០នឹងរក្សានូវភាពខ្លាំង និងរឹងមាំ។

សារស្វាគមន៍ពី ប្រធាននាយកប្រតិបត្តិធនាគារ (ត)

វិស័យធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានរីកលូតលាស់យ៉ាងឆាប់រហ័សដោយឆ្លុះបញ្ចាំងយ៉ាងច្បាស់តាមរយៈការកើនឡើងជាលំដាប់ទៅលើទ្រព្យសកម្ម សេវាឥណទាន ប្រាក់បញ្ញើ និងតម្រូវការសម្រាប់ សេវាកម្មធនាគារផ្សេងៗទៀត។ប្រព័ន្ធធនាគារនៅក្នុងប្រទេសកម្ពុជាបានបន្តធ្វើការអភិវឌ្ឍនិងកែលម្អឡើងជាលំដាប់ចាប់ពីដំណាក់កាលដំបូងនៃការធ្វើសេរីភាវូបនីយកម្មទ្រង់ទ្រាយធំរបស់ខ្លួនបន្ទាប់ពីការបោះឆ្នោតជាសកលនិងជាលើកដំបូងនៅក្នុងឆ្នាំ១៩៩៣ក្រោមការជួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ ដែរបានជួយកសាងនូវ ទំនុកចិត្តដល់សាធារណៈជនកាន់តែខ្លាំងនៅក្នុងវិស័យធនាគារ និងវិស័យពាក់ព័ន្ធដ៏ទៃទៀតដែលជំរុញឲ្យមាន តម្រូវការកាន់តែខ្លាំងលើសេវាកម្មហិរញ្ញវត្ថុនិងសេវាកម្មផ្សេងៗទៀតរបស់ធនាគារ។

ធនាគារពាណិជ្ជឈីហ្វកំពុងប្រើប្រាស់គំរូអជីវកម្មមួយដែលបានធ្វើមូលដ្ឋាននីយកម្មដោយស្របទៅតាមតម្រូវការពិតប្រាកដរបស់អតិថិជននៅក្នុងប្រទេសកម្ពុជានិងតំបន់ស្វែងរកឱកាសវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។យើងកំពុងធ្វើការងារយ៉ាងសកម្មដើម្បីអោយប្រសើរបន្ថែមទៀតលើផលិតផលដែលមានស្រាប់របស់យើងនិងផលិតផលឬសេវាកម្មថ្មីៗដើម្បីបំពេញនូវតម្រូវការដែលកំពុងកើនឡើងរបស់អតិថិជន។

កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនិងបរិយាកាសអជីវកម្មដ៏ល្អប្រសើរបានផ្តល់នូវឱកាសជាច្រើនសម្រាប់កំណើនដ៏រឹងមាំនៅក្នុងឧស្សាហកម្មធនាគារទោះបីជាមានការប្រកួតប្រជែងខ្លាំងយ៉ាងណាក៏ដោយក៏ប៉ុន្តែធនាគារពាណិជ្ជឈីហ្វពិតជាមានទំនុកចិត្តនៅក្នុងការចាក់គ្រឹះដ៏រឹងមាំនិងរូបមន្តដ៏ត្រឹមត្រូវក្នុងការធ្វើការជាមួយអតិថិជនសម្រាប់ផលប្រយោជន៍ទៅវិញទៅមក។ទស្សនះឆ្នាំ២០២០ប្រកបទៅដោយគំនិតសុទិដ្ឋិនិយមនិងជាមួយការរៀបចំរចនាសម្ព័ន្ធដ៏ល្អប្រសើរយើងមានជំនឿយ៉ាងមុតមាំថាយុទ្ធសាស្ត្រដ៏មុតស្រួចរបស់យើងរួមបញ្ចូលនូវដំណោះស្រាយរួមរបស់អតិថិជនទៅនឹងភាពជោគជ័យនៃអជីវកម្មនឹងនាំអោយធនាគារមានការរីកចម្រើនទៅមុខប្រកបដោយនិរន្តភាពនិងអត្ថប្រយោជន៍នៃការប្រកួតប្រជែង។

ជូសមុខអោយគណៈគ្រប់គ្រងជាន់ខ្ពស់នៃធនាគារពាណិជ្ជឈីហ្វ(ខេមបូឌា)ម.កខ្ញុំបាទសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជនរបស់យើងទាំងអស់សម្រាប់ការជ្រើសរើសយកធនាគារពាណិជ្ជឈីហ្វ(ខេមបូឌា)ម.កជាដៃគូពាណិជ្ជកម្មយូរអង្វែង។ ជាមួយគ្នានេះដែរខ្ញុំសូមថ្លែងអំណរគុណដល់សហសេវិករបស់ខ្ញុំប្រធានក្រុមប្រឹក្សាភិបាល សមាជិកក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាភិបាលឯករាជ្យទាំងអស់ព្រមទាំងបុគ្គលិកនិងគណៈគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជាទាំងអស់សម្រាប់ការគាំទ្រដោយគ្មានងាករេរបស់ពួកគេដែលបានផ្តល់អោយខ្ញុំ ក្នុងការបំពេញតួនាទីជាប្រធាននាយកប្រតិបត្តិ។ខ្ញុំបាទពិតជាមានមោទនភាពខ្លាំងណាស់ចំពោះវឌ្ឍភាពដ៏សំខាន់មួយនេះដែលយើងបានបង្កើតឡើង។ យើងទាំងអស់គ្នាមានទំនុកចិត្តថាយើងកំពុងតែផ្តល់ជូនអតិថិជនរបស់ ខ្លួននូវគុណភាពផលិតផលនិងសេវាកម្មអោយប្រសើរឡើងជាធនាគារដែលមានភាពថ្នៃប្រឌិតជាធនាគារជម្រើសដំបូងរបស់អតិថិជនជាធនាគារដែលនិយោជិក អតិថិជននិងអ្នកពាក់ព័ន្ធផ្សេងទៀតរបស់យើងអាចជឿទុក ចិត្តយ៉ាងពិតប្រាកដ។

យើងខ្ញុំរង់ចាំស្វាគមន៍ និងផ្តល់ការបម្រើដ៏ល្អបំផុតដល់អស់លោកអ្នកជានិច្ច

ដោយការគោរពដ៏ស្មោះស្ម័គ្រពីខ្ញុំ

ឧកញ៉ា បណ្ឌិត សឿង ម៉ូរ៉ារិទ្ធ
ប្រធាននាយកប្រតិបត្តិ
ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក

ក្រុមប្រឹក្សាភិបាល

Mr. CHAU Chung Kai Peter

ស្ថាបនិក និង ប្រធានក្រុមប្រឹក្សាភិបាល, Chief Group

Mr. Chau Chung Kai Peter, គឺជាស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាល Chief Group ហើយគាត់ក៏ជាសហគ្រិនជោគជ័យមួយរូបនៅក្នុងទីក្នុងហុងកុង ដែលបានបង្កើតឡើងនូវសហគ្រាសរបស់គាត់ពីដំបូង។ លោក CHAU បានកើតនៅក្នុងឆ្នាំ១៩៣៩ នៅក្នុងទីក្រុងចៅស៊ូ (Chaozhou) ប្រទេសចិន។ លោក CHAU បានចូលបំរើការងារនៅក្នុងឧស្សាហកម្មធនាគារហុងកុងនៅក្នុងឆ្នាំ ១៩៥៨។ លោក CHAU គឺជានាយកប្រតិបត្តិជាន់ខ្ពស់របស់ធនាគារ Chong Hing ពីឆ្នាំ ១៩៥៩ ដល់ ១៩៦២ និងជានាយកប្រតិបត្តិរបស់ធនាគារបាងកកពី ឆ្នាំ១៩៦២ ដល់ ១៩៧០។ លោក CHAU មានបទពីសោធន៍យ៉ាងច្រើនជាមួយធនាគារពាណិជ្ជក្នុងការបង្កើតនូវផលិតផលដែលប្រកបដោយភាពឆ្នៃប្រឌិតឈានមុខគេ និងធ្វើប្រតិបត្តិការណ៍ផ្នែកធនាគារដ៏ល្អប្រសើរ ក្នុងកំឡុងពេលការអភិវឌ្ឍន៍វិស័យឧស្សាហកម្មធនាគារនៅទីក្រុងហុងកុង។ លោក CHAU បានបង្កើតនូវក្រុមហ៊ុនផ្ទាល់ខ្លួនរបស់លោកនៅក្នុងឆ្នាំ ១៩៧៩ ដែលមានឈ្មោះថា "Chief Investment Co."។ លោកបានទទួលយកនូវបទពិសោធន៍ដ៏មានតំលៃ (ដោយការចាប់ផ្តើមដាក់បង្ហាញទៅដល់ទីផ្សារមូលធនជាសកល និងឧស្សាហកម្មហិរញ្ញវត្ថុ) នៅក្នុងពាក់កណ្តាលសតវត្សរ៍ចុងក្រោយ។ ជំនឿ នៃសុចរិតភាព និង ភាពស្មោះត្រង់ គឺជាព្រលឹងដ៏សំខាន់មួយដែលលោក CHAU បន្តបង្កើតអស់រយៈពេលជាង៣០ឆ្នាំ នៅពេលដែលលោកប្រតិបត្តិនៅក្នុងក្រុមហ៊ុននេះ។ រហូតមកដល់ពេលបច្ចុប្បន្ន Chief Group គឺជាក្រុមហ៊ុនមួយ ក្នុងចំនោម អន្តរការីមូលបត្រដ៏ធំជាងគេនៅក្នុងទីក្រុងហុងកុង ដែលមាន ចំនួនសាខា និង ជាក្រុមហ៊ុននាំមុខគេមួយនៅក្នុងវិស័យឧស្សាហកម្មសំរាប់ សេវា និងផលិតផលហិរញ្ញវត្ថុច្រើនប្រភេទ។ លោក CHAU យកចិត្តទុកដាក់យ៉ាងសកម្មផងដែរ នៅក្នុងសកម្មភាព សប្បុរសធម៌ ដែលគាត់ជឿជាក់ថា ការអប់រំគឺជាមូលដ្ឋាន នៃការកសាងជាតិ។ ការចាប់ផ្តើមពីឆ្នាំ ២០០៦, លោក CHAU បានផ្តល់ការបរិច្ចាគបន្តបន្ទាប់ជាបុគ្គល និង ស្ថាបនិកក្រុមហ៊ុន ក្នុងការកសាងសាលារៀន នៅក្នុងតំបន់ដាច់ស្រយាលជាច្រើននៃប្រទេសចិន រួមទាំងសាលាបឋមសិក្សាចំនួន៥០សាលា និង អនុវិទ្យាល័យចំនួន២សាលា។

Ms. NG Siu Mui, Fion

អភិបាល

សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ
សមាជិកគណៈកម្មាធិការសវនកម្មផ្ទៃក្នុង
សមាជិកគណៈកម្មាធិការធនធានមនុស្ស តែងតាំង និង ផ្តល់តម្លៃការ
សមាជិកក្រុមប្រឹក្សាភិបាល

ការសិក្សា

- បរិញ្ញាប័ត្រជាន់ខ្ពស់គ្រប់គ្រងធុរកិច្ច នៅសាកលវិទ្យាល័យហុងកុង ទីក្រុងហុងកុង។
- សញ្ញាប័ត្រវិជ្ជាជីវៈ អភិបាលកិច្ចនិងដឹកនាំសាជីវកម្ម ក្នុងទីក្រុងហុងកុង។

បទពិសោធន៍ការងារ

- អគ្គនាយិកា Chief Group Ltd. ទីក្រុងហុងកុង (បច្ចុប្បន្ន)។
- នាយិកា និងមន្ត្រីទទួលខុសត្រូវ Chief Security Ltd. ទីក្រុងហុងកុង (បច្ចុប្បន្ន)។
- នាយិកា និងមន្ត្រីទទួលខុសត្រូវ Chief Commodities Ltd. ទីក្រុងហុងកុង (បច្ចុប្បន្ន)។
- នាយិកា Chief Great China Assets Management Ltd. ទីក្រុងហុងកុង (បច្ចុប្បន្ន)។
- នាយិកា Chief Financial Services Ltd. ទីក្រុងហុងកុង (បច្ចុប្បន្ន)។

Mr. LAM Wai Chuen, Patrick

អភិបាល
សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ
សមាជិកគណៈកម្មាធិការសវនកម្មផ្ទៃក្នុង
សមាជិកគណៈកម្មាធិការធនធានមនុស្ស តែងតាំង និង ផ្តល់តម្លៃការ
សមាជិកក្រុមប្រឹក្សាភិបាល

ការសិក្សា

- Certified Public Accountant, HKICPA, Hong Kong
- សមាជិកសមាគមន៍, ACCA

បទពិសោធន៍ការងារ

- អ្នកត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Chief Group Ltd ទីក្រុងហុងកុង(បច្ចុប្បន្ន)។
- ប្រធានសវនកម្ម របស់ក្រុមហ៊ុន Kreston CAC CPA Limited ។

Mr. YE Haiya, Michael

អភិបាល
សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ
សមាជិកគណៈកម្មាធិការសវនកម្មផ្ទៃក្នុង
សមាជិកគណៈកម្មាធិការធនធានមនុស្ស តែងតាំង និង ផ្តល់តម្លៃការ
សមាជិកក្រុមប្រឹក្សាភិបាល

ការសិក្សា

- បរិញ្ញាបត្រវិទ្យាសាស្ត្រនៅសាកលវិទ្យាល័យហុងកុង ទីក្រុងហុងកុង។

បទពិសោធន៍ការងារ

- នាយកផ្នែក Investment Sales Division, Chief Group Ltd ទីក្រុងហុងកុង(បច្ចុប្បន្ន)។
- នាយក និងមន្ត្រីទទួលខុសត្រូវ Chief Securities Limited (បច្ចុប្បន្ន)។
- នាយក Chief Financial Services Limited (បច្ចុប្បន្ន)។
- នាយក និងមន្ត្រីទទួលខុសត្រូវ Chief Great China Assets Management Limited (បច្ចុប្បន្ន)។

Mr. CHAN Kwok Cheung

ប្រធាន ក្រុមប្រឹក្សាភិបាលឯករាជ្យ
ប្រធានគណៈកម្មាធិការសវនកម្មផ្ទៃក្នុង
សមាជិកក្រុមប្រឹក្សាភិបាល

ការសិក្សា

- សមាជិកសមាគមន៍, HKICPA ទីក្រុងហុងកុង។
- សមាជិកសមាគមន៍, ACCA។

បទពិសោធន៍ការងារ

- នាយកក្រុមហ៊ុន Kreston CAC CPA Limited (បច្ចុប្បន្ន)។

Mr. CHEUNG Ka Wai

ប្រធានក្រុមប្រឹក្សាភិបាលឯករាជ្យ
ប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ
ប្រធានគណៈកម្មាធិការធនធានមនុស្ស តែងតាំង និង ផ្តល់តែម្លការ
សមាជិកក្រុមប្រឹក្សាភិបាល

ការសិក្សា

- LL.B (Hons) (HKU) 1991
- P.C.LL. (HKU) 1992
- LL.M. (HKU) 1994

បទពិសោធន៍ការងារ

- Senior Partner of Messrs. Kelvin Cheung & Co.

ប្រធាននាយកប្រតិបត្តិ

ឧកញ៉ា បណ្ឌិត សឿង ម៉ូរ៉ារិទ្ធ

ប្រធាននាយកប្រតិបត្តិ

ការសិក្សា

- បណ្ឌិត គ្រប់គ្រងពាណិជ្ជកម្ម ឯកទេសហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យ ជាតិគ្រប់គ្រង នៅក្នុងរាជធានីភ្នំពេញ។
  សហនិពន្ធ របាយការណ៍បច្ចេកទេស លើប្រធានបទ " ការធ្វើពាណិជ្ជកម្មតាមរយៈអេឡិចត្រូនិច នៅក្នុងប្រទេស កម្ពុជា៖ ស្តីអំពី ការអភិវឌ្ឍន៍ និងការសិក្សា ចំពោះការប្រើប្រាស់អ៊ិនធឺណិត " អោយ វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់ អាស៊ាន និង អាស៊ីខាងកើត។
  អត្ថបទស្រាវជ្រាវលើ "ការវាយតំលៃនៃការអនុវត្ត (គុណភាព និងសេវា) SERVQUAL នៅក្នុងវិស័យធនាគាររបស់កម្ពុជា" នៅមជ្ឈមណ្ឌលសម្រាប់ការសិក្សាអាស៊ាននៃសាកលវិទ្យាល័យ Antwerp ប្រទេសបែលហ្ស៊ិកឆ្នាំ២០១២។
- អនុបណ្ឌិត នៅសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅរាជធានីភ្នំពេញ។
- បរិញ្ញាបត្រ ផ្នែកគណនេយ្យ នៅសាកលវិទ្យាល័យ ជាតិគ្រប់គ្រង នៅក្នុងរាជធានីភ្នំពេញ។

- សញ្ញាបត្រជំនាញខាង ថ្នាក់គ្រប់គ្រងល្អ ពី Harvard Business School, Boston, USA, ២០១៩ ។
- សញ្ញាបត្រអាជីពជំនាញខាង យុទ្ធសាស្ត្រ " ការកសាង និងការរក្សានូវអត្ថប្រយោជន៍នៃការប្រកួត ប្រជែង " ពី Harvard Business School, Boston, USA, ២០១៩ ។
- សញ្ញាបត្រអាជីពជំនាញខាង ការបង្កើតគំនិតថ្មី ពី Harvard Business School, Boston, USA, ២០១៩ ។
- សញ្ញាបត្រអាជីពជំនាញខាងអភិវឌ្ឍន៍អ្នកដឹកនាំល្អ ពី Harvard Business School, Boston, USA, 2017 ។

បទពិសោធន៍ការងារ

- អគ្គនាយក នៅធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី។
- អ្នកតំណាងឲ្យធនាគារឯកទេស ដែលបម្រើការងារនៅក្នុងក្រុមប្រឹក្សាភិបាលរបស់សមាគមធនាគារនៅកម្ពុជា (ខែមីនា ឆ្នាំ២០១៧ ដល់ ខែមីនា ឆ្នាំ២០១៨)។
- អ្នកគ្រប់គ្រងជាន់ខ្ពស់ នៅធនាគារ Kookmin រាជធានី ភ្នំពេញ។
- នាយកផ្នែកឥណទាន នៅធនាគារ Kookmin រាជធានីភ្នំពេញ។
- ប្រធានឥណទាន (ទីស្នាក់ការកណ្តាល) នៅធនាគារ Angkor Capital រាជធានីភ្នំពេញ។
- មន្ត្រីឥណទានជាន់ខ្ពស់នៅ Cambodian Public Bank រាជធានីភ្នំពេញ។
- មន្ត្រីឥណទាន នៅធនាគារ Canadia រាជធានីភ្នំពេញ។
- មន្ត្រីឥណទានជាន់ទាប នៅធនាគារ អេស៊ីលីដា ភីអិលស៊ី។
- សាស្ត្រាចារ្យ ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យ (បច្ចុប្បន្ន)។

រចនាសម្ព័ន្ធ

ក្រុមប្រឹក្សាភិបាល

Mr. CHAU Chung Kai Peter
ស្ថាបនិក និង នាយក

Ms. NG Siu Mui, Fion

អភិបាល

សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ
សមាជិកគណៈកម្មាធិការសវនកម្មផ្ទៃក្នុង
សមាជិកគណៈកម្មាធិការធនធានមនុស្ស
តែងតាំង និង ផ្តល់តម្លៃការ
សមាជិកក្រុមប្រឹក្សាភិបាល

Mr. LAM Wai Chuen, Patrick

អភិបាល

សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ
សមាជិកគណៈកម្មាធិការសវនកម្មផ្ទៃក្នុង
សមាជិកគណៈកម្មាធិការធនធានមនុស្ស
តែងតាំង និង ផ្តល់តម្លៃការ
សមាជិកក្រុមប្រឹក្សាភិបាល

Mr. YE Haiya, Michael

អភិបាល

សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ
សមាជិកគណៈកម្មាធិការសវនកម្មផ្ទៃក្នុង
សមាជិកគណៈកម្មាធិការធនធានមនុស្ស
តែងតាំង និង ផ្តល់តម្លៃការ
សមាជិកក្រុមប្រឹក្សាភិបាល

Mr. CHAN Kwok Cheung

ប្រធាន ក្រុមប្រឹក្សាភិបាលឯករាជ្យ

ប្រធានគណៈកម្មាធិការសវនកម្មផ្ទៃក្នុង
សមាជិកក្រុមប្រឹក្សាភិបាល

Mr. CHAN Kwok Cheung

ប្រធាន ក្រុមប្រឹក្សាភិបាលឯករាជ្យ

ប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ
ប្រធានគណៈកម្មាធិការធនធានមនុស្ស
តែងតាំង និង ផ្តល់តម្លៃការ
សមាជិកក្រុមប្រឹក្សាភិបាល

រចនាសម្ព័ន្ធ

គណៈគ្រប់គ្រង

ព័ត៌មានសង្ខេបអំពីធនាគារ

ឈ្មោះរបស់ធនាគារ	ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា)ម.ក
កាលបរិច្ឆេទនៃការបង្កើតធនាគារ	ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣
លេខនៃការចុះបញ្ជី	00005793
អាសយដ្ឋាន ការិយាល័យកណ្តាល	ផ្ទះលេខសេ 01 ផ្លូវ អ៊ែ 11កែងនឹងផ្លូវ 70, ភូមិ 1 សង្កាត់ស្រះចក, ខណ្ឌ ដូនពេញ, រាជធានីភ្នំពេញ
គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨	
តំលើងដើមទុន	US$75Million
ចំនួនបុគ្គលិក	១៣៥

	ឈ្មោះ	ចំនួនភាគហ៊ុនដែលបានកាន់កាប់	ភាគរយនៃភាគហ៊ុនដែលបានកាន់កាប់(%)
ម្ចាស់ភាគហ៊ុន	Chief Financial Group (Cambodia) Limited.		១០០%

សវនករ	Deloitte (Cambodia) Co., Ltd.

ផលិតផល និង សេវា

ដើម្បីបំពេញនូវតម្រូវការកើនឡើងរបស់អតិថិជន ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក បានធ្វើការយ៉ាងសកម្ម ក្នុងការធ្វើអោយប្រសើរឡើងបន្ថែមទៀត ចំពោះ ផលិតផលនិង សេវា ដែលមានស្រាប់របស់យើង និង ធ្វើការផ្តល់ជូននូវផលិតផលជាធនាគារពាណិជ្ជពិតប្រាកដប្រកប ដោយលក្ខណៈដ៏គួរអោយទាក់ទាញ និង ច្នៃប្រឌិត ដែលទាំងនោះគឺសាកសមបំផុតសម្រាប់ អតិថិជនដែលមានតំរូវការហិរញ្ញប្បទានអាជីវកម្មខ្នាតតូច កសិដ្ឋាន ឥណទានផ្ទាល់ខ្លួន និងក្រុមហ៊ុនព្រមទាំងសេវាប្រាក់បញ្ញើ ជាមួយអត្រាការប្រាក់ ដ៏គួរអោយទាក់ទាញ ។ល។

ឥណទានសំរាប់ ប្រើប្រាស់ផ្ទាល់ខ្លួន

ឥណទានទិញគេហដ្ឋាន

ឥណទានទិញរថយន្ត

ឥណទានទិញម៉ូតូ

ឥណទានពុំមានទ្រព្យធានា

ធនាគារចល័ត / សេវាបើកប្រាក់បៀវត្ស



ធនាគារ ចល័ត

សេវាបើប្រាក់បៀវត្ស

ឥណទាន អាជីវកម្ម

ឥណទានអាជីវកម្មខ្នាតតូច និងតូចបំផុត

ឥណទានអាជីវកម្មខ្នាតមធ្យម

ឥណទានអាជីវកម្មខ្នាតធំ

ប្រាក់បញ្ញើ

គណនីប្រាក់បញ្ញើមាន កាលកំណត់

គណនីប្រាក់បញ្ញើ សន្សំថេរ

គណនីបញ្ញើសំចៃ គណនីចរន្ត



គណនីកុមារ

ព័ត៌មានសង្ខេបអំពី CHIEF GROUP

លោក Chau Chung Kai Peter គឺជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Chief Group ដែលត្រូវបាន បង្កើតឡើងក្នុងឆ្នាំ ១៩៧៩ នៅក្នុងទីក្រុងហុងកុង។ជាច្រើនទសវត្សន៍មកនេះ ក្រុមហ៊ុន Chief Group បានចូលរួមនៅក្នុងស្ថាប័នហិរញ្ញវត្ថុ ដ៏ទូលំទូលាយមួយជាមួយនឹងសេវាកម្ម និងផលិតផលច្រើនប្រភេទផ្សេងៗគ្នា។យើងគឺជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុននាំមុខគេក្នុង វិស័យ ឧស្សាហកម្ម អន្តរការីហិរញ្ញវត្ថុរបស់ទីក្រុងហុងកុង ដែរបានកាន់កាប់ដោយមោទនភាពនូវ បណ្តាញសេវាសាខាធំជាងគេបង្អស់។

បេសកកម្មរបស់យើង

យើងបានប្តេជ្ញាដើម្បីបំរើអតិថិជនរបស់យើងជាមួយឥរិយាបទប្រកបដោយសុចរិតភាព និងគុណភាព។ ទាំងនោះហើយដែលបានបង្កើតនូវទស្សនៈអាជីវកម្មតែមួយ (ទីណាមានមនុស្ស ទីនោះមាន ឈីហ្វ, The Chief Way) ដែរជាវិធីសាស្រ្តគ្រប់គ្រងទ្រព្យសម្បត្តិអោយប្រសើរឡើងតែមួយគត់។ ទីណាមានមនុស្ស ទីនោះមាន ឈីហ្វ, The Chief Way នាំមកនូវភាពជឿជាក់លើមនោគមវិជ្ជាអាជីវកម្មរបស់យើង និងភាពស្មោះត្រង់របស់អតិថិជន និង ដៃគូរអាជីវកម្ម។ យើងស្វែងរកភាពរីកចំរើនទាំងអស់គ្នា ជាមួយអតិថិជន និង ដៃគូរអាជីវកម្មរបស់យើង។

ទស្សនៈវិស័យរបស់យើង

មូលដ្ឋានរឹងមាំដែលបានចាក់ឬសនៅក្នុងទីក្រុងហុងកុង យើងបានពង្រីកនូវព្រំដែនអាជីវកម្មរបស់យើងនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ការដាក់ទីតាំងនូវចំកណ្តាលបេះដូងនៃតណ្ឌចិន ដូចជាប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍យ៉ាងរហ័ស គឺជាមជ្ឈមណ្ឌលដំបូងនៃបណ្តាញសេវារបស់យើង នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ យើងផ្តល់នូវភាពជំនាញទៅអោយ អតិថិជនរបស់យើង និងចែករំលែកនូវសមិទ្ធិផលជាមួយនឹងបុគ្គលិកក្នុងស្រុកយើងនៅក្នុងប្រទេសកម្ពុជា។

ដូចជាឧត្តមភាពសេវាកម្ម តែងតែជាការស្វែងរកដំបូងបង្អស់របស់យើង យើងបានផ្តល់នូវចំនុចអាទិភាព ដើម្បីរក្សានូវការលើកកម្ពស់ សេវាកម្មតាមរយៈ វគ្គបណ្តុះបណ្តាលបុគ្គលិក ការរួមបញ្ចូលខាងបច្ចេកវិទ្យា និង ភាពផ្សេងៗគ្នានៃ ផលិតផល។ យើងចង់ក្លាយជាធនាគារ គំរូនៅក្នុងឧស្សាហកម្មហិរញ្ញវត្ថុ។

ព័ត៌មានសង្ខេបអំពី ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក

ធនាគារឈីហ្វបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិ នៃកម្ពុជា សម្រាប់ធ្វើអាជីវកម្មជាធនាគារឯកទេស នៅកម្ពុជានៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣។ដោយសារតែភាពជោគជ័យ ជាបន្តបន្ទាប់នៃប្រតិបត្តិការរបស់ ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី បានកម្លាយខ្លួនជោគជ័យ ទៅជាធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ ក្រោម អាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារ លេខ៖ធ៤៣ ហើយនឹង តម្លើងដើមទុនចុះបញ្ជី របស់ខ្លួន រហូតដល់ ៧៥លានដុល្លារសហរដ្ឋអាមេរិក នៅក្នុងឆ្នាំនេះផងដែរ ។

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក បានធ្វើការប្ដេជ្ញាចិត្ត ដើម្បីក្លាយជាធនាគារបរទេសមួយប្រកបដោយភាពច្នៃប្រឌិត អភិវឌ្ឍ និងមានប្រសិទ្ធិភាពខ្ពស់បំផុត ដោយផ្ដល់នូវការគាំទ្រ យ៉ាងពេញលេញចំពោះសសរស្ដម្ភទាំងបួននៃកំណើនសេដ្ឋកិច្ចកម្ពុជា ដូចជា៖ វិស័យនាំចេញ សម្លៀកបំពាក់ វិស័យទេសចរណ៍ វិស័យកសិកម្ម និង វិស័យអចលនទ្រព្យ។ ធនាគារឈីហ្វផ្ដល់ ជូននូវផលិតផល និង សេវាកម្ម ធនាគារពាណិជ្ជ ជាច្រើនរួមមានគណនីប្រាក់បញ្ញើ-សន្សំ ច្រើនប្រភេទផ្សេងៗគ្នា និង ឥណទានសំរាប់បុគ្គល ឥណទានសំរាប់ ក្រុមហ៊ុន និង សេវាហិរញ្ញប្បទានពាណិជ្ជកម្ម និងជាច្រើនទៀត ប្រកបដោយ លក្ខណៈ ពិសេសគួរឱ្យទាក់ទាញ និងភាពច្នៃប្រឌិតទៅអោយអតិថិជនរបស់ខ្លួន នៅក្នុងប្រទេស កម្ពុជា ដែលជាប្រទេសតូចមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលទទួលបាននូវ អត្រាកំណើនសេដ្ឋកិច្ចដ៏ខ្ពស់ដោយគ្មានការអាក់ខាន សម្រាប់រយៈពេលវែងបំផុត មិនដែរធ្លាប់មាននៅក្នុង កំណត់ត្រាប្រវត្តិសាស្ត្រ ដោយសារតែមានស្ថេរភាពទាំង នយោបាយ និងម៉ាក្រូសេដ្ឋកិច្ច។

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក ជាធនាគារពាណិជ្ជ ដែលទើបតែបង្កើតថ្មី ក៏ប៉ុន្តែពោរពេញដោយសក្ដានុពលខ្ពស់ដោយប្រើប្រាស់នូវគំរូអាជីវកម្មផ្ដោតសំខាន់ទៅលើការបំពេញតម្រូវការអោយបានល្អប្រសើរបំផុតដល់អតិថិជនទូទៅ នៅក្នុងប្រទេសកម្ពុជានិងតំបន់ដែលបានស្វែងរកឱកាសវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ចក្ខុវិស័យរបស់យើង

យើងប្តេជ្ញាបំពេញនូវតម្រូវការអតិថិជន និងជួយជ្រោមជ្រែងពួកគេអោយទទួលបានជោគជ័យ ខាងផ្នែកហិរញ្ញវត្ថុ។

បេសកកម្មរបស់យើង

- ក្លាយជាធនាគារដ៏ធំ ដែលផ្តល់នូវសេវាកម្មសម្បូរបែប ជាមួយនឹងបណ្តាញសាខាធំ ជាងគេ
- ជា ធនាគារដែលជាជម្រើសរបស់អតិថិជនទី១ ដែរផ្តល់នូវបទពិសោធន៍ដ៏គួរអោយទាក់ទាញ
- ជា ធនាគារបរទេស ដែរប្រកបដោយប្រសិទ្ធិភាព និងការច្នៃប្រឌិតខ្ពស់ ដែរមានការធានា និងការផ្តល់សេវាកម្មប្រកបដោយភាពល្អឥតខ្ចោះ
- ធានានូវការគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ និង គោរពប្រតិបត្តិទៅតាមច្បាប់ទាំងឡាយដែលយើងបានធ្វើ

គោលដៅរបស់យើង

គោលដៅរបស់យើងគឺ ក៏សាងនូវទំនាក់ទំនងជាមួយអតិថិជនរបស់យើង អោយកាន់តែទូលំទូលាយ ស្និតស្នាល និង យូរអង្វែង ហើយយើងរង់ចាំជួយពួកគេ គ្រប់ជំហ៊ាន ដើម្បីអោយមុខ ជំនួញរបស់ពួកគេឆ្ពោះទៅរកភាពមានបាន និងផ្តល់អោយនូវគុណតម្លៃដែលមានរយៈពេលវែងសំរាប់ម្ចាស់ភាគហ៊ុន។

ទស្សនវិជ្ជារបស់យើង

- រក្សានូវ ភាពស្មោះត្រង់ និង វិជ្ជាជីវៈ អោយខ្ពស់បំផុត
- ឈានមុខគេ តាមរយៈគំនិតច្នៃប្រឌិត និងការបង្កើតថ្មី នៃផលិតផលនិងសេវាកម្ម
- ភ្ជាប់ទំនាក់ទំនង និង បម្រើអតិថិជន យ៉ាងសកម្មនិងអស់ពីដួងចិត្ត
- ចូលរួមចំណែកយ៉ាងសកម្មក្នុងសកម្មភាពសង្គម

វប្បធម៌ការងារ

ដោយបង្កើតនូវការងារជាក្រុមក្នុងចំណោមបុគ្គលិករបស់យើង យើងលើកទឹកចិត្តដល់បុគ្គលិកដែលមានបំណងចង់សិក្សា នឹងមានចក្ខុវិស័យឆ្ពោះទៅការងាររបស់ពួកគេ។ ពួកគេគឺជាកត្តាដ៏សំខាន់ ដើម្បីជោគជ័យរបស់ពួកគេ នៅក្នុងការសំរេចបានគោលដៅ និង ការអភិវឌ្ឍន៍នៃទំនាក់ទំនងយ៉ាងរឹងមាំនៅក្នុងរង្វង់ការងាររបស់ពួកគេ។ម្យ៉ាងវិញទៀតយើងក៏យកចិត្តទុក្ខដាក់ផងដែរទៅលើ ក្រមសីលធម៌វិជ្ជាជីវៈអោយមានកំរិត ខ្ពស់។ សុចរិតភាព ការប្រុងប្រយ័ត្ន និងតម្លាភាព គឺជាមូលដ្ឋានស្នូល នៃវប្បធម៌ការងារ របស់យើង។

ការចែករំលែកនូវបច្ចេកទេស និង វគ្គបណ្តុះបណ្តាល ត្រូវបានរៀបចំសំរាប់គ្រប់បុគ្គលិកទាំងអស់របស់ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក ជាទៀងទាត់។ ទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ នូវគុណភាព និង ប្រសិទ្ធភាព នៃសេវារបស់យើង។ ក្រុមបុគ្គលិករបស់យើងត្រូវបានរក្សានូវការបោះជំហ៊ានឆ្ពោះទៅមុខ ។

ការបំពេញចិត្តអតិថិជន

> “យើងមានគោលបំណងដើម្បីផ្តល់នូវគុណភាពសេវាដ៏ប្រសើរជាងគេ និងការបំពេញចិត្តអតិថិជនអោយប្រសើរឡើង។”

ការបំពេញចិត្តអតិថិជន

យើងមានគោលបំណងដើម្បីផ្តល់នូវគុណភាពសេវាដ៏ប្រសើរជាងគេ និងការបំពេញចិត្តអតិថិជនអោយប្រសើរឡើង។ គុណភាពសេវាដ៏ប្រសើរជាងគេ អាចបង្កើតបន្ថែមទៀតនូវភាពស្មោះត្រង់របស់អតិថិជន នាំមកនូវឱកាសសំរាប់ការលក់ផលិតផលចម្រុះនិងអតិថិជនដែលផ្សព្វផ្សាយអោយប្រើប្រាសនូវសេវាកម្មរបស់យើងផងដែរ។ កេរ្តិ៍ឈ្មោះរបស់សហគ្រាស គឺ ត្រូវផ្តើមឡើងពីការពេញចិត្តខ្ពស់ ពីសំណាក់អតិថិជន។

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក ផ្តោតទៅលើ សុចរិតភាពអាជីវកម្ម និង យើងធ្វើការយ៉ាងយកចិត្តទុកដាក់ជាមួយអតិថិជន របស់យើង បុគ្គលិក របស់យើង និង សង្គមរបស់យើងដើម្បីអនាគតដ៏ល្អប្រសើរខាងមុខ។ តាមរយៈសេវាប្រកបដោយ វិជ្ជាជីវៈនិង សីលធម៌ យើងបង្កើតនូវភាពជឿជាក់ ទៅវិញទៅមក និង ដៃគូរអាជីវកម្មរយៈពេលវែងជាមួយអតិថិជន របស់យើង។

យើងបានប្រគល់ជូននូវការបែងចែកជំនាញវិជ្ជាជីវៈសំរាប់គ្រប់ៗគ្នា និងគ្រប់អតិថិជន ដើម្បីកាន់កាប់នូវ ប្រតិបត្តិការណ៍ធនាគារពាណិជ្ជនៅក្នុងធនាគារ ឈីហ្វ។ ព័ត៌មានអ្វីទាំងអស់ដែលបានផ្តល់ដោយ ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា)ម.ក គឺជាការកើន ឡើងរហូតដល់ចំនុចគួរអោយកត់ សម្គាល់ និងចម្ងល់របស់អតិថិជនទាំងអស់ត្រូវបានបក ស្រាយយ៉ាងច្បាស់លាស់។ ចំនុច ពិសេសៗដ៏ទៃទៀតរបស់ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក គឺជាការតាមដានដ៏ជាប់លាប់ ចំពោះសំណើរអតិថិជនរបស់យើង ដើម្បីឆ្លើយតបទៅនឹងតំរូវការ និង ការចង់បានរបស់ពួកគេ។ ដូចគ្នានោះផងដែរ យើងស្វែងរកជាទៀងទាត់នូវយោបល់ត្រឡប់របស់ អតិថិជន ដើម្បីដឹងនូវឱកាសអភិវឌ្ឍន៍ផលិតផល និងសេវាហើយដើម្បីប្រាប់ពួកយើងអោយប្រុង ប្រយ័ត្ន ទៅនឹងការរីកចំរើនប្រកបដោយ សក្តានុពល។ យើងមានវិធីសាស្ត្រជាច្រើន ដើម្បីប្រមូលផ្តុំព័ត៌មានពីអតិថិជន តាមរយៈទូរស័ព្ទ ការស្ទង់មតិ ការបំពេញចិត្តរបស់អតិថិជន និង មតិយោបល់ដែលសរសេរដោយអតិថិជន។ យើងនឹងពិនិត្យមើលទៅលើមតិយោបល់របស់អតិថិជនម្តងមួយៗ និង យកនូវតំរូវការ សកម្មភាពសមស្របណាមួយ ដើម្បីធ្វើការដោះស្រាយទៅតាមស្ថានភាពផ្សេងៗគ្នា។

ទិសដៅយុទ្ធសាស្ត្រ

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក បានធ្វើការប្តេជ្ញាចិត្ត ក្នុងការបំពេញនូវ តម្រូវការរបស់អតិថិជននិងជួយពួកគាត់ឲ្យមានភាពជោគជ័យនៅក្នុងវិស័យហិរញ្ញវត្ថុ ព្រមទាំង ក្លាយជាធនាគារបរទេសក្នុងស្រុក ដែលប្រកបដោយភាពច្នៃប្រឌិត អភិរក្ស និងមានប្រសិទ្ធិភាពខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា។ ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក ផ្តល់នូវការគាំទ្រយ៉ាង ខ្លាំងដល់សសរគ្រឹះសេដ្ឋកិច្ចទាំងបួន ដែលជាកត្តាជំរុញអោយ វិស័យសេដ្ឋកិច្ចរីកចំរើនខ្លាំងនៅប្រទេសកម្ពុជារួមមាន៖ ការនាំចេញសម្លៀកបំពាក់ វិស័យទេសចរណ៍ កសិកម្ម និងផ្នែកអចលទ្រព្យ។

ក. យុទ្ធសាស្ត្រទីផ្សារ

យុទ្ធសាស្ត្រអាទិភាពដំបូងគេ របស់ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក គឺដើម្បីបំពេញចិត្តអតិថិជនដែលមានស្រាប់របស់ខ្លួន ដោយផ្តល់អោយនូវផលិតផលដែលបានចម្រាញ់អោយកាន់តែប្រសើរឡើង ជាមួយនឹងអត្រាការប្រាក់ប្រកួតប្រជែងលើទីផ្សារ ដោយស្រប ទៅតាមការវិវត្តនូវតំរូវការចាំបាច់របស់ពួកគេ ទាំងនេះបានបង្ហាញជាភស្តុតាង តាមរយៈ កំណើនតំរូវការជាមូលដ្ឋាន របស់អតិថិជន និង កំណើនជារៀងរាល់ថ្ងៃនៃគុណភាពឥណទានសរុបរបស់យើង (គ្មានឥណទានដែលខូច រហូតដល់ពេលបច្ចុប្បន្ន)។

យុទ្ធសាស្ត្រអាទិភាពទីពីរគឺដើម្បីទាញយកអតិថិជនថ្មីតាមរយៈប្រព័ន្ធផ្សព្វផ្សាយដែលមានប្រជាប្រិយភាព ក្នុងគោលបំណងដើម្បីបង្កើននូវចំនួនអតិថិជនថ្មីៗបន្ថែមទៀត ចូលទៅក្នុងវដ្តនៃការរីកចំរើនក្នុងពេលបច្ចុប្បន្នដែលមានស្រាប់ ដោយធ្វើការពង្រីកនូវបណ្តាញសាខាជាច្រើន ទៅទីកន្លែងដែលមានសក្តានុពល នៅក្នុងរាជធានីភ្នំពេញ ក្នុងខណៈពេលដែលចាប់ផ្តើមនូវការប្តេជ្ញាចិត្តដើម្បីផ្តល់នូវការជឿជាក់ ការច្នៃប្រឌិតសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពរាក់ទាក់ ការប្រើប្រាស់នូវបច្ចេកវិទ្យាទំនើប និង ផ្តោតទៅលើ ការធ្វើឲ្យប្រសើរឡើងជាបន្តបន្ទាប់ តាមរយៈការអភិវឌ្ឍនបុគ្គលិករបស់យើង និង ការទទួលយកនូវជំនាញការចាំបាច់មួយដើម្បីចាប់យកអត្ថប្រយោជន៍ប្រៀបធៀបពីគូប្រកួតប្រជែងរបស់យើង។

បន្ទាប់មកទៀត យើងកំពុងមានផែនការណ៍ពង្រីក ទៅកាន់ខេត្តក្រុងដែលជឿជាក់ថាមាន សក្តានុពលថ្មី ដូចជា ក្រុងព្រះសីហនុ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ និង ខេត្តបាត់ដំបង។ នៅក្នុងរយៈពេល១០ឆ្នាំ យើងជឿជាក់ថា អាចពង្រីកបន្ថែមទៀតជាមួយប្រតិបត្តិការណ៍សាខា នៅក្នុង ខេត្តកណ្តាល ខេត្តពោធិសាត់ ខេត្តព្រៃវែង និង ខេត្តតាកែវ។ វាគឺជាបំណងរបស់យើងផងដែរ ដើម្បីបង្កើតនូវការិយាល័យតំណាង (និង សាខាបន្តបន្ទាប់) នៅក្នុងទីក្រុងហុងកុង នៅពេលសមរម្យណាមួយដើម្បីគាំទ្រអោយប្រសើរឡើងនូវអាជីវកម្មអន្តរជាតិរបស់ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក ។

ខ- ការកំណត់ទីផ្សារគោលដៅ

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក សម្លឹងមើលឃើញនូវបរិយាកាសសេដ្ឋកិច្ច និង សង្គម មានភាពវិជ្ជមាន ដើម្បីពង្រីកនូវ សកម្មភាពរបស់ខ្លួន នៅក្នុង បីឆ្នាំបន្ទាប់។ ធនាគារ បានអភិវឌ្ឍន៍ នូវបែបបទគ្រោងការគ្រប់គ្រងដើមទុនផ្លូវការមួយ ដោយមានគោលដៅដែល បានកំណត់យ៉ាង ច្បាស់លាស់ដើម្បីរក្សានូវកំរិតសមស្របនៃដើមទុន។ ទាំងនេះធានាឱកាស គ្រប់គ្រាន់សម្រាប់ការពង្រីកអាជីវកម្មនាពេលអនាគត។

ធនាគារ បានកំណត់យកនូវទីតាំង ដែលមានសក្តានុពលបំផុត ដែរនឹងត្រូវពង្រីកចាប់តាំងពី ឆ្នាំ២០១៧ ទៅកាន់កន្លែងដែលមានការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុមិនសូវមាន ហើយប៉ុន្តែតម្រូវការមានកំរិតខ្ពស់។

គ- ទំហំ និង និន្នាការទីផ្សារ

ការកើនឡើងនូវតម្រូវការទីផ្សាររបស់ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក រក្សានូវការកើនឡើង ដែលបានបង្ហាញអោយ ឃើញច្បាស់ ដោយកំណើនជាប្រចាំថ្ងៃ នៅក្នុង ទំហំឥណទានប្រកបដោយគុណភាព ចាប់តាំងពីការបង្កើត រហូតដល់ពេលបច្ចុប្បន្ន។ ការរីកចំរើន នៅក្នុងសេដ្ឋកិច្ចទីផ្សារ និង សេដ្ឋកិច្ចកំពុងអភិវឌ្ឍន ត្រូវបានរៀបចំជាគំរោងដើម្បី ធ្វើអោយមានកំណើនឡើងនូវទីផ្សារឥណទាន ដែរបានគាំទ្រដោយតម្រូវការក្នុងស្រុកកាន់តែ ខ្លាំងឡើង ព្រមទាំងការស្តារឡើងវិញនូវតម្រូវការខាងក្រៅ ដែលបានជំរុញ ដោយកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។

ដោយមានឱកាសវិនិយោគក្នុងស្រុកមានកំរិតខ្ពស់ វិស័យធនាគារ និងគ្រឹះស្ថាន ហិរញ្ញវត្ថុ ដ៏ទៃទៀត ដូចជា មីក្រូហិរញ្ញវត្ថុ ដែលបានទទួលនៅផលចំណេញដ៏សន្ធឹកសន្ធាប់ បានទាក់ទាញនូវការវិនិយោគថ្មី ដែរនាំអោយមានការរីកលូតលាស់ក្នុងវិស័យនេះយ៉ាង ឆាប់រហ័ស។ ទាំងនេះបានឆ្លុះបញ្ចាំង ពីការកើនឡើងឥតឈប់ឈរ ក្នុងទ្រព្យសកម្ម ឥណទាន ការដាក់ប្រាក់បញ្ញើ តម្រូវការសម្រាប់ឥណទានធនាគារ និង សេវាកម្មធនាគារដ៏ទៃទៀត។ ភាពជោគជ័យនៅក្នុងវិស័យធនាគារនេះត្រូវបានសន្មត់ដោយគ្មានការសង្ស័យទៅនឹងការ រីកចម្រើនគួរអោយកត់សម្គាល់នៅក្នុង ប្រព័ន្ធហិរញ្ញវត្ថុ និងធនាគារក្នុងព្រះរាជាណាចក្រមួយនេះ ដែលបានបន្តដើម្បីអភិវឌ្ឍន៍ និងធ្វើអោយប្រសើរឡើងជាលំដាប់។ ការជួយជ្រោមជ្រែងទាំងនេះ បានកសាងនូវទំនុកចិត្ត និង ជំនឿទុកចិត្តថែមទៀតពី សាធារណជន និងអ្នកវិនិយោគនៅក្នុងវិស័យធនាគារ និងវិស័យពាក់ព័ន្ធផ្សេងទៀត ជាលទ្ធផល តម្រូវការមានកំរិតខ្ពស់ សម្រាប់សេវាកម្មហិរញ្ញវត្ថុ និង ធនាគារ ព្រមទាំងសេវាកម្មពាក់ព័ន្ធផ្សេងទៀត។ ការផ្តល់នូវវត្តមាននាពេលបច្ចុប្បន្ននៅក្នុងការរីកចំរើន នៃតម្រូវការទីផ្សារចំពោះសេវាកម្មធនាគារទាំងនោះរួមមាន ឥណទាន ប្រាក់បញ្ញើ និងសេវាកម្មផ្សេងៗទៀត នឹងកើនឡើងចំពោះសេវាកម្មទីផ្សារធនាគារ នៅតែល្អដដែល។

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក មានផែនការណ៍បង្កើតនូវទំនាក់ទំនងល្អជាមួយនឹងក្រុមហ៊ុនជាច្រើនទៀត ដែលរាប់ចាប់តាំងពីមុខរបរនៅតាមផ្ទះ រហូតដល់អាជីវកម្មខ្នាតមធ្យម ដើម្បីផ្តល់អោយពួកគេនូវសេវាកម្មរបស់ធនាគារ។ តាមរយៈផែនការណ៍អាជីវកម្មធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក ជឿជាក់ថា អាជីវកម្មទាំងនោះ អាចនឹងមក ទទួលយកនូវសេវាកម្មធនាគារ ក្នុងគោលបំណងដើម្បីពង្រីក នូវអាជីវកម្ម របស់ពួកគេ។នេះមានន័យថា ទំហំទីផ្សារ និង និន្នាការប្រើប្រាស់សេវា ធនាគារ នឹងត្រូវបាន ពង្រីកកាន់តែធំឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

ឃ- ការវិភាគពីការប្រកួតប្រជែង

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក មានបុគ្គលិកក្នុងស្រុកដែលមានវិជ្ជាជីវៈជំនាញជាច្រើនផ្នែកនៅក្នុងវិស័យ ធនាគារ គណនេយ្យការគ្រប់គ្រងឥណទាន ប្រតិបត្តិការណ៍ ទីផ្សារ និង ការគ្រប់គ្រងធនធានមនុស្ស បូករួមទាំង ថ្នាក់ដឹកនាំកំពូលដែល មានសាវតារមកពីតំបន់អាស៊ីប៉ាស៊ីហ្វិក ដូចជា ទីក្រុងហុងកុង ប្រទេសចិន កម្ពុជា...។ល។ នេះបានផ្តល់អំណាចអោយយើង នូវសេវាដែលមានគុណភាពដើម្បីបំពេញតំរូវការក្នុងស្រុក អោយបានច្រើនបំផុតសំរាប់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជាជាមួយនឹងចំណេះដឹងដ៏ទូលំទូលាយនៅក្នុងការអភិវឌ្ឍន៍អនាគតរបស់ធនាគារ។

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក មានបំណងដើម្បីអភិវឌ្ឍន៍ជាធនាគារពាណិជ្ជដែរមានសេវា ពេញលេញ ជាមួយវិស័យអាជីវកម្មមួយចំនួនដូចជា៖

- កសិកម្ម និងអាជីវកម្មខ្នាតតូច
- អាជីវកម្មជាក្រុមហ៊ុន
- អាជីវកម្មជាបុគ្គល
- រតនាគារ

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក នឹងធ្វើការយ៉ាងជិតស្និតជាមួយធនាគារជាតិនៃកម្ពុជា និង ព្រមទាំងធនាគារពាណិជ្ជដែលបានបង្កើតនៅក្នុងស្រុក និង សាខាធនាគារបរទេស ដើម្បីរក្សានូវតួនាទីដ៏សំខាន់នៅក្នុងវិស័យធនាគារក្នុងប្រទេសកម្ពុជា។ យើងនឹងធ្វើការយ៉ាងជិតស្និតផងដែរ ដើម្បីគាំទ្រដល់ អង្គការ ឬ ក្រុមហ៊ុនស្របច្បាប់ដែលមានស្រាប់ ដែលចូលរួមក្នុងសកម្មភាពឥណទានជនបទ។

ក្រុមប្រឹក្សាភិបាល និង គណៈគ្រប់គ្រង នៃធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក គឺជាអ្នកដែលមានវិជ្ជាជីវៈ និងឆន្ទៈមុះមុត។ គណៈគ្រប់គ្រង គឺមានចំណេះដឹងវិជ្ជាជីវៈទៅលើ ធនាគារពាណិជ្ជ ធនាគារឯកទេស ធនាគារឯកទេសជនបទ ឥណទានសហគមន៍ ក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុ និង បានបញ្ជាក់នូវការយល់ដឹងនៃលក្ខណៈសម្បត្តិតែមួយគត់ នៃគំរូអាជីវកម្មសេវាហិរញ្ញវត្ថុ នីមួយៗ ព្រមទាំង តំរូវការ និងការចង់បាន នៃក្រុមអតិថិជន។

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក ធ្វើប្រតិបត្តិការណ៍របស់ខ្លួនជាមួយការអនុម័តឥណទានដ៏រឹងមាំមួយ ប្រព័ន្ធតាមដាន និងប្រព័ន្ធគ្រប់គ្រងហានិភ័យ ដើម្បីធានានូវភាពរឹងមាំ និងស្ថេរភាពហិរញ្ញវត្ថុនៃប្រតិបត្តិការណ៍ធនាគារ។ ធនាគារធ្វើការអនុម័តប្រព័ន្ធតាមដានឥណទានជាប្រាំផ្នែក ជាមួយនឹងតំលៃអត្រាការប្រាក់ដោយផ្អែកលើហានិភ័យ ដើម្បីធានានូវការគ្រប់គ្រងហានិភ័យដ៏ត្រឹមត្រូវមួយ។

ការពង្រីកអាជីវកម្ម

នៅក្នុងបរិយាកាសអាជីវកម្មដែរ មានភាពអនុគ្រោះល្អប្រសើរដូចជា កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ស្ថេរភាពបរិយាកាសនយោបាយនិងសក្តានុពលដ៏អស្ចារ្យព្រមទាំងមានលក្ខខណ្ឌអនុគ្រោះជាច្រើនទៀត ធនាគារ ឈីហ្វ នឹងបង្កើតសាខាជាច្រើនក្នុងប៉ុន្មានឆ្នាំខាងមុខទៀតនៅក្នុងរាជធានីភ្នំពេញក្នុងគោលបំណងដើម្បីពង្រឹងនូវអាជីវកម្ម របស់ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក និង ទទួលយកផល ប្រយោជន៍ ពីការរីកចម្រើននៃសេដ្ឋកិច្ចរបស់ ប្រទេសកម្ពុជា និង ការកើនឡើងនៃតម្រូវការ សេវាកម្មធនាគារ។

បណ្ដាញសាខា

មានសក្តានុពលអាជីវកម្មដ៏ធំសម្បើម ដើម្បីបង្កើតសាខានៅ ក្នុងរាជធានីភ្នំពេញដែលត្រូវ បានជ្រើសរើសជាក់ ដើម្បីពង្រីកនូវចំណែកទីផ្សារទទួលនិង នូវសក្តានុពលជំនួញលើវិស័យ ធនាគារពីផែនការណ៍ពង្រីកសាជីវកម្មថ្មីរបស់យើង។ ទីកន្លែងទាំងនោះស្ថិតនៅទួលទំពូង/អូរឡាំពិក តាម បណ្ដោយ មហាវិថីនរោត្តម សង្កាត់ស្ទឹងមានជ័យ និង ផ្សេងៗទៀត ដែលជាទីកន្លែងដែលតម្រូវការមានកំរិតខ្ពស់។ ដើម្បីសម្រេចនូវគោលដៅរបស់យើង យើងត្រូវការកសាងកេរ្តិ៍ឈ្មោះរបស់ធនាគារ ឈីហ្វ ហើយនឹងដើម្បីបង្កើតនូវបណ្ដាញអាជីវកម្មមួយ ក្នុងគោលបំណងចង្អុលបង្ហាញនូវវឌ្ឍនភាពរបស់ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក និងភាពខុសប្លែករបស់ធនាគារ ឈីហ្វ ពីគូប្រកួតប្រជែង។

អាសយដ្ឋាន ការិយាល័យកណ្ដាល

ផ្ទះលេខ សេ០១ ផ្លូវ អ៊ែ១១ កែងនឹងផ្លូវ៧០ ភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ទូរស័ព្ទ : 855-23-900 878
ទូរសារ : 855-23-900 858
អ៊ីម៉ែល : info@chiefholdings.com.kh
គេហទំព័រ : www.chiefbank.com.kh

អាសយដ្ឋាន សាខាច្បារអំពៅ

អាគារលេខ ញ ॥ ០០៤៦ ផ្លូវជាតិលេខ១ ភូមិដើមស្លែងសង្កាត់ច្បារអំពៅទី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

ទូរស័ព្ទ : 855-23-230 488
ទូរសារ : 855-23-230 477

អាសយដ្ឋាន ផ្សារអូឡាំពិក

ផ្ទះលេខ ២០ ២១ និង២១ សេ ផ្លូវលេខ២៧៤ សង្កាត់វាលវង់ ខណ្ឌ៧មករាជធានីភ្នំពេញ

ទូរស័ព្ទ : 855-23-212 878
ទូរសារ : 855-23-212 879

របាយការណ៍ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

សម្រាប់ការិយបរិច្ឆេទដែល បានបញ្ចប់
ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2019 និង ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2018

- ព័ត៌មានអំពីធនាគារ ២៤
- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ២៥-២៨
- របាយការណ៍សវនករឯករាជ្យ ២៩-៣០
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ៣១
- របាយការណ៍ចំណេញឬខាត និងលទ្ធផលលម្អិតផ្សេងៗ ៣២
- របាយការណ៍បម្រែបម្រួលមូលធន ៣៣-៣៤
- របាយការណ៍លំហូរសាច់ប្រាក់ ៣៥-៣៦
- កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ៣-១០៥

ព័ត៌មានអំពីធនាគារ

ធនាគារ	ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ភីអិលស៊ី	
ចុះបញ្ជីពាណិជ្ជកម្មលេខ	00005793	
ការិយាល័យចុះបញ្ជី	មជ្ឈមណ្ឌលរាជធានីភ្នំពេញ,ផ្ទះលេខសេ 01 ផ្លូវ អ៊ែ 11កែងនឹងផ្លូវ 70, ភូមិ 1 សង្កាត់ស្រះចក, ខណ្ឌ ដូនពេញ, រាជធានីភ្នំពេញ	
នាយកប្រតិបត្តិ	លោក Chau Chung Kai Peter	
ក្រុមប្រឹក្សាភិបាល	លោក Chau Chung Kai Peter	ប្រធានក្រុមប្រឹក្សាភិបាល
	លោក Lam Wai Chuen	អភិបាល
	កញ្ញា Ng Siu Mui	អភិបាល
	លោក Ye Haiya	អភិបាល
	លោក Chan Kwok Cheung	អភិបាលឯករាជ្យ
	លោក Cheung Ka Wai	អភិបាលឯករាជ្យ
សវនករ	ក្រុមហ៊ុន ឌីឡយធ៍ (ខេមបូឌា) ខូ អិលធីឌី	

របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្ស ក្នុងការដាក់បង្ហាញរបាយការណ៍របស់ខ្លួន និង របាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួចរបស់ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ "ធនាគារ")សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2019 និង ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2018។

សកម្មភាពចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺផ្តល់ឥណទានដល់អតិថិជន និងសេវាផ្សេងៗ ដែលទាក់ទងនឹងវិស័យហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

លទ្ធផលហិរញ្ញវត្ថុ

ខាងក្រោមជាលទ្ធផលហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់ធនាគារសម្រាប់ការិយបរិច្ឆេទដែល បានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 និង ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2018

	ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2019		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2018		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់ចំណេញមុនដកពន្ធ	1,562,665	6,331,919	364,359	1,473,832	974,009	3,939,867
ចំណាយពន្ធលើប្រាក់ចំណូល	(356,310)	(1,443,768)	(181,635)	(734,714)	(230,031)	(930,475)
ប្រាក់ចំណេញសុទ្ធក្នុងឆ្នាំ	1,206,355	4,888,151	182,724	739,118	743,978	3,009,391

ភាគលាភ

ធនាគារមិនមាន ការប្រកាស ឬបង់ភាគលាភនៅក្នុងកំឡុងឆ្នាំនោះទេ (2018៖ គ្មាន; 2017៖ 1,000,000 ដុល្លារអាមេរិក).

ដើមទុន

នៅថ្ងៃទី 7 ខែមិថុនា ឆ្នាំ 2018 ធនាគារជាតិបានអនុម័តឲ្យតំឡើងដើមទុនបន្ថែម ចំនួន 36,200,000 ដុល្លារអាមេរិក ដែលធ្វើ ឲ្យដើម ទុនចុះបញ្ជីត្រូវកើនដល់ 75,000,000 ដុល្លារអាមេរិក។ ដើមទុនចុះបញ្ជីថ្មីចំនួន75,000,000 ដុល្លារអាមេរិក ដែលមានភាគហ៊ុន ចំនួន75,000,000 និងតម្លៃចារឹក 1ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន ត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី 27 ខែមិថុនា ឆ្នាំ 2018។

ទុនបម្រុង និង សំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ការលុបចេញពីបញ្ជី និង សំវិធានធនលើទ្រព្យសកម្មហិរញ្ញវត្ថុ

មុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមហេតុផល ដើម្បីដឹងថាសកម្មភាពត្រូវបានធ្វើឡើង ទាក់ទងនឹងការលុបចោលទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមានការរំពឹងទុក សមហេតុផលក្នុងការស្តារឡើងវិញ នូវលំហូរសាច់ប្រាក់ តាមកិច្ចសន្យាទាំងមូល ឬចំណែកណាមួយ និងបានធ្វើសំវិធានធន លើការខាតបង់ឥណទានរំពឹងទុកលើទ្រព្យសកម្មហិរញ្ញវត្ថុនិង ជឿ ជាក់ថារាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានដឹងថានឹងមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញ នូវលំហូរសាច់ប្រាក់តាមកិច្ចសន្យាត្រូវបានលុបចោល ហើយបានធ្វើសំវិធានធនគ្រប់គ្រាន់ សម្រាប់ការបាត់បង់ឥណទានដែលរំពឹងទុក លើទ្រព្យសកម្ម ហិរញ្ញវត្ថុត្រូវបានធ្វើឡើង។

នៅ កាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងអំពី កាលៈទេសៈណាមួយដែលអាចបង្ហាញពីចំនួនទឹកប្រាក់ នៃ សំវិធានធនសម្រាប់ការខាតបង់ឥណទាន ដែលរំពឹងទុកលើទ្រព្យសកម្មហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារមិនមានលក្ខណៈ មិនគ្រប់គ្រាន់រហូតដល់កម្រិតជាសារវន្តនោះទេ។

ទ្រព្យសកម្ម

មុនពេលរបាយការណ៍ហិរញ្ញវត្ថុ ធនាគារត្រូវបានរៀបចំរួច ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមហេតុផលដើម្បីធានាថា ទ្រព្យសកម្មណាមួយដែលទំនងជាមិនត្រូវបានលក់ចេញក្នុងដំណើរការអាជីវកម្មធម្មតាតាមតម្លៃរបស់ពួកគេ ដូចដែលបានបង្ហាញនៅក្នុងកំណត់ត្រាគណនេយ្យរបស់ធនាគារ ត្រូវបានគេកត់ត្រាទៅចំនួនដែលពួកគេរំពឹងថានឹងទទួលបាន។

នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងអំពីករណីណាមួយដែលនឹងធ្វើឱ្យតម្លៃដែលត្រូវបានដាក់បញ្ចូលដោយទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានការយល់ ច្រឡំ។

វិធីសាស្ត្រក្នុងការវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុង របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ថាមានភាពមិនត្រឹមត្រូវនោះទេ។

បំណុលជាយថាភាព និង បំណុលផ្សេងៗ

នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានទេនូវ:

(ក) កម្រៃលើទ្រព្យសកម្មរបស់ ធនាគារដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំហិរញ្ញវត្ថុ ដែលធានាលើបំណុលរបស់បុគ្គលផ្សេងទៀត ឬ

(ខ) បំណុលយថាភាពណាមួយទាក់ទងនឹងធនាគារដែលបានកើតឡើងតាំងពីដំណាច់ឆ្នាំហិរញ្ញវត្ថុក្រៅពី មូលហេតុធម្មតានៃអាជីវកម្មធនាគារ។

មិនមានការជាប់បំណុលយថាភាព ឬទំនួលខុសត្រូវផ្សេងទៀតរបស់ ធនាគារបានក្លាយជាការអនុវត្តឬទំនងជាអាចអនុវត្តបានក្នុងរយៈពេល ១២ខែបន្ទាប់ពីបញ្ចប់ឆ្នាំហិរញ្ញវត្ថុដែលតាមគំនិតរបស់ក្រុមប្រឹក្សាភិបាលឬនឹងមានឥទ្ធិពលយ៉ាងខ្លាំងដល់សមត្ថភាពរបស់ ធនាគារដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលពួកគេត្រូវដល់កំណត់។

ការផ្លាស់ប្តូរនៃហេតុការណ៍

គិតត្រឹមការបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលមិនបានរៃកញែក នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍
ហិរញ្ញវត្ថុរបស់ធនាគារដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវទេ។

ប្រតិបត្តិការមិនប្រក្រតី

នៅក្នុងមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារសម្រាប់ឆ្នាំនេះមិនមាន រងផលប៉ះពាល់យ៉ាងខ្លាំងពីប្រតិបត្តិការណាមួយ ឬ ព្រឹត្តិការណ៍ដែលមានភាពមិនប្រក្រតី និងជា សារវន្ត។

នៅក្នុងមតិរបស់ក្រុមប្រឹក្សាភិបាល មិនមានការកើតឡើងក្នុងចន្លោះពេលដំណាច់ឆ្នាំនិងកាលបរិច្ឆេទនៃរបាយការណ៍នេះទេ ប្រតិបត្តិការណាមួយឬព្រឹត្តិការណ៍ដែលមានភាពមិនប្រក្រតី និងជាសារវន្តដែលអាចមាន ឥទ្ធិពលលើលទ្ធផលនៃប្រតិបត្តិការរបស់ធនាគារសម្រាប់ឆ្នាំបច្ចុប្បន្នដែល របាយការណ៍នេះត្រូវបានធ្វើឡើង។

ព្រឹត្តិការណ៍ក្រោយការបរិច្ឆេទនៃរបាយការណ៍ មាននៅក្នុង Account

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលកាន់តំណែងក្នុងឆ្នាំនិងកាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចជា:

លោក Chau Chung Kai Peter	ប្រធានក្រុមប្រឹក្សាភិបាល
លោក Lam Wai Chuen	អភិបាល
កញ្ញា Ng Siu Mui	អភិបាល
លោក Ye Haiya	អភិបាល
លោក Chan Kwok Cheung	អភិបាលឯករាជ្យ
លោក Cheung Ka Wai	អភិបាលឯករាជ្យ

ផលប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

លោក Chau Chung Kai Peter គឺជាភាគទុនិកមេរបស់ធនាគារ។
ពុំមានអភិបាលផ្សេងទៀត ដែលបានកាន់កាប់ឬពាក់ព័ន្ធដោយផ្ទាល់នៅក្នុងភាគហ៊ុនរបស់ធនាគារនៅក្នុងកំឡុងឆ្នាំឡើយ។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុងពេលនិងនៅចុងឆ្នាំនេះគ្មានការរៀបចំណាមួយដែលធនាគារ ជាភាគីដែលមានគោលបំណងជួយឱ្យអភិបាលធនាគារទទួលបានអត្ថប្រយោជន៍តាមរយៈការទទួលបានភាគហ៊ុន នៅក្នុងការសងបំណុលរបស់ធនាគារឬក្រុមហ៊ុនផ្សេងទៀត ។
ចាប់តាំងពីចុងឆ្នាំហិរញ្ញវត្ថុមុន ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់របស់ធនាគារ ឬមានសិទ្ធិទទួលបាន អត្ថប្រយោជន៍ណាមួយ (ក្រៅ ពីអត្ថប្រយោជន៍ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) ដោយហេតុផលកិច្ចសន្យាដែលធ្វើឡើងដោយធនាគារ ឬសាជីវកម្មដែលពាក់ព័ន្ធ ជាមួយក្រុមហ៊ុនដែលអភិបាលជាសមាជិកឬជាមួយក្រុមហ៊ុនដែលអភិបាលមានការចាប់អារម្មណ៍ផ្នែកហិរញ្ញវត្ថុច្រើនជាងអ្វី ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារៈជាអ្នកទទួលខុសត្រូវ ដើម្បីធានាថារបាយការណ៍ហិរញ្ញវត្ថុបានផ្តល់នូវភាពត្រឹមត្រូវ អំពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាការិយបរិច្ឆេទថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 និង ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2018 និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ ការិយបរិច្ឆេទដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលត្រូវបានតម្រូវឲ្យៈ

អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្របដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព;
(II) អនុវត្តទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឲ្យមានភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ;
(III) រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព;
(IV) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យក្នុងការសន្មត ថាធនាគារ នឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគត;
(V) ត្រួតពិនិត្យនិងដឹកនាំធនាគារឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់ការតម្រូវ ដូចបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

ជាមតិរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញយ៉ាងត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជា សារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ2019 និង ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2018 ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលជឿជាក់ថា ធនាគារមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទូទាត់បំណុល នៅពេលដល់កាលកំណត់សង។

ចុះហត្ថលេខាតាងនាមឲ្យក្រុមប្រឹក្សាភិបាល

លោក Chau Chung Kai Peter
ប្រធានក្រុមប្រឹក្សាភិបាល

ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ:

របាយការណ៍សវនករឯករាជ្យ

ជូនចំពោះភាគទុនិកនៃធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ភីអិលស៊ី

មតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារពាណិជ្ជឈីហ្វ (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថា "ធនាគារ") ដែលរួម បញ្ចូលរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របស់ធនាគារគិតត្រឹមថ្ងៃទី 31 ខែធ្នូឆ្នាំ 2019 និង ថ្ងៃទី 31 ខែធ្នូឆ្នាំ 2018 និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗទៀត របាយការណ៍បម្រែបម្រួលមូលធននិងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ឆ្នាំ និង កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្ដីសង្ខេបនៃគោលនយោបាយគណនេយ្យ សំខាន់ៗដូចមានចែងនៅទំព័រ10 ដល់113។

ជាមតិយោបល់របស់យើងខ្ញុំ

របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពត្រឹមត្រូវជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ ធនាគារ នាថ្ងៃទី 31 ខែធ្នូឆ្នាំ 2019 និង ថ្ងៃទី 31 ខែធ្នូឆ្នាំ 2018 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារ របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។

មូលដ្ឋានសម្រាប់ការផ្តល់មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាម ស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើង ខ្ញុំដោយអនុលោមតាមស្តង់ដារនេះ ត្រូវបានពិពណ៌នាបន្ថែមនៅក្នុងការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មទៅលើរបាយការណ៍ ហិរញ្ញវត្ថុនៃរបាយការណ៍នេះ។ យើងខ្ញុំឯករាជ្យពី ធនាគារដោយអនុលោមតាមការតម្រូវក្រមសីលធម៌ដែលពាក់ព័ន្ធ និងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅកម្ពុជា ព្រមទាំងបានបំពេញការខុសត្រូវលើក្រមសីលធម៌ផ្សេងៗទៀតស្របតាមតម្រូវការ ទាំងនេះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងបានទទួលគឺគ្រប់គ្រាន់និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់មតិយោបល់របស់យើង។

បញ្ហាផ្សេងៗ

ធនាគារបានរៀបចំនូវរបាយការណ៍ហិរញ្ញវត្ថុមួយផ្សេងទៀត សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងបទបញ្ញត្តិ និងគោលការណ៍ណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជា ដែលយើងខ្ញុំបានចេញនូវរបាយការណ៍សវនករមួយផ្សេងទៀតទៅភាគទុនិកនៃធនាគារនាថ្ងៃទី 28 ខែ មីនា ឆ្នាំ 2019។

ព័ត៌មានផ្សេងៗក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍សវនករ

គណៈគ្រប់គ្រងទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមានព័ត៌មានអំពីធនាគារ និងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលនៅទំព័រទី 1 និង ទំព័រទី 2 ទៅ ទំព័រទី 6 ប៉ុន្តែមិនបានរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍សវនករទេ។

មតិយោបល់របស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុមិនគ្របដណ្តប់ព័ត៌មានផ្សេងៗហើយយើងខ្ញុំមិនបានធ្វើការសន្និដ្ឋានអះអាងលើ ព័ត៌មានផ្សេងៗឡើយ។

ទាក់ទងទៅនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺអានព័ត៌មាន ផ្សេងៗ និងពិចារណាថាតើព័ត៌មានផ្សេងៗមិនស្របគ្នាជាមួយរបាយការណ៍ហិរញ្ញវត្ថុជាសារវន្តឬជាមួយចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ឬកើតឡើងពីកំហុសឆ្គងជាសារវន្ត។ ប្រសិនបើផ្អែកទៅលើការងាររបស់យើងខ្ញុំដែលបានអនុវត្ត ហើយសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មាន ផ្សេងៗយើងខ្ញុំនឹងធ្វើការរាយការណ៍ទៅលើភាពជាក់ស្តែងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ឡើយ។

ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវលើការរៀបចំ និងបង្ហាញភាពត្រឹមត្រូវលើរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើប្រព័ន្ធត្រួត ពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការប៉ាន់ប្រមាណពីលទ្ធភាពរបស់ ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការបង្ហាញបញ្ហាដែលពាក់ព័ន្ធ នឹងការបន្តនិរន្តរភាពប្រសិនបើមាន និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពគណនេយ្យលើកលែងតែគណៈគ្រប់គ្រងមានបំណងរំលាយ ឬបញ្ឈប់អាជីវកម្ម ឬមិនមានជម្រើសជាក់ស្តែងណាមួយក្រៅពីអនុវត្តដូច្នេះ។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវលើការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបានអំណះអំណាងដែលសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុ គឺមិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងដើម្បីបង្ហាញ របាយការណ៍សវនករ ដែលរួមបញ្ចូលមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងដែលសមហេតុផល គឺជា អំណះអំណាងកម្រិតខ្ពស់ប៉ុន្តែមិនមែនជាការធានាថា ការធ្វើសវនកម្មអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជានឹងតែងតែរកឃើញកំហុសឆ្គងជាសារវន្តនៅពេលដែលវាមាននោះទេ។ កំហុសឆ្គងនេះអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានពិចារណាជាកំហុសឆ្គងជាសារវន្ត ប្រសិនបើកំហុសនីមួយៗ ឬកំហុសសរុបមានឥទ្ធិពលដល់ការសម្រេចចិត្ត សេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាយើងបានធ្វើការ វិនិច្ឆ័យ និងការប៉ាន់ប្រមាណតាមវិជ្ជាជីវៈ។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុទោះជា បណ្តាល មកពីការក្លែងបន្លំឬកំហុសឆ្គងក៏ដោយ កំណត់ និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹង ហានិភ័យទាំងនោះដើម្បីទទួលបានភស្តុតាងពីការធ្វើសវនកម្ម ដែលគ្រប់គ្រាន់ និងសមរម្យ ដើម្បីផ្តល់ជាមូលដ្ឋានក្នុងការផ្តល់មតិយោបល់។ ហានិភ័យដែលមិនបានរកឃើញកំហុសឆ្គងជាសារវន្តពីការ

  ក្លែងបន្លំ គឺធ្ងន់ធ្ងរជាងកំហុសឆ្គងធម្មតា ខណៈដែលការក្លែងបន្លំអាចបណ្តាលមកពីការឃុបឃិត ការក្លែងបន្លំ ការលុបចោលដោយចេតនា ការថ្លែងខុស ឬការបំពានលើការគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបានការយល់ដឹងពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មដើម្បីរៀបចំនីតិវិធី សវនកម្ម ដែលសមរម្យទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងបញ្ចេញមតិទៅលើ ប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារឡើយ។
- វាយតម្លៃភាពត្រឹមត្រូវ នៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលពាក់ព័ន្ធនានាដោយគណៈគ្រប់គ្រង។
- សន្និដ្ឋានភាពសមហេតុផល លើមូលដ្ឋាននៃការប្រើប្រាស់គោលការណ៍គណនេយ្យនិរន្តរភាព នៃដំណើរការអាជីវកម្មរបស់គណៈគ្រប់គ្រង និងផ្អែកទៅលើភស្តុតាងសវនកម្មដែលបានទទួលថាតើភាពមិនប្រាកដជាសារវន្តកើតមានឡើងដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចមានភាពមិនច្បាស់លាស់ទៅលើ លទ្ធភាពរបស់ធនាគារដើម្បីបន្តនិរន្តរភាពនៃដំណើរការអាជីវកម្មឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំត្រូវបានតម្រូវឲ្យមានការទាញចំណាប់អារម្មណ៍នៅក្នុងរបាយការណ៍របស់សវនករ ទៅលើការបង្ហាញដែល ពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការបង្ហាញមិនគ្រប់គ្រាន់យើងខ្ញុំត្រូវបញ្ជាក់នៅក្នុងមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំផ្អែកទៅលើភស្តុតាងសវនកម្ម ដែលទទួលបានរហូតដល់ថ្ងៃនៃរបាយការណ៍សវនកម្ម។ ទោះជាយ៉ាងណា ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឲ្យ ធនាគារបញ្ឈប់ការបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម។
- វាយតម្លៃការបង្ហាញជារួម រចនាសម្ព័ន្ធ និងខ្លឹមសារ នៃរបាយការណ៍ហិរញ្ញវត្ថុរួមទាំងការបង្ហាញ ថាតើ របាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការជាមូលដ្ឋាន និងព្រឹត្តិការណ៍នៅក្នុងការទទួលបានការបង្ហាញ ដែលត្រឹមត្រូវ។

យើងខ្ញុំរាយការណ៍ជូនអ្នកទទួលបន្ទុកអភិបាលកិច្ច ពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗដូចជាវិសាលភាព និងពេលវេលានៃការធ្វើសវនកម្ម និងបញ្ហាសវនកម្មសំខាន់ៗរួមទាំងកង្វះខាតសារវន្តនៃការត្រួតពិនិត្យផ្ទៃក្នុង ដែលបានរកឃើញនៅក្នុងអំឡុងពេលធ្វើសវនកម្មរបស់ យើងខ្ញុំ។

តំណាងក្រុមហ៊ុន ឌីឡូយធ៍ (ខេមបូឌា) ខូ អិលធីឌី

អុឹង ឥមសុភ័ក្រ្តា
នាយក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី 15 ខែ ឧសភា ឆ្នាំ 2020

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

គិតត្រឹម ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 និង ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

	កំណត់	ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2017	
	សម្គាល់	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្ម	6	2,844,371	11,590,812	2,508,273	10,078,241	97,295	392,780
សាច់ប្រាក់ក្នុងដៃ	7	19,045,026	77,608,481	14,294,434	57,435,036	40,101,474	161,889,651
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	8	608,585	2,479,984	15,402,227	61,886,148	125,234	505,570
សមតុល្យនៅធនាគារផ្សេងៗ	9	77,745,040	316,811,038	44,011,194	176,836,977	33,608,083	135,675,831
ឥណទានផ្តល់ដល់អតិថិជន	10	416,530	1,697,360	695,533	2,794,652	135,027	545,104
ទ្រព្យសកម្មផ្សេងៗ	11	2,515,117	10,249,102	1,341,005	5,388,158	1,273,129	5,139,622
ទ្រព្យសម្បត្តិ និងបរិក្ខារ	12	1,603,780	6,535,404	-	-	-	-
សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម	13	614,743	2,505,078	364,926	1,466,273	395,059	1,594,853
ទ្រព្យសកម្មអរូបី	14	174,441	710,847	165,927	666,695	107,045	432,141
ទ្រព្យសកម្មពន្ធពន្យារ							
ទ្រព្យសកម្មសរុប		105,567,633	430,188,104	78,783,519	316,552,179	75,842,346	306,175,551
បំណុល	15	26,220,095	106,846,887	2,435,707	9,786,671	-	-
ប្រាក់បញ្ញើរបស់អតិថិជន	16	1,644,788	6,702,511	-	-	-	-
បំណុលភតិសន្យា	14	307,329	1,252,366	206,491	829,681	189,598	765,407
បំណុលពន្ធសកម្ម	17	159,666	650,640	111,921	449,699	84,254	340,134
បំណុលផ្សេងៗ							
បំណុលសរុប		28,331,878	115,452,404	2,754,119	11,066,050	273,852	1,105,541
មូលធន							
ដើមទុន	18	75,000,000	305,625,000	75,000,000	301,350,000	38,800,000	156,635,600
ការបន្ថែមដើមទុន	18	-	-	-	-	36,200,000	146,139,400
ទុនបម្រុងតាមបទបញ្ញត្តិ		780,513	3,180,590	442,203	1,776,772	-	-
ប្រាក់ចំណេញរក្សាទុក		1,455,242	5,883,709	587,197	2,366,389	568,494	2,292,962
លម្អៀងនៃការប្តូររូបិយប័ណ្ណ		-	46,402	-	(7,032)	-	2,048
មូលធនសរុប		77,235,755	314,735,700	76,029,400	305,486,129	75,568,494	305,070,010
បំណុល និងមូលធនសរុប		105,567,633	430,188,104	78,783,519	316,552,179	75,842,346	306,175,551

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រ 18 ដល់ 113 គឺជាផ្នែកសំខាន់មួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍ចំណេញ ឬ ខាត និង លទ្ធផលលម្អិតផ្សេងៗ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 និង ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

	កំណត់សម្គាល់	ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2018		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2017	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណូលការប្រាក់		5,888,435	23,859,939	3,441,935	13,922,627	3,047,753	12,328,161
ចំណាយការប្រាក់		(531,099)	(2,152,013)	(7,793)	(31,523)	-	-
ចំណូលពីការប្រាក់សុទ្ធ	20	5,357,336	21,707,926	3,434,142	13,891,104	3,047,753	12,328,161
ចំណូលពីកម្រៃជើងសារ		785	3,181	3,972	16,067	3,824	15,468
ចំណាយលើកម្រៃជើងសារ		(1,915)	(7,760)	(3,066)	(12,402)	-	-
ចំណូលសុទ្ធពីកម្រៃជើងសារ	21	(1,130)	(4,579)	906	3,665	3,824	15,468
ចំណូល / (ខាត) ផ្សេងៗ	22	(90,338)	(366,050)	22,034	89,128	-	-
សំវិធានធនលើការខាតបង់លើ ឧបករណ៍ ហិរញ្ញវត្ថុ	23	308,050	1,248,219	(258,975)	(1,047,554)	(29,701)	(120,141)
ចំណាយបុគ្គលិក	24	(1,851,429)	(7,501,990)	(1,218,977)	(4,930,762)	(787,655)	(3,186,064)
រំលស់	25	(849,304)	(3,441,380)	(377,612)	(1,527,441)	(263,495)	(1,065,837)
យោងតាមប្រកាសនេះ ធនាគារត្រូវធ្វើសំវិធានធនសម្រាប់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដោយអនុលោម តាមបទប្បញ្ញត្តិ ទន្ទឹមគ្នានឹងការគណនាសំវិធានធនដោយយោងតាមស្តង់ដា CIFRSs។ សំវិធានធនដែលគណនាតាម CIFRSs ត្រូវបានទទួលស្គាល់និងកត់ត្រា។ ចំនួនលើសនៃសំវិធានធនដែលបានមកពីការគណនាស្របតាមបទប្បញ្ញត្តិ ប្រៀបធៀបទៅនឹងការគណនាតាម CIFRSs នឹងត្រូវផ្ទេរពីគណនីប្រាក់ចំណេញរក្សាទុក ទៅក្នុងគណនីទុនបម្រុង តាមបទប្បញ្ញត្តិ ក្នុងខ្ទង់មូលធនរបស់ភាគទុនិក។

នៅថ្ងៃ១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា បានចេញសារាចរណែនាំលេខ B7-018-001 ដើម្បីបញ្ជាក់ បន្ថែម លើការអនុវត្តប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើឱនភាព ។

យោងតាមសារាចរនេះ ធនាគារត្រូវធ្វើការគណនាសំវិធានធនសម្រាប់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដោយអនុលោមតាម បទប្បញ្ញត្តិ ដោយហ្វាស៊ីលីធីត្រូវបានចាត់ជា 5 ថ្នាក់ ដែលមានអត្រាសំវិធានធន ដូចខាងក្រោម៖

ចំណាត់ថ្នាក់	ចំនួនថ្ងៃដែលហួសកាលកំណត់សង	អត្រាសំវិធានធន
សំវិធានធនទូទៅ		
ហ្វាស៊ីលីធីរយៈពេលខ្លី (តិចជាងឬស្មើមួយឆ្នាំ):		
ធម្មតា	ពី 0 ទៅ 14 ថ្ងៃ	1%
ហ្វាស៊ីលីធីរយៈពេលវែង (លើសពីមួយឆ្នាំ):		
ធម្មតា	ពី 0 ទៅ 30 ថ្ងៃ	1%
សំវិធានធនជាក់លាក់		
ហ្វាស៊ីលីធីរយៈពេលខ្លី (តិចជាងឬស្មើមួយឆ្នាំ):		
- ឃ្លាំមើល	ពី 15 ទៅ 30 ថ្ងៃ	3%
- ក្រោមស្តង់ដា	ពី 31 ទៅ 60 ថ្ងៃ	20%
- សង្ស័យ	ពី 61 ទៅ 90 ថ្ងៃ	50%
- បាត់បង់	ពី 91 ថ្ងៃឡើងទៅ	100%
ហ្វាស៊ីលីធីរយៈពេល វែង (លើស ពីមួយឆ្នាំ):		
ឃ្លាំមើល	ពី 30 ទៅ 89 ថ្ងៃ	3%
ក្រោមស្តង់ដា	ពី 90 ទៅ 179 ថ្ងៃ	20%
សង្ស័យ	ពី 180 ទៅ 359 ថ្ងៃ	50%
បាត់បង់	ពី 360 ថ្ងៃឡើងទៅ	100%

៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

៤.១០ សំវិធានធន (ត)

ចំពោះហ្វាស៊ីលីធីដែលមានការទូទាត់សងប្រចាំត្រីមាស ប្រចាំឆមាសឬយូរជាងនេះ នឹងត្រូវបានចាត់ថ្នាក់ថា ក្រោមស្តង់ដា ប្រសិនបើមានការខកខានទូទាត់សងចាប់ពី 5 ថ្ងៃនៃថ្ងៃធ្វើការ។

៤.១១ ការប្រាក់

អត្រាការប្រាក់ប្រកបដោយប្រសិទ្ធភាព (EIR)

ចំណូលនិងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាតដោយប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រកបដោយប្រសិទ្ធភាព។ អត្រាការប្រាក់ប្រកបដោយប្រសិទ្ធភាព ឬ EIR គឺជាអត្រាដែលមានការបញ្ចុះតម្លៃយ៉ាងពិតប្រាកដនូវការប៉ាន់ប្រមាណលំហូរសាច់ប្រាក់នាពេលអនាគត តាមរយៈអាយុកាលដែលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុទៅ៖

- តម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- តម្លៃចំណាយដករំលស់នៃបំណុលហិរញ្ញវត្ថុ។

នៅពេលគណនា EIR សម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ធនាគារបានធ្វើការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនមែនការបាត់បង់ឥណទានដែលរំពឹងទុកទេ (ECL) ។

ការគណនានៃ EIR រួមបញ្ចូលទាំងថ្លៃឈ្នួលទាំងអស់ដែលបានបង់ឬទទួលបានរវាងភាគីនៃកិច្ចសន្យាដែលជាផ្នែកសំខាន់នៃ EIR និងថ្លៃប្រតិបត្តិការ។ ថ្លៃដើមប្រតិបត្តិការរួមមានការចំណាយបន្ថែមដែលត្រូវបានបង្កឡើងដោយផ្ទាល់ទាក់ទងទៅនឹងការទិញឬបោះផ្សាយនៃទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ។

តម្លៃដករំលស់ និង តម្លៃយោងដុល

តម្លៃដករំលស់នៃទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុគឺជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងលើការទទួលស្គាល់លើកដំបូង ដកការទូទាត់ថ្លៃដើម បូក ឬដក ការរំលោះតគ្នាដោយប្រើវិធីសាស្ត្រការប្រាក់ប្រកបដោយប្រសិទ្ធភាពនៃភាពខុសគ្នាណាមួយរវាងសមតុល្យដើម និងចំនួនទឹកប្រាក់កំណត់ហើយសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែតម្រូវសម្រាប់ការបាត់បង់ឥណទានដែលរំពឹងទុកទេ។

តម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុគឺជា តម្លៃដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុមុនពេលធ្វើការកែតម្រូវសម្រាប់ការបាត់បង់ឥណទានដែលរំពឹងទុកទេ។

ការគណនាចំណូលនិងចំណាយការប្រាក់

EIRនៃទ្រព្យសកម្មឬបំណុលហិរញ្ញវត្ថុត្រូវបានគណនាលើការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុ។ ក្នុងការគណនាចំណូលនិងចំណាយការប្រាក់ EIR ត្រូវបានអនុវត្តទៅលើតម្លៃយោងដុលនៃទ្រព្យសកម្មមុនពេលធ្វើការកែសម្រួលលើសំវិធានធនការខាតបង់ឥណទានដែលរំពឹងទុកឬទៅលើតម្លៃដករំលស់នៃបំណុល។ EIR ត្រូវបានកែតម្រូវដែលជាលទ្ធផលនៃការប៉ាន់ប្រមាណឡើងវិញតាមកាលកំណត់នៃលំហូរសាច់ប្រាក់ដោយប្រើអត្រាប្រែប្រួល ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរអត្រាការប្រាក់លើទីផ្សារ។

ចំពោះ ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពឥណទាន បន្ទាប់ពីការទទួលស្គាល់ដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយអនុវត្ត EIR ទៅនឹងតម្លៃដករំលោះនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានឱនភាពឥណទាន។ ប្រសិនបើទ្រព្យនោះលែងមានឱនភាពឥណទានបន្ទាប់មកការគណនាចំណូលការប្រាក់នឹងត្រលប់ទៅមូលដ្ឋានដុលវិញ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពឥណទាននៅពេលទទួលស្គាល់ដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយអនុវត្តឥណទានកែតម្រូវ EIR ទៅនឹងតម្លៃដករំលោះនៃទ្រព្យសកម្ម។ ការគណនានៃ ចំណូលការប្រាក់មិនត្រលប់ទៅមូលដ្ឋានដុលវិញនោះទេទោះបីហានិភ័យឥណទាននៃទ្រព្យសកម្មនោះត្រូវបានកើនឡើង។

ការបង្ហាញ

ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ដែលមានប្រសិទ្ធិភាព ដែលបានបង្ហាញក្នុងប្រាក់ចំណេញឬខាត រួមមានការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងដោយតម្លៃដក រំលស់។
ចំណាយការប្រាក់ដែលបានបង្ហាញក្នុងប្រាក់ចំណេញឬខាត រួមមានបំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងដោយតម្លៃដករំលស់។

៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

៤.១២ កម្រៃជើងសារ

ចំណូល និងចំណាយកម្រៃជើងសារ រួមមានកម្រៃទាំងឡាយណាដែលមិនមែនជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព (សូមមើលកំណត់សម្គាល់លេខ 4.1)។

ចំណូលកម្រៃជើងសារផ្សេងៗទៀត រួមមានកម្រៃណែនាំ កម្រៃសេវាផ្ទេរប្រាក់ កម្រៃសេវា និងកម្រៃសេវាលើគណនីប្រាក់បញ្ញើ កម្រៃជើងសារលើឥណទានផ្តល់អតិថិជនផ្សេងៗទៀត និងកម្រៃផ្សេងៗទៀត ត្រូវទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម។

ចំណាយកម្រៃជើងសារផ្សេងៗទៀត ពាក់ព័ន្ធនឹងប្រតិបត្តិការ និងកម្រៃសេវា នឹងត្រូវទទួលស្គាល់ជាចំណាយនៅពេល បានទទួលសេវាកម្ម។

៤.១៣ អត្ថប្រយោជន៍និយោជិត

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លីត្រូវបានគិតជាចំណាយ នៅពេលដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ជូន។ បំណុលត្រូវទទួលស្គាល់តាម ចំនួនដែលរំពឹងថាត្រូវបង់ ប្រសិនបើធនាគារ មានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬដោយ ប្រយោល ដើម្បីទូទាត់នូវបំណុលនោះ ដោយសារតែសេវាកម្មផ្តល់ដោយនិយោជិតពីអតីតកាល ហើយកាតព្វកិច្ចនោះ ត្រូវបានប៉ានស្មានដែលអាចជឿជាក់បាន។

៤.១៤ ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ រួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ វាត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬខាតលើកលែងតែទំហំដែលវាទាក់ទងទៅនឹងវត្ថុដែលត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងភាគហ៊ុនឬនៅក្នុងOCI។

ធនាគារបានកំណត់ថា ការប្រាក់និងប្រាក់ពិន័យដែលទាក់ទងនឹងពន្ធលើប្រាក់ចំណេញ រួមទាំងពន្ធដែល មិនទាន់ដឹងច្បាស់លាស់ គឺ មិនមែនជាពន្ធ លើប្រាក់ចំណេញទេ ដូច្នេះវាត្រូវទទួលស្គាល់តាមស្តង់ដា CIAS 37 ស្តីពី សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ និងត្រូវទទួលស្គាល់ជាចំណាយនៅក្នុង " ចំណាយផ្សេងៗ" ។

ពន្ធប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថាត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើ អត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តមួយភាគធំនៅកាលបរិច្ឆេទតារាងតុល្យការ និងនិយ័តភាពទាំងឡាយទៅលើ ពន្ធត្រូវបង់ពីឆ្នាំមុនៗ។

ពន្ធពន្យារ

ពន្ធពន្យារ ត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ នឹងតម្លៃយោងសម្រាប់ការគិតពន្ធ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវទទួលស្គាល់ចំពោះឥណទានពន្ធដែលមិនទាន់បានប្រើ និងភាពលម្អៀង បណ្តោះអាសន្នដែលអាចកាត់កងបាន ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត អាចប្រើប្រាស់សម្រាប់កាត់កង ជាមួយភាពលម្អៀងបណ្តោះអាសន្ននោះបាន។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណី មិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវវាស់វែង តាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះ អាសន្ននៅពេលដែលវាអាចប្រើប្រាស់បាន ឬកាត់កងបាន ដោយប្រើអត្រាពន្ធនៅកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងពន្ធពន្យារជាទ្រព្យសកម្ម ឆ្លុះបញ្ចាំងនូវពន្ធដែល ធនាគាររំពឹងថាអាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលនៅកាលបរិច្ឆេទរាយការណ៍។

ពន្ធពន្យារជាទ្រព្យសកម្ម និងពន្ធពន្យារជាបំណុលអាចកាត់កងបាន នៅពេលដែលលក្ខណៈវិនិច្ឆ័យជាក់លាក់ត្រូវបានបំពេញ។

៥. ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ និងប្រភពសំខាន់ៗនៃការប៉ាន់ស្មានភាពមិនប្រាកដ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឱ្យអ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត ដែលមាន ផលប៉ះពាល់ដល់ការអនុវត្តនូវ គោលនយោបាយគណនេយ្យ និងចំនួនទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែទៅលើការប៉ាន់ស្មាន គណនេយ្យ ត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងគ្រាដែលការប៉ាន់ស្មាននោះត្រូវបានកែប្រែ និងការិយបរិច្ឆេទ អនាគតដែលប៉ះពាល់ដោយការកែប្រែនេះ។

៥.១ ការវិនិច្ឆ័យសំខាន់ៗក្នុងការអនុវត្តគោលការណ៍គណនេយ្យ

ព័ត៌មានអំពីការវិនិច្ឆ័យក្នុងការអនុវត្តគោលនយោបាយគណនេយ្យ ដែលមានការប៉ះពាល់ជាសារវន្ត លើចំនួន ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

ការវាយតម្លៃម៉ូឌែលអាជីវកម្ម

ការចាត់ថ្នាក់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ អាស្រ័យលើលទ្ធផលនៃការពិសោធន៍ SPPI និងម៉ូឌែល អាជីវកម្ម (សូមមើលកំណត់សម្គាល់លេខ 4.6)។

ធនាគារធ្វើការកំណត់ម៉ូឌែលអាជីវកម្មនៅកម្រិតមួយ ដែលអាចឆ្លុះ បញ្ចាំងពីវិធីសាស្ត្រក្នុងការគ្រប់គ្រងក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ដើម្បីសម្រេចបាននូវគោលដៅ អាជីវកម្មជាក់លាក់មួយ។ ការវាយតម្លៃនេះ រួមមាន ការវិនិច្ឆ័យ ដែលឆ្លុះបញ្ចាំងនូវរាល់ភស្តុតាងពាក់ព័ន្ធទាំងអស់ រួមទាំង វិធីវាយតម្លៃនិងវាស់វែង លទ្ធផលរបស់ទ្រព្យសកម្ម ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលរបស់ទ្រព្យសកម្មនិងវិធីគ្រប់គ្រងហានិភ័យទាំងនេះ និងវិធីសាស្ត្រតបស្នងអ្នកគ្រប់គ្រងទ្រព្យសកម្មនេះ។ ធនាគារធ្វើការតាមដានរាល់ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃដករំលស់ ដែលត្រូវបានឈប់ទទួលស្គាល់មុន កាលវសានរបស់វាដើម្បីស្វែងយល់ពីមូលហេតុក្នុងការបោះបង់ចោល និងថាតើមូលហេតុទាំងនោះ ស្របតាមគោលដៅអាជីវកម្មក្នុងការរក្សាទ្រព្យសកម្មដែរ ឬទេ។ ការតាមដាននេះ គឺជាផ្នែកនៃការវាយតម្លៃជាបន្តបន្ទាប់របស់ធនាគារថាតើម៉ូឌែលអាជីវកម្មក្នុងការរក្សាទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះ នៅបន្តសមប្រកបដែរ ឬទេ ហើយប្រសិនបើវាមិនសមប្រកបទេ ថាតើមានការផ្លាស់ប្តូរណាមួយនៅក្នុងម៉ូឌែលអាជីវកម្មដែរឬអត់ ហើយប្រសិនមាន ត្រូវធ្វើការផ្លាស់ប្តូរចំណាត់ថ្នាក់ទ្រព្យសកម្មទាំងនោះចាប់ពីពេលផ្លាស់ប្តូរម៉ូឌែលអាជីវកម្ម។

ការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន

ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ 36.1.4 ការខាតបង់ឥណទានដែលរំពឹងទុក (ECL) ត្រូវវាស់វែង ជា សំវិធានធនស្មើនឹង ១២ខែ ចំពោះទ្រព្យសកម្មដែលស្ថិតក្នុងចំណាត់ថ្នាក់ទី១ និងសំវិធានធនស្មើនឹងអាយុកាលរបស់ ទ្រព្យសកម្មចំពោះទ្រព្យសកម្មដែលស្ថិតក្នុងចំណាត់ថ្នាក់ទី2 និងទី3។ ទ្រព្យសកម្មមួយ ត្រូវប្តូរទៅស្ថិតនៅក្នុង ចំណាត់ថ្នាក់ទី២ នៅពេលដែលហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះមានការកើនឡើងជាសារវន្ត ចាប់តាំងពីពេលទទួលស្គាល់ជាលើកដំបូង។ ដើម្បីវាយតម្លៃថាតើ ហានិភ័យឥណទានរបស់ទ្រព្យសកម្ម។ សូមមើលកំណត់សំគាល់ 38 សំរាប់ពត៌មានលំអិត។

ការបង្កើតក្រុមទ្រព្យសកម្មដែលមានចរិតលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា

នៅពេលដែល ការខាតបង់ឥណទានដែលរំពឹងទុក ត្រូវវាស់វែងតាមមូលដ្ឋានជាក្រុម ឧបករណ៍ហិរញ្ញវត្ថុត្រូវបានប្រមូលផ្តុំតាមមូលដ្ឋានចរិតលក្ខណៈហានិភ័យ។ ធនាគារធ្វើការតាមដានភាពសមស្របនៃចរិតលក្ខណៈហានិភ័យឥណទាន ដោយផ្អែកលើមូលដ្ឋាននិន្នាការ ដើម្បីវាយតម្លៃថាតើហានិភ័យទាំងនោះ នៅតែបន្តលក្ខណៈ ស្រដៀងគ្នាទៀតដែរឬទេ។ កិច្ចការនេះ ត្រូវធ្វើដើម្បីធានាថា ប្រសិនបើចរិតលក្ខណៈហានិភ័យ ឥណទានមានការ ផ្លាស់ប្តូរ គឺត្រូវធ្វើការប្រមូលផ្តុំទ្រព្យសកម្មឱ្យបានសមស្របឡើងវិញ។ ការប្រមូលផ្តុំឡើងវិញនេះ អាចនាំឱ្យមាននូវ ការបង្កើតក្រុមទ្រព្យសកម្មថ្មី ឬក៏ទ្រព្យសកម្មត្រូវប្តូរទៅក្រុមទ្រព្យសកម្មដែលមានស្រាប់ផ្សេងទៀត ដែលអាចឆ្លុះ បញ្ចាំងនូវចរិតលក្ខណៈហានិភ័យឥណទានស្រដៀងគ្នាទៅនឹងក្រុមទ្រព្យសកម្មនោះ។ ការប្រមូលផ្តុំទ្រព្យសកម្មឡើងវិញ និងការប្តូរពីក្រុម ទ្រព្យសកម្មមួយទៅក្រុមទ្រព្យសកម្មមួយទៀតគឺជារឿង ធម្មតា នៅពេលមានការកើនឡើងជាសារវន្តនូវ ហានិភ័យឥណទាន (ឬក៏នៅពេលការកើនឡើងជាសារវន្តនោះ មានភាពបញ្រ្ចាសមកវិញ) ដូច្នេះទ្រព្យសកម្ម ត្រូវប្តូរពីទ្រព្យសកម្មដែលត្រូវធ្វើសំវិធានធនស្មើ១២ខែ ទៅជាទ្រព្យសកម្មដែលត្រូវធ្វើសំវិធានធនស្មើនឹង អាយុកាលរបស់ទ្រព្យសកម្មនោះ ឬក៏បញ្រ្ចាសមកវិញ ប៉ុន្តែវាក៏អាចកើតឡើងផងដែរ ចំពោះក្រុមទ្រព្យសកម្ម ដែលនៅតែបន្តវាស់វែងតាមមូលដ្ឋានសំវិធានធនស្មើ ១២ខែ ឬសំវិធានធនស្មើនឹងអាយុកាលរបស់ក្រុមទ្រព្យសកម្មនោះ គ្រាន់តែចំនួនសំវិធានធនត្រូវផ្លាស់ប្តូរដោយសារហានិភ័យឥណទានរបស់ក្រុមទ្រព្យសកម្មនោះ មានការប្រែប្រួល។

៥. ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ និងប្រភពសំខាន់ៗនៃការប៉ាន់ស្មានភាពមិនប្រាកដ

៥.១ ការវិនិច្ឆ័យសំខាន់ៗក្នុងការអនុវត្តគោលការណ៍គណនេយ្យ

ម៉ូឌែល និងការសន្មតដែលបានប្រើ

ធនាគារប្រើម៉ូឌែល និងការសន្មតផ្សេងៗ ដើម្បីវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ព្រមទាំង ការប៉ាន់ស្មាននូវ ការខាតបង់ឥណទានដែលរំពឹងទុក។ ត្រូវប្រើការវិនិច្ឆ័យ ដើម្បីកំណត់ម៉ូឌែល ដែលសាកសមបំផុត សម្រាប់ប្រភេទទ្រព្យសកម្មនីមួយៗ និងដើម្បីកំណត់នូវការសន្មតដែលត្រូវប្រើក្នុងម៉ូឌែលទាំងនេះ រួមទាំងការសន្មត ពាក់ព័ន្ធនឹងចលករសំខាន់ៗរបស់ហានិភ័យ។

ព័ត៌មានអំពីការសន្មតសំខាន់ៗ និង ការប៉ាន់ស្មានភាពមិនប្រាកដ ដែលមានការប៉ះពាល់ លើចំនួនជាសារវន្ត ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

ការបង្កើតចំនួននិងការថ្លឹងថ្លែងស្ថានភាពដែលទាក់ទង នៃទិដ្ឋភាពដែលរំពឹងទុកទៅថ្ងៃខាងមុខសម្រាប់ប្រភេទផលិតផលនីមួយៗ និងកំណត់ព័ត៌មានដែលរំពឹងទុកទៅថ្ងៃខាងមុខទាក់ទងនឹងទិដ្ឋភាពនីមួយៗ៖

នៅពេលវាស់វែង ការខាតបង់ឥណទានដែលរំពឹងទុក ធនាគារប្រើប្រាស់នូវព័ត៌មានដែលរំពឹងទុកទៅថ្ងៃ ខាងមុខ ដែលមានលក្ខណៈអាចទ្រទ្រង់បាន និងសមហេតុផល ដោយផ្អែកលើការសន្មតចំពោះការផ្លាស់ប្តូរ នាពេលអនាគតនូវចលករសេដ្ឋកិច្ចផ្សេងៗគ្នា និងរបៀបដែលចលករទាំងនេះមានការប៉ះពាល់គ្នាទៅវិញទៅ មក។

ភាពដែលអាចខកខានក្នុងការសង (PD)

ភាពដែលអាចខកខានក្នុងការសង គឺជាធាតុចូលដ៏សំខាន់ក្នុងការវាស់វែងការខាតបង់ឥណទានដែលរំពឹង ទុក។ ភាពដែលអាច ខកខានក្នុងការសង គឺជាការប៉ាន់ស្មាននូវ ភាពប្រហាក់ប្រហែលក្នុងការខកខានសងក្នុងរយៈពេលណា មួយ ដែលការគណនារបស់វា ត្រូវការនូវទិន្នន័យពីមុនៗ ការសន្មត និងការរំពឹងទុកនូវលក្ខខណ្ឌនាពេលអនាគត។

ការខាតបង់ដោយសារខកខានក្នុងការសង (LGD)

ការខាតបង់ដោយសារខកខានក្នុងការសង គឺជាការប៉ាន់ស្មាននូវការខាតបង់កើតចេញមកពីការខកខានក្នុងការបង់សង។ វាផ្អែកទៅលើភាពខុសគ្នារវាង លំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលដល់កាលកំណត់ត្រូវបង់សង និងលំហូរសាច់ប្រាក់ដែលម្ចាស់កម្ចីរំពឹងថានឹងទទួលបាន ដោយគិតទាំងលំហូរសាច់ប្រាក់ពីទ្រព្យដាក់ធានា និងការធ្វើឱ្យប្រសើរឡើងនូវឥណទានទាំងមូល។

ពន្ធ

ប្រព័ន្ធពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈច្រើនប្រភេទ និងបញ្ញត្តិមានការផ្លាស់ប្តូរញឹកញាប់ ដែលជាទូទៅមានភាពមិនច្បាស់លាស់ មានភាពផ្ទុយគ្នា និងអាស្រ័យទៅលើការបកស្រាយ។ ជាទូទៅ យុត្តាធិការ និងអាជ្ញាធរពន្ធភាគច្រើន តែងតែមានការបកស្រាយផ្សេងៗពីគ្នា។ ពន្ធ គឺត្រូវស្ថិតក្រោមការ ត្រួតពិនិត្យ និងការអង្កេតដោយអាជ្ញាធរ ដែលបានផ្តល់សិទ្ធិដោយច្បាប់ក្នុងការដាក់ពិន័យ ដាក់ទណ្ឌកម្ម និងបង់ការប្រាក់។

បញ្ហាទាំងនេះអាចបង្កើតឱ្យមានហានិភ័យពន្ធយ៉ាងខ្លាំងសម្រាប់ធនាគារ។ អ្នកគ្រប់គ្រងជឿជាក់ថា ពួកគេ មានការយល់ដឹងពីបទប្បញ្ញត្តិពន្ធដែលពាក់ព័ន្ធ និងបានធ្វើសំវិធានធន ដែលមានលក្ខណៈគ្រប់គ្រាន់ដោយផ្អែកទៅ លើការបកស្រាយនៃនីតិកម្មពន្ធ។ ក៏ប៉ុន្តែអាជ្ញាធរជាប់ពាក់ព័ន្ធ អាចនឹងមានបំណកស្រាយខុសគ្នា ហើយផលប៉ះពាល់ អាចមានទំហំធំ។

៦. សាច់ប្រាក់ក្នុងដៃ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សាច់ប្រាក់ក្នុងដៃ	2,769,561	11,285,961	2,506,613	10,071,571	97,295	392,780
សាច់ប្រាក់ក្នុង ATM	74,810	304,851	1,660	6,670	-	-
	2,844,371	11,590,812	2,508,273	10,078,241	97,295	392,780

៧. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់បញ្ញើតាមច្បាប់:						
ប្រាក់ធានាលើដើមទុន	3,000,880	12,228,586	236,657	950,888	-	-
ប្រាក់បម្រុងកាតព្វកិច្ច	7,520,417	30,645,699	7,523,441	30,229,186	7,507,970	30,309,675
	10,521,297	42,874,285	7,760,098	31,180,074	7,507,970	30,309,675
គណនីចរន្ត	8,523,729	34,734,196	6,434,336	25,853,162	32,593,504	131,579,976
មូលបត្រអាចជួញដូរបាន	-	-	100,000	401,800	-	-
	19,045,026	77,608,481	14,294,434	57,435,036	40,101,474	161,889,651

៨. សមតុល្យនៅធនាគារផ្សេងៗ

សមតុល្យនៅធនាគារផ្សេងៗត្រូវបានវាស់វែងតាមតម្លៃដករំលស់ ដោយសារតែឧបករណ៍ទាំងនេះ បានបំពេញលក្ខខណ្ឌ SPPIនិងត្រូវបានរក្សាទុកដើម្បីប្រមូលសាច់ប្រាក់តាមកិច្ចសន្យា។

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សមតុល្យនៅធនាគារផ្សេងៗដែលវាស់វែងតាមតម្លៃដករំលស់	621,386	2,532,148	15,723,458	63,176,854	125,234	505,570
សំវិធានធនលើការខាតបង់ពីការធ្លាក់ចុះតម្លៃ	(12,801)	(52,164)	(321,231)	(1,290,706)	-	-
	608,585	2,479,984	15,402,227	61,886,148	125,234	505,570

សមតុល្យនៅធនាគារផ្សេងៗត្រូវបានធ្វើការវិភាគដូចខាងក្រោម៖

៨. សមតុល្យនៅធនាគារផ្សេងៗ (ត)

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	តម្លៃយោងដុល	សំវិធានធន ECL	តម្លៃយោង	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
គណនីចរន្ត	621,275	(12,798)	608,477	2,479,543
គណនីសន្សំ	111	(2)	109	441
	621,386	(12,801)	608,585	2,479,984

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

	តម្លៃយោងដុល	សំវិធានធន ECL	តម្លៃយោង	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
គណនីចរន្ត	94,873	(1,954)	92,919	373,347
គណនីសន្សំ	615	(13)	602	2,420
គណនីមានកាលកំណត់	15,627,970	(319,264)	15,308,706	61,510,381
	15,723,458	(321,231)	15,402,227	61,886,148

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017

	តម្លៃយោងដុល	សំវិធានធន ECL	តម្លៃយោង	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
គណនីចរន្ត	125,234	-	125,234	505,570

៩. ឥណទានផ្តល់ដល់អតិថិជន

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ឥណទានផ្តល់ដល់អតិថិជនវាស់វែង តាមតម្លៃដករំលស់	77,745,930	316,814,665	44,011,704	176,839,026	33,948,838	137,051,459
សំវិធានធនលើការខាតបង់ពីការធ្លាក់ចុះតម្លៃ	(890)	(3,627)	(510)	(2,049)	(340,755)	(1,375,628)
	77,745,040	316,811,038	44,011,194	176,836,977	33,608,083	135,675,831

ឥណទានផ្តល់ដល់អតិថិជនត្រូវបានវិភាគដូចខាងក្រោម៖

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	តម្លៃយោងដុល	សំវិធានធន ECL	តម្លៃយោង	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
ឥណទានឯកត្តជន	76,867,540	(890)	76,866,650	313,231,599
ឥណទានឲ្យក្រុមហ៊ុន	878,390	-	878,390	3,579,439
	77,745,930	(890)	77,745,040	316,811,038

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

	តម្លៃយោងដុល	សំវិធានធន ECL	តម្លៃយោង	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
ឥណទានឯកត្តជន	44,011,704	(510)	44,011,194	176,836,977
ឥណទានឲ្យក្រុមហ៊ុន	-	-	-	-
	44,011,704	(510)	44,011,194	176,836,977

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017

	តម្លៃយោងដុល	សំវិធានធន ECL	តម្លៃយោង	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
ឥណទានឯកត្តជន	31,321,833	(315,977)	31,005,856	125,170,641
ឥណទានឲ្យក្រុមហ៊ុន	2,627,005	(24,778)	2,602,227	10,505,190
	33,948,838	(340,755)	33,608,083	135,675,831

៩. ឥណទានផ្តល់ដល់អតិថិជន (ត)

បម្រែបម្រួលនៃសំវិធានធនលើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន និងបុរេប្រទានមានដូចខាងក្រោម៖

	2019		2018	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ដំណាក់កាលទី 1 សំវិធានធន				
នាថ្ងៃទី 1 ខែ មករា	510	2,049	340,755	1,375,628
ផលប៉ះពាល់នៃការវាស់វែងសារជាថ្មីរបស់ CIFRS 9	-	-	(280,763)	(1,128,104)
នាថ្ងៃទី 1 ខែ មករា ក្រោយផលប៉ះពាល់នៃការវាស់វែងសារជាថ្មីរបស់ CIFRS 9	510	2,049	59,992	247,524
សំវិធានធនលើការខាតបង់ឱនភាពនៅក្នុងកំឡុងឆ្នាំ	380	1,540	(59,482)	(240,606)
លម្អៀងនៃការប្តូររូបិយប័ណ្ណ	-	38	-	(4,869)
នាថ្ងៃទី 31 ខែ ធ្នូ	890	3,627	510	2,049

១០. ទ្រព្យសកម្មផ្សេងៗ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សម្ភារៈការិយាល័យ	71,659	292,010	72,418	290,976	-	-
ប្រាក់បញ្ញើ / បុរេប្រទានទុកមុន	154,753	630,618	527,538	2,119,648	24,127	97,401
គណនីត្រូវទទួលផ្សេងៗ	19,961	81,341	1,232	4,950	-	-
ប្រាក់បង់មុន	170,157	693,391	89,915	361,278	36,435	147,088
ផ្សេងៗ	-	-	4,430	17,800	74,465	300,615
	416,530	1,697,360	695,533	2,794,652	135,027	545,104

១១. ទ្រព្យសម្បត្ត និងបរិក្ខារ

	អាគារ	ការជួសជុលកែលម្អ	យានយន្ត	បរិក្ខារកុំព្យូទ័រ	គ្រឿងបរិក្ខារ	សម្ភារៈការិយាល័យ	ទ្រព្យសម្បត្តិនិងបរិក្ខារកំពុងសាងសង់	សរុប	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
តម្លៃដើម									
ថ្ងៃទី1 ខែ មករា ឆ្នាំ 2019	-	1,043,116	254,011	461,921	20,289	1,071	330,000	2,110,408	8,479,619
ការទិញបន្ថែម	-	490,054	118,180	144,848	342,223	47,180	550,000	1,692,485	6,857,950
ការលក់ចេញ	-	(270,130)	(55,766)	-	-	-	-	(325,896)	(1,320,531)
ការផ្ទេរ	880,000		-	-	-	-	(880,000)	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	-	151,725
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	880,000	1,263,040	316,425	606,769	362,512	48,251	-	3,476,997	14,168,763
ដកៈ រំលស់បង្គរ									
ថ្ងៃទី1 ខែ មករា ឆ្នាំ 2019	-	429,224	122,889	203,969	13,251	70	-	769,403	3,091,461
រំលស់	25,781	241,288	57,567	103,491	35,573	5,407	-	469,107	1,900,825
ការលក់ចេញ	-	(229,031)	(47,599)	-	-	-	-	(276,630)	(1,120,917)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	-	48,280
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	25,781	441,481	132,855	307,460	48,824	5,477	-	961,880	3,919,661
តម្លៃយោង									
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	854,219	821,559	183,568	299,308	313,688	42,774	-	2,515,117	10,249,102

១១. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

	អាគារ	ការជួសជុលកែលម្អ	យានយន្ត	បរិក្ខារកុំព្យូទ័រ	គ្រឿងបរិក្ខារ	សម្ភារៈការិយាល័យ	ទ្រព្យសម្បត្តិនិងបរិក្ខារកំពុងសាងសង់	សរុប	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
តម្លៃដើម									
ថ្ងៃទី1 ខែ មករា ឆ្នាំ 2018	-	1,022,968	243,841	409,669	18,575	-	-	1,695,053	6,842,929
ការទិញបន្ថែម	-	20,148	10,170	52,252	2,785	-	330,000	415,355	1,680,111
ការលក់ចេញ	-	-	-	-	-	-	-	-	-
ការផ្ទេរ	-	-	-	-	(1,071)	1,071	-	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	-	(43,421)
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	-	1,043,116	254,011	461,921	20,289	1,071	330,000	2,110,408	8,479,619
ដកៈ រំលស់បង្គរ	-								
ថ្ងៃទី1 ខែ មករា ឆ្នាំ 2018	-	224,066	73,681	114,542	9,635	-	-	421,924	1,703,307
រំលស់	-	205,158	49,208	89,427	3,686	-	-	347,479	1,405,553
ការលក់ចេញ	-	-	-	-	-	-	-	-	-
ការផ្ទេរ	-	-	-	-	(70)	70	-	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	-	(17,398)
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		429,224	122,889	203,969	13,251	70	-	769,403	3,091,461
តម្លៃយោង									
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	-	613,892	131,122	257,952	7,038	1,001	330,000	1,341,005	5,388,158

១១. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

	អាគារ	ការជួសជុលកែលម្អ	យានយន្ត	បរិក្ខារកុំព្យូទ័រ	គ្រឿងបរិក្ខារ	សម្ភារៈការិយាល័យ	ទ្រព្យសម្បត្តិ និងបរិក្ខារកំពុងសាងសង់	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
តម្លៃដើម									
ថ្ងៃទី1 ខែ មករា ឆ្នាំ 2017	-	394,090	105,841	172,791	35,480	-	303,600	1,011,802	4,084,645
ការទិញបន្ថែម	-	2,339	138,000	236,878	4,900	-	450,176	832,293	3,366,625
ការលក់ចេញ	-	(127,237)	-	-	(21,805)	-	-	(149,042)	(602,875)
ការផ្ទេរ	-	753,776	-	-	-	-	(753,776)	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	-	(5,466)
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	-	1,022,968	243,841	409,669	18,575	-	-	1,695,053	6,842,929
ដក: រំលស់បង្គរ									
ថ្ងៃទី1 ខែ មករា ឆ្នាំ 2017	-	160,080	31,903	58,609	19,630	-	-	270,222	1,090,886
រំលស់	-	147,959	41,778	55,933	4,456	-	-	250,126	1,011,760
ការលក់ចេញ	-	(83,973)	-	-	(14,451)	-	-	(98,424)	(398,125)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	-	(1,214)
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	-	224,066	73,681	114,542	9,635	-	-	421,924	1,703,307
តម្លៃយោង									
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	-	798,902	170,160	295,127	8,940	-	-	1,273,129	5,139,622

១២. សិទ្ធិក្នុងការប្រើទ្រព្យសកម្ម

ធនាគារមានកិច្ចសន្យាលើការជួលការិយាល័យដែលមានទីស្នាក់ការកណ្តាល និង ការិយាល័យសាខា។

ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	សរុប	
	ដុល្លារអាមេរិក	ពាន់រៀល
តម្លៃដើម		
ថ្ងៃទី1 ខែ មករា ឆ្នាំ 2019	1,954,131	7,851,698
ការទិញបន្ថែម	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	111,385
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	1,954,131	7,963,084
ដក: រំលស់បង្គរ		
ថ្ងៃទី 1 ខែ មករា ឆ្នាំ 2019	-	-
រំលស់	350,351	1,419,622
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	8,058
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	350,351	1,427,680
តម្លៃយោង		
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	1,603,780	6,535,404

១៣. ទ្រព្យសកម្មអរូបី

ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	សូហ្វវែរ និងអាជ្ញាប័ណ្ណ	ការងារកំពុងដំណើរការ	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
តម្លៃដើម				
ថ្ងៃទី1 ខែ មករា ឆ្នាំ 2019	151,858	266,645	418,502	1,681,541
ការទិញបន្ថែម	12,500	267,162	279,662	1,133,190
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	30,285
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	164,358	533,807	698,164	2,845,016
ដក: រំលស់បង្គរ				
ថ្ងៃទី 1 ខែ មករា ឆ្នាំ 2019	53,577	-	53,576	215,268
រំលស់	29,845	-	29,846	120,932
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	3,739
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	83,421	-	83,421	339,939
តម្លៃយោង				
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	80,937	533,807	614,743	2,505,077

ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

	សូហ្វវែរ និងអាជ្ញាប័ណ្ណ	ការងារកំពុងដំណើរការ	សរុប	
	US$	US$	ដុល្លារអាមេរិក	ពាន់រៀល
តម្លៃដើម				
ថ្ងៃទី1 ខែ មករា ឆ្នាំ 2018	151,858	266,645	418,502	1,689,493
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	(7,952)
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	151,858	266,645	418,502	1,681,541
ដក: រំលស់បង្គរ				
ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018	23,443	-	23,443	94,827
រំលស់	30,134	-	30,133	121,888
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	(1,447)
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	53,577	-	53,576	215,268
តម្លៃយោង				
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	98,281	266,645	364,926	1,466,273

១៣. ទ្រព្យសកម្មអរូបី (ត)

ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017

	សូហ្វវែរ និងអាជ្ញាប័ណ្ណ	ការងារកំពុងដំណើរការ	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
តម្លៃដើម				
ថ្ងៃទី1 ខែ មករា ឆ្នាំ 2017	20,386	159,987	180,373	728,166
ការទិញបន្ថែម	131,472	106,658	238,129	963,232
លម្អៀងពីការប្តូររូបិយប័ណ្ណ				(1,905)
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	151,858	266,645	418,502	1,689,493
ដកៈ រំលស់បង្គរ				
ថ្ងៃទី 1 ខែ មករា ឆ្នាំ 2017	10,074	-	10,074	40,669
រំលស់	13,369	-	13,369	54,078
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	-	-	-	81
At 31 December 2017	23,443	-	23,443	94,827
តម្លៃយោង				
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	128,415	266,645	395,059	1,594,853

១៤. ពន្ធលើប្រាក់ចំណេញ

(ក).បំណុលពន្ធលើប្រាក់ចំណេញក្នុងគ្រា

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សមតុល្យដើមឆ្នាំ	206,491	841,451	189,598	761,805	322,833	1,303,277
ចំណាយពន្ធលើប្រាក់ចំណេញ	364,824	1,478,267	240,517	972,893	217,486	879,731
ពន្ធលើប្រាក់ចំណេញដែលបានបង់	(263,986)	(1,075,741)	(223,624)	(898,521)	(350,721)	(1,415,861)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	8,389	-	(6,496)	-	(1,739)
សមតុល្យចុងឆ្នាំ	307,329	1,252,366	206,491	829,681	189,598	765,408

១៤. ពន្ធលើប្រាក់ចំណេញ (ត)

(ខ).បំណុលពន្ធលើប្រាក់ចំណេញក្នុងគ្រា

	ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ពន្ធលើប្រាក់ចំណេញក្នុងគ្រា	364,824	1,478,267	240,517	972,893	217,486	879,731
ពន្ធពន្យារ	(8,514)	(34,499)	(58,882)	(238,179)	12,545	50,744
ចំណេញពន្ធលើប្រាក់ចំណេញ	356,310	1,443,768	181,635	734,714	230,031	930,475

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញក្នុងគ្រា ដែលបានគណនាតាមអត្រាពន្ធ 20% ជាមួយចំណាយពន្ធលើប្រាក់ចំណេញដែលបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល មានដូចខាងក្រោម៖

	ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ	1,562,665	6,331,919	364,359	1,473,832	974,009	3,939,867
ពន្ធតាមអត្រា 20%	312,533	1,266,384	72,872	294,766	194,802	787,973
ផលប៉ះពាល់នៃ៖						
ចំណាយដែលមិនអាចកាត់កងតាមច្បាប់ពន្ធ	43,777	177,384	108,763	439,948	35,229	142,502
	356,310	1,443,768	181,635	734,714	230,031	930,475

យោងតាមច្បាប់ពន្ធដារកម្ពុជា ធនាគារមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ តាមចំនួនមួយណាដែលខ្ពស់ជាងគេ រវាងពន្ធលើប្រាក់ចំណេញតាមអត្រា 20% នៃប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមាតាមអត្រា 1% នៃប្រាក់ចំណូលដុល។

១៤. ពន្ធលើប្រាក់ចំណេញ (ត)

(គ).ទ្រព្យសកម្ម/(បំណុល)ពន្ធពន្យារ

បម្រែបម្រួលទ្រព្យសកម្មពន្ធពន្យារក្នុងអំឡុងឆ្នាំ មានដូចខាងក្រោម៖

	សំវិធានធន ឥណទាន	ទ្រព្យ និង បរិក្ខារ	សិទ្ធក្នុងការ ប្រើប្រាស់ ទ្រព្យសកម្ម	បំណុល ភតិសន្យា	សំវិធានធន នៃការស្តារ ឡើងវិញ	ចំណេញលើ ការប្តូរប្រាក់ ដែលមិនទាន់ ទទួលស្គាល់	កម្រៃរៀបចំ ឥណទានមិន ទាន់ទទួល ស្គាល់	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
នាថ្ងៃទី1 ខែ មករា ឆ្នាំ 2017	62,211	4,505	-	-	4,100	-	48,774	119,590
ការដកចេញពី/ (ដាក់បញ្ចូលក្នុង) របាយការណ៍លទ្ធផល	5,940	(19,456)	-	-	(4,100)	(1,312)	6,383	(12,545)
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	275,126	(60,357)	-	-	-	(5,297)	222,669	432,141
សមមូលជាពាន់រៀល								
នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018	68,151	(14,951)	-	-	-	(1,312)	55,157	107,045
ការដកចេញពី/ (ដាក់បញ្ចូលក្នុង) របាយការណ៍លទ្ធផល	(3,803)	29,544	-	-	-	(2,069)	35,210	58,882
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	64,348	14,593	-	-	-	(3,381)	90,367	165,927
សមមូលជាពាន់រៀល	258,551	58,635	-	-	-	(13,585)	363,095	666,695
នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2019	64,348	14,593	-	-	-	(3,381)	90,367	165,927
ការដកចេញពី/ (ដាក់បញ្ចូលក្នុង) របាយការណ៍លទ្ធផល	(61,610)	(16,116)	(320,756)	328,958	-	17,087	60,951	8,513
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	2,738	(1,523)	(320,756)	328,958	-	13,706	151,314	174,441
សមមូលជាពាន់រៀល	11,158	(6,208)	(1,307,081)	1,340,502	-	55,853	616,622	710,847

១៥. ប្រាក់បញ្ញើពីអតិថិជន

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
តាមតម្លៃដករំលស់៖						
ប្រាក់បញ្ញើចរន្ត	259,888	1,059,042	-	-	-	-
ប្រាក់បញ្ញើសន្សំ	2,241,413	9,133,760	1,671,433	6,715,818	-	-
ប្រាក់បញ្ញើតាមដំណាក់កាល	58,805	239,630	5,874	23,602	-	-
ប្រាក់បញ្ញើមានកាលកំណត់	23,659,989	96,414,455	758,400	3,047,251	-	-
	26,220,095	106,846,887	2,435,707	9,786,671	-	-

១៦. បំណុលភតសន្យា

ការវិភាគតាមកាលកំណត់:

	31 December 2019	
	ដុល្លារអាមេរិក	ពាន់រៀល
តិចជាង 1 ឆ្នាំ	406,668	1,657,172
ច្រើនជាង 1 ឆ្នាំ និងតិចជាង 5 ឆ្នាំ	1,088,337	4,434,973
ច្រើនជាង 5 ឆ្នាំ	430,000	1,752,250
	1,925,005	7,844,395
ដក៖ ការប្រាក់មិនទាន់ទទួលស្គាល់	(280,217)	(1,141,884)
	1,644,788	6,702,511

វិភាគជា

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	
	ដុល្លារអាមេរិក	ពាន់រៀល
រយៈពេលខ្លី	326,357	1,329,905
រយៈពេលវែង	1,318,431	5,372,606
	1,644,788	6,702,511

១៧. បំណុលផ្សេងៗ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ពន្ធត្រូវបង់ផ្សេងៗ	46,930	191,240	28,465	114,372	15,945	64,370
ចំណាយលើសេវាវិជ្ជាជីវៈ	-	-	-	-	19,892	80,304
ផ្សេងៗ	112,736	459,400	83,456	335,327	48,417	195,460
	159,666	650,640	111,921	449,699	84,254	340,133

១៨. ដើមទុន

ធនាគារគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលត្រូវបានកាន់កាប់ទាំងស្រុងដោយក្រុមហ៊ុន ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមច្បាប់នៃប្រទេស ដែលមានលេខចុះបញ្ជី 1771142 និងមានអាសយដ្ឋានចុះបញ្ជីនៅ Vickhams Cay II, Road Town, Tortola, VG1110, British Virgin Islands។

យោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ចុះថ្ងៃទី 4 ខែធ្នូ ឆ្នាំ 2017 ធនាគារបានបង្កើនដើមទុនរបស់ខ្លួនពី 38,800,000 ដុល្លារអាមេរិក ទៅ 75,000,000 ដុល្លារអាមេរិក ដើម្បីបំពេញតាមតម្រូវការមូលធនអប្បបរមារបស់ធនាគារពាណិជ្ជ នៅពេលដែលធនាគារមានបំណងបង្កើនអាជ្ញាប័ណ្ណរបស់ខ្លួនពីធនាគារឯកទេសទៅធនាគារពេញលេញ។

នៅថ្ងៃទី7 ខែមិថុនា ឆ្នាំ2018 ធនាគារជាតិបានអនុម័តឲ្យតំឡើងដើមទុនបន្ថែមចំនួន 36,200,000 ដុល្លារអាមេរិក ដែលធ្វើឲ្យដើមទុនចុះបញ្ជីត្រូវកើនដល់ 75,000,000 ដុល្លារអាមេរិក។ ដើមទុនចុះបញ្ជីថ្មីចំនួន75,000,000 ដុល្លារអាមេរិក ដែលមានភាគហ៊ុន ចំនួន 75,000,000 និងតម្លៃចារឹក 1 ដុល្លារអាមេរិកក្នុងមួយភាគហ៊ុនត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី 27 ខែ មិថុនា ឆ្នាំ 2018។

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019			ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018			ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017		
	ចំនួនភាគហ៊ុន	%	ដុល្លារអាមេរិក	ចំនួនភាគហ៊ុន	%	ដុល្លារអាមេរិក	ចំនួនភាគហ៊ុន	%	ដុល្លារអាមេរិក
Chief Financial Group (Cambodia) Limited	75,000,000	100	75,000,000	75,000,000	100	75,000,000	38,800,000	100	38,800,000

នៅឆ្នាំ 2017 ធនាគារផ្ទេរប្រតិបត្តិការមិនមែនសាច់ប្រាក់ចំនួន 7,800,000 ដុល្លារអាមេរិកពី ការបន្ថែមដើមទុន ទៅដើមទុន នៅពេលមានការកែប្រែក្នុងលក្ខន្តិកៈ ធនាគារ។

១៩. កំណត់សម្គាល់សម្រាប់របាយការណ៍លំហូរសាច់ប្រាក់

(ក) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សាច់ប្រាក់ក្នុងដៃ	2,844,371	11,590,812	2,508,273	10,078,241	97,294	392,780
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	11,545,026	47,045,981	6,794,434	27,300,036	32,593,505	131,579,975
សមតុល្យនៅធនាគារនានា	608,585	2,479,984	15,402,227	61,886,148	125,234	505,570
	14,997,982	61,116,777	24,704,934	99,264,425	32,816,033	132,478,325

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមបញ្ចូលនូវសាច់ប្រាក់សុទ្ធ និងប្រាក់បញ្ញើរយៈពេលខ្លីដែលមានកាលកំណត់ដើមបីខែ ឬតិចជាងនេះ។ តម្លៃយោងនៃទ្រព្យសកម្មទាំងនេះគឺប្រហាក់ប្រហែលនឹងតម្លៃសមស្រប។ សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងគ្រាដែលបានបង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់អាចផ្ទៀងផ្ទាត់នឹងសមតុល្យដែលបានបង្ហាញខាងលើ។

(ខ) ការប្រែប្រួលក្នុងបំណុលដែលកើតឡើងពីសកម្មភាពហិរញ្ញវត្ថុ

តារាងខាងក្រោមនេះបង្ហាញពត៌មានលំអិតពីការប្រែប្រួលនៃបំណុលដែលកើតពីសកម្មភាពហិរញ្ញវត្ថុរបស់ សម្ព័ន្ធក្រុមហ៊ុន និង ធនាគាររួមមានការប្រែប្រួលទាក់ទងនឹងសាច់ប្រាក់ និង មិនសាច់ប្រាក់។ បំណុលដែលកើតពីសកម្មភាពហិរញ្ញវត្ថុទាំងនោះមានលំហូរសាច់ប្រាក់ដែលធ្លាប់ ឬ លំហូរសាច់ប្រាក់នាពេលអនាគតដែលនឹងចាត់ថ្នាក់ចូលទៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់រួមរបស់ធនាគារជាលំហូរសាច់ប្រាក់ដែលកើតពីសកម្មភាពហិរញ្ញវត្ថុ។

	ថ្ងៃទី 1 ខែ មករា ឆ្នាំ 2019	ការសងប្រាក់	បម្រែបម្រួល មិនមែនសាច់ប្រាក់ ភតិសន្យាថ្មី	លម្អៀងនៃការប្តូររូបិយប័ណ្ណ	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019
បំណុលភតិសន្យា		(309,343)	1,954,131	-	1,644,788
សមមូលជាពាន់រៀល	-	(1,253,458)	7,918,139	37,830	6,702,511

២០. ចំណូលការប្រាក់សុទ្ធ

(ក) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

	ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណូលការប្រាក់						
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	48,362	195,963	40,635	164,369	14,127	57,144
សមតុល្យនៅធនាគារនានា	122,386	495,908	200,870	812,519		-
ឥណទានផ្តល់ដល់អតិថិជន	5,717,687	23,168,068	3,200,430	12,945,739	3,033,626	12,271,017
	5,888,435	23,859,939	3,441,935	13,922,627	3,047,753	12,328,161
ចំណាយការប្រាក់						
ប្រាក់បញ្ញើពីអតិថិជន	433,774	1,757,652	7,793	31,523	-	-
បំណុលភតិសន្យា	97,325	394,361	-	-	-	-
	531,099	2,152,013	7,793	31,523	-	-
ចំណូលការប្រាក់សុទ្ធ	5,357,336	21,707,926	3,434,142	13,891,104	3,047,753	12,328,161

ចំនួនដែលបានរាយការណ៍ខាងលើ គឺជា ចំណូលការប្រាក់ និងចំណាយការប្រាក់ដែលគណនាដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធិភាព ដែលមានទំនាក់ទំនងនឹងទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់វែងតាមតម្លៃដករំលស់។

២១. ចំណូលកម្រៃជើងសារសុទ្ធ

	ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណូលកម្រៃជើងសារ						
កម្រៃសេវាគណនីបញ្ញើ	785	3,181	3,972	16,067	3,824	15,468
ចំណាយកម្រៃជើងសារ						
សោហ៊ុយធនាគារ	1,915	7,760	3,066	12,402	-	-
ចំណូលកម្រៃជើងសារសុទ្ធ	(1,130)	(4,579)	906	3,665	3,824	15,468

២២. ចំណូល/(ខាត)ផ្សេងៗ

	ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណេញពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ	5,935	24,049	-	-	-	-
ចំណេញពីការប្តូររូបិយប័ណ្ណ	(99,123)	(401,646)	16,543	66,916	-	-
ចំណូលផ្សេងៗទៀត	2,850	11,547	5,491	22,212	-	-
	(90,338)	(366,050)	22,034	89,128	-	-

២៣. ការខាតបង់លើឱនភាពសុទ្ធនៃឧបករណ៍ហិរញ្ញវត្ថុ

	ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សមតុល្យនៅធនាគារនានា	308,430	1,249,758	(318,651)	(1,288,943)	-	-
ឥណទានផ្តល់ដល់អតិថិជន	(380)	(1,539)	59,676	241,389	(29,701)	(120,141)
	308,050	1,248,219	(258,975)	(1,047,554)	(29,701)	(120,141)

២៤. ចំណាយបុគ្គលិក

	ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់បៀវត្សរ៍ និងបុព្វលាភ	1,724,881	6,989,218	1,038,942	4,202,520	723,050	2,924,737
ប្រាក់ដំណាច់អតីតភាពការងារ	48,119	194,978	113,400	458,703	-	-
ចំណាយបុគ្គលិកផ្សេងៗ	78,429	317,794	66,635	269,539	64,605	261,327
	1,851,429	7,501,990	1,218,977	4,930,762	787,655	3,186,064

២៥. ចំណាយរំលស់

	ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសម្បត្តិ និងបរិក្ខារ	469,107	1,900,825	347,479	1,405,553	250,126	1,011,760
សិទ្ធិក្នុងការប្រើទ្រព្យសកម្ម	350,351	1,419,622	-	-	-	-
ទ្រព្យសកម្មអរូបី	29,846	120,932	30,133	121,888	13,369	54,078
	849,304	3,441,380	377,612	1,527,440	263,495	1,065,837

២៦. ចំណាយផ្សេងៗ

	ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
កម្រៃអាជ្ញាប័ណ្ណ ពន្ធប៉ាតង់ និងពន្ធផ្សេងៗ	301,948	1,223,493	205,933	832,999	102,762	415,673
សេវាវិជ្ជាជីវៈ	289,882	1,174,602	340,871	1,378,823	212,562	859,814
ការផ្សព្វផ្សាយពាណិជ្ជកម្ម និងទីផ្សារ	147,418	597,338	64,255	259,911	30,304	122,580
ទឹក-ភ្លើង	139,382	564,776	58,818	237,919	102,764	415,682
ការទំនាក់ទំនង	83,889	339,918	25,253	102,148	23,195	93,823
ភតិសន្យា និងការជួល	70,296	284,839	281,501	1,138,672	284,349	1,150,191
សម្ភារៈការិយាល័យ និងបរិក្ខារ	65,077	263,692	12,750	51,574	15,552	62,907
ការជួសជុល និងថែទាំ	15,341	62,162	4,043	16,354	3,528	14,269
ការរក្សាសន្តិសុខ	7,137	28,919	1,815	7,342	-	-
ផ្សេងៗ	190,150	770,488	241,920	978,566	221,774	897,073
	1,310,520	5,310,227	1,237,159	5,004,308	996,789	4,032,012

២៧. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ

ធនាគារគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលត្រូវបានកាន់កាប់ទាំងស្រុងដោយក្រុមហ៊ុន Chief Financial Group (Cambodia) Limited ធនាគារមេ ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមច្បាប់ នៃប្រទេស British Virgin Islands។

ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធសំខាន់ៗ មានដូចខាងក្រោម៖

ទំនាក់ទំនង	ភាគីពាក់ព័ន្ធ
ធនាគារមេ	ធនាគារដែលមានសិទ្ធកាន់កាប់ និងការគ្រប់គ្រងជាសារវន្តទៅលើធនាគារ។
ក្រុមហ៊ុនបុត្រសម្ព័ន្ធ/ធនាគារពាក់ព័ន្ធ	ក្រុមហ៊ុនទាំងឡាយដែលជាសមាជិក នៃក្រុមតែមួយ ឬភាទុនិកចុងក្រោយរបស់ធនាគារ។
គណៈគ្រប់គ្រងសំខាន់ៗ	បុគ្គលដែលមានសិទ្ធិអំណាច និងតួនាទីក្នុងការធ្វើគម្រោង ចាត់ការ និងគ្រប់គ្រងសកម្មភាពអាជីវកម្មរបស់ធនាគារ ដោយលក្ខណៈផ្ទាល់ ឬដោយប្រយោល រាប់បញ្ចូលទាំងអភិបាល (ទោះជាប្រតិបត្តិការ ឬមិនប្រតិបត្តិការ) នៃធនាគារ។

(ក).ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ	116,401	474,334	138,481	556,417	104,318	421,132

(ខ).ឥណទានផ្តល់ដល់ភាគីពាក់ព័ន្ធ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
គណៈគ្រប់គ្រងសំខាន់ៗ	473,857	1,930,967	513,727	2,064,155	195,178	787,934
ក្រុមហ៊ុនបុត្រសម្ព័ន្ធ	-	-	-	-	672,838	2,716,247
ធនាគារពាក់ព័ន្ធ	500,000	2,037,500	-	-	1,805,000	7,286,785
	973,857	3,968,467	513,727	2,064,155	2,673,016	10,790,966
ការប្រាក់ត្រូវទទួលពី						
គណៈគ្រប់គ្រងសំខាន់ៗ	620	2,527	1,223	4,914	709	2,862
ក្រុមហ៊ុនបុត្រសម្ព័ន្ធ	-	-	-	-	1,826	7,372
ធនាគារពាក់ព័ន្ធ	2,333	9,507	-	-	4,813	19,430
	2,953	12,034	1,223	4,914	7,348	29,664

(គ).សមតុល្យត្រូវបង់ជាមួយភាគីពាក់ព័ន្ធ

	31 December 2019		31 December 2018		31 December 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល	KHR'000
សាច់ប្រាក់ត្រូវបង់ទៅ ក្រុមហ៊ុនមេ	23,484	95,697	-	-	-	-

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

(ឃ).ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណាយដែលធនាគារមេបានបង់ជំនួស	56,219	227,799	324,307	1,311,822	545,893	2,208,137
ការទូទាត់ភតិសន្យា	210,000	850,920	120,000	485,400	120,000	485,400
កម្រៃអាជ្ញាប័ណ្ណត្រូវបង់ឲ្យធនាគារមេ	72,000	291,744	72,000	291,240	72,000	291,240
កម្រៃគ្រប់គ្រងត្រូវបង់ឲ្យក្រុមហ៊ុន Chief Securities Ltd.	180,000	729,360	66,000	266,970	66,000	266,970
ចំណូលការប្រាក់ពីឥណទានផ្តល់ដល់ គណៈគ្រប់គ្រង សំខាន់ៗ	34,279	138,899	14,697	59,449	12,294	49,729
ចំណូលការប្រាក់ពីឥណទានផ្តល់ដល់ ក្រុមហ៊ុនបុត្រសម្ព័ន្ធ	-	-	50,562	204,523	56,989	230,521
ចំណូលការប្រាក់ពីឥណទានផ្តល់ដល់ ក្រុមហ៊ុនពាក់ព័ន្ធ	27,111	109,854	143,700	581,267	153,899	622,521
	579,609	2,348,576	791,266	3,200,671	1,027,075	4,154,518

សកម្មភាពអាជីវកម្មរបស់ធនាគារប្រឈមមុខនឹងហានិភ័យហិរញ្ញវត្ថុផ្សេងៗមួយចំនួនដូចជា ហានិភ័យឥណទាន ហានិភ័យទីផ្សារ (រួមមាន ហានិភ័យរូបិយប័ណ្ណ ហានិភ័យ អត្រាការប្រាក់ និងហានិភ័យតម្លៃ) និងហានិភ័យសាច់ប្រាក់ងាយស្រួល។ អាជីវកម្មហិរញ្ញវត្ថុភាគច្រើនប្រឈមមុខនឹងហានិភ័យ ក្នុងនោះហានិភ័យប្រតិបត្តិការគឺជាផលវិបាកដែលពិបាកជៀសរួចណាស់ក្នុងដំណើរការអាជីវកម្ម។

ធនាគារមិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (derivative financial instrument) ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ (foreign exchange contract) និងការផ្លោះប្តូរអត្រាការប្រាក់ (interest rate swaps) ដើម្បីគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ខ្លួននោះទេ។

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

(ឃ).ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ(ត)

ប្រភេទនៃឧបករណ៍ហិរញ្ញវត្ថុ

ធនាគារមានទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្មហិរញ្ញវត្ថុ						
សាច់ប្រាក់ក្នុងដៃ	2,844,371	11,590,812	2,508,273	10,078,241	97,295	392,780
សមតុល្យនៅធនាគារជាតិនៃ កម្ពុជា	19,045,026	77,608,481	14,294,434	57,435,036	40,101,474	161,889,651
សមតុល្យនៅធនាគារនានា	608,585	2,479,984	15,402,227	61,886,148	125,234	505,570
ឥណទានផ្តល់ដល់អតិថិជន	77,745,040	316,811,038	44,011,194	176,836,977	33,608,083	135,675,831
ទ្រព្យសកម្មផ្សេងៗ	174,714	711,959	528,770	2,124,598	24,127	97,401
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	100,417,736	409,202,274	76,744,898	308,361,000	73,956,213	298,561,232
បំណុលហិរញ្ញវត្ថុ						
ប្រាក់បញ្ញើពីអតិថិជន	26,220,095	106,846,887	2,435,707	9,786,671	-	-
បំណុលភតិសន្យា	1,644,788	6,702,511	-	-	-	-
បំណុលផ្សេងៗ	112,736	459,400	83,456	335,327	68,309	195,459
បំណុលហិរញ្ញវត្ថុសរុប	27,977,619	114,008,798	2,519,163	10,121,998	68,309	195,459

ចំណាត់ថ្នាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុនៅកាលបរិច្ឆេទនៃការអនុវត្តដំបូងរបស់ CIFRS 9

តារាងខាងក្រោមបង្ហាញពីការវាស់វែងដំបូងនៃប្រភេទនីមួយៗទៅតាម CIAS 39 និងការវាស់វែងថ្មីនៃប្រភេទនីមួយៗក្រោម CIFRS 9 សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ធនាគារនាកាលបរិច្ឆេទថ្ងៃទី 1 ខែ មករា ឆ្នាំ 2018។

	ការចែកចំណាត់ថ្នាក់ដំបូងក្រោម CIAS 39	ការចែកចំណាត់ថ្នាក់ថ្មីក្រោម CIFRS	តម្លៃយោងដំបូងក្រោម CIAS 39	CIFRS 9 វាស់វែងឡើងវិញរួមមាន ECL	កំណត់សម្គាល់	តម្លៃយោងថ្មីក្រោម CIFRS 9
				ដុល្លារអាមេរិក		ដុល្លារអាមេរិក
ទ្រព្យសកម្មហិរញ្ញវត្ថុ						
សាច់ប្រាក់ក្នុងដៃ	ឥណទាន និងគណនីត្រូវទទួលបាន	តម្លៃដករំលស់	97,295	-		97,295
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	ឥណទាន និងគណនីត្រូវទទួលបាន	តម្លៃដករំលស់	40,101,474	-		40,101,474
សមតុល្យនៅធនាគារនានា	ឥណទាន និងគណនីត្រូវទទួលបាន	តម្លៃដករំលស់	125,234	(2,580)	(ក)	122,654
ឥណទានផ្តល់ដល់អតិថិជន	ឥណទាន និងគណនីត្រូវទទួលបាន	តម្លៃដករំលស់	33,608,083	280,762		33,888,845
ទ្រព្យសកម្មផ្សេងៗ	ឥណទាន និងគណនីត្រូវទទួលបាន	តម្លៃដករំលស់	24,127	-	(ក)	24,127
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប			73,956,213	278,182		74,234,395
សមមូលជាពាន់រៀល			298,561,232	1,123,019		299,684,251

២៨. ប្រតបត្តការ និងសមតុល្យភាគពាក់ព័ន្ធ(ត)

ចំណាត់ថ្នាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុនៅកាលបរិច្ឆេទនៃការអនុវត្តដំបូងរបស់ CIFRS 9 (ត)

	ការចែកចំណាត់ថ្នាក់ដំបូងក្រោម CIAS 39	ការចែកចំណាត់ថ្នាក់ថ្មីក្រោម CIFRS	តម្លៃយោងដំបូងក្រោម CIAS 39	CIFRS 9 វាស់វែងឡើងវិញ រួមមាន ECL	តម្លៃយោងថ្មីក្រោម CIFRS 9
បំណុលហិរញ្ញវត្ថុ					
បំណុលផ្សេងៗ	តម្លៃដករំលស់	តម្លៃដករំលស់	68,309	-	68,309
បំណុលហិរញ្ញវត្ថុសរុប			68,309	-	68,309
សមមូលជាពាន់រៀល			275,763	-	275,763

	តម្លៃយោងដំបូងក្រោមCIAS 39	CIFRS 9 វាស់វែងឡើងវិញ រួមមាន ECL	កំណត់សម្គាល់	តម្លៃយោងថ្មីក្រោម CIFRS 9
មូលធន*				
ដើមទុននិង បុព្វលាភ	38,800,000	-		38,800,000
ការបន្ថែមដើមទុន	36,200,000	-		36,200,000
ប្រាក់ចំនេញរក្សាទុក	568,494	278,182	(ក)	846,676
មូលធនសរុប	75,568,494	278,182		75,846,676
សមមូលជាពាន់រៀល	305,070,010	1,123,020		306,193,030

* មិនមែនឧបករណហិរញ្ញវត្ថុ

កំណត់សម្គាល់សម្រាប់ការផ្ទៀងផ្ទាត់៖

(ក) ការអនុវត្តនៃតម្រូវការឱនភាព CIFRS 9 បានចេញលទ្ធផលជា ការខាតបង់នៃសំវិធានធនដើម្បីទទួលស្គាល់សម្រាប់សមតុល្យនៅធនាគារនានា និងការកាត់បន្ថយនូវការខាតបង់នៃសំវិធានធនសម្រាប់ឥណទានផ្តល់ដល់អតិថិជន។

(ខ) ការអនុវត្តនៃតម្រូវការឱនភាព CIFRS 9 បានចេញលទ្ធផលជាក្រេដីតសុទ្ធនៃប្រាក់ចំណេញរក្សាទុក។

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន

ហានិភ័យឥណទានសំដៅទៅលើហានិភ័យដែលធនាគាររងការខាតបង់ផ្នែកហិរញ្ញវត្ថុប្រសិនបើសមភាគីខកខានក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា និងការខាតបង់ដែលកើតឡើងពី ប្រាក់បញ្ញើជាមួយធនាគារនានា និងឥណទានផ្តល់ដល់អតិថិជន (រួមទាំងកិច្ចសន្យាឥណទាន)។ ធនាគារបានពិចារណាគ្រប់ផ្នែកទាំងអស់នៃហានិភ័យឥណទាន រួមមានហានិភ័យដែល សមភាគីពុំមានលទ្ធភាពសង ហានិភ័យភូមិសាស្ត្រ និងហានិភ័យវិស័យ ហានិភ័យផលិតផល និងហានិភ័យអាជីវកម្មក្នុងគោលបំណងគ្រប់គ្រងហានិភ័យ។

២៨.១.១ ការគ្រប់គ្រងហានិភ័យឥណទាន

គណៈកម្មាធិការឥណទានរបស់សម្ព័ន្ធធនាគារមានទំនួលត្រូវក្នុងការគ្រប់គ្រងហានិភ័យឥណទានរបស់ ធនាគារដោយៈ

- ធានាថា ធនាគារមានការអនុវត្តហានិភ័យឥណទានសមស្រប រួមទាំងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាពដើម្បីកំណត់នូវសំវិធានធនគ្រប់គ្រាន់ស្របតាមគោលនយោបាយ និងនីតិវិធីដែលបានចែងរបស់ ធនាគារ CIFRS និងការណែនាំត្រួតពិនិត្យដែលពាក់ព័ន្ធ។
- កំណត់អត្តសញ្ញាណ វាយតម្លៃ និងវាស់វែងហានិភ័យឥណទាននៅទូទាំងសម្ព័ន្ធធនាគារចាប់ពីឧបករណ៍តែមួយទៅកម្រិតផលប័ត្រ។
- បង្កើតគោលនយោបាយឥណទានដើម្បីការពារ ធនាគារពីហានិភ័យដែលបានកំណត់ រួមទាំងតម្រូវការដើម្បីទទួលបានវត្តបញ្ចាំពីអ្នកខ្ចីដើម្បីអនុវត្តការវាយតម្លៃឥណទានរបស់អ្នកខ្ចី និងដើម្បីតាមដានត្រួតពិនិត្យការប្រឈមនឹងហានិភ័យផ្ទៃក្នុងជាបន្តបន្ទាប់។
- កំណត់នៃការប៉ះពាល់នៃប្រភេទនៃទ្រព្យ សមភាគី ឧស្សាហកម្ម ការវាយតម្លៃឥណទាន ទីតាំងភូមិសាស្ត្រ។ល។
- បង្កើតក្របខ័ណ្ឌត្រួតពិនិត្យដ៏រឹងមាំទាក់ទងនឹងរចនាសម្ព័ន្ធដែលអនុញ្ញាតសម្រាប់ការអនុម័ត និងការបន្តផ្តល់ឥណទានហ្វាស៊ីលីធី។
- អភិវឌ្ឍ និងថែរក្សានូវការចាត់ចំណាត់ថ្នាក់ហានិភ័យរបស់ ធនាគារដើម្បីចាត់ថ្នាក់ហានិភ័យតាមប្រភេទ ហានិភ័យ។ ការចាត់ថ្នាក់ ហានិភ័យត្រូវឆ្លងកាត់ការត្រួតពិនិត្យជាប្រចាំ។
- អភិវឌ្ឍន៍ និងថែរក្សាដំណើរការរបស់ ធនាគារក្នុងការវាស់ ECL រួមមានការត្រួតពិនិត្យហានិភ័យឥណទាន ការបញ្ចូលព័ត៌មានដែលមើលទៅមុខ និងវិធីសាស្ត្រប្រើប្រាស់ក្នុងការវាស់ ECL។
- ធានាថា ធនាគារនេះមានគោលនយោបាយ និងនីតិវិធីក្នុងការថែរក្សា និងធ្វើឱ្យបានត្រឹមត្រូវនូវគំរូដែលត្រូវបានប្រើដើម្បីវាយ តម្លៃ និងវាស់វែង ECL។
- បង្កើតការវាយតម្លៃគណនេយ្យ និងដំណើរការវាស់វែងហានិភ័យឥណទានដែលផ្តល់ជាមូលដ្ឋានរឹងមាំសំរាប់ប្រព័ន្ធទូទៅ ឧបករណ៍និងទិន្នន័យដើម្បីវាយតម្លៃហានិភ័យឥណទាននិងគណនេយ្យភាពរបស់ ECL ។ ការផ្តល់យោបល់ និងការណែនាំ ព្រមទាំងជំនាញដល់អង្គភាពអាជីវកម្មដើម្បីលើកកម្ពស់ការអនុវត្តល្អបំផុតនៅទូទាំង ធនាគារក្នុងការគ្រប់គ្រងហានិភ័យឥណទាន។
- សវនកម្មផ្ទៃក្នុងមានមុខងារធ្វើសវនកម្មទៀងទាត់ដើម្បីឱ្យប្រាកដថាការគ្រប់គ្រងនិងនីតិវិធីដែលបានបង្កើតឡើងត្រូវបានរៀបចំនិងអនុវត្តឱ្យបានត្រឹមត្រូវ។

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន

២៨.១.២ ការវិភាគគុណភាពឥណទាន

តារាងខា ងក្រោមនេះបង្ហាញព័ត៌មានអំពីគុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែងតាមតម្លៃដក រំលស់។ លុះត្រាតែបានបញ្ជាក់ច្បាស់លាស់ ចំនួនទឹកប្រាក់នៃទ្រព្យសម្បត្តិហិរញ្ញវត្ថុទាំងអស់ នៅក្នុងតារាង តំណាងខាងក្រោមបង្ហាញជាតម្លៃយោងដុល។

ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

	ដំណាក់កាលទី1	ដំណាក់កាលទី2	ដំណាក់កាលទី3	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
សមតុល្យជាមួយធនាគារនានា៖					
ធម្មតា	621,386	-		621,386	2,532,148
សំវិធានធនលើការខាតបង់	(12,801)	-		(12,801)	(52,164)
តម្លៃយោង	608,585	-	-	608,585	2,479,984
ឥណទានផ្តល់ដល់អតិថិជន៖					
ធម្មតា	77,745,930			77,745,930	316,814,665
សំវិធានធនលើការខាតបង់	(890)			(890)	(3,627)
តម្លៃយោង	77,745,040	-	-	77,745,040	316,811,038

ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

	ដំណាក់កាលទី1	ដំណាក់កាលទី2	ដំណាក់កាលទី3	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
សមតុល្យជាមួយធនាគារនានា៖					
ធម្មតា	15,723,458	-	-	15,723,458	63,176,854
សំវិធានធនលើការខាតបង់	(321,231)	-	-	(321,231)	(1,290,706)
តម្លៃយោង	15,402,227	-	-	15,402,227	61,886,148
ឥណទានផ្តល់ដល់អតិថិជន៖					
ធម្មតា	44,011,704	-	-	44,011,704	176,839,026
ឃ្លាំមើល	-	-	-	-	-
ក្រោមស្តង់ដា	-	-	-	-	-
សង្ស័យ	-	-	-	-	-
បាត់បង់	-	-	-	-	-
	44,011,704	-	-	44,011,704	176,839,026
សំវិធានធនលើការខាតបង់	(510)	-	-	(510)	(2,049)
តម្លៃយោង	44,011,194	-	-	44,011,194	176,836,977

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.២ ការវិភាគគុណភាពឥណទាន(ត)

តារាងខាងក្រោមនេះបង្ហាញព័ត៌មានអំពីស្ថានភាពហួសកាលកំណត់សង នៃឥណទានផ្តល់ដល់អតិថិជននៃដំណាក់កាលទី១ ទី២និងទី៣។

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019				
	ដំណាក់កាលទី1	ដំណាក់កាលទី2	ដំណាក់កាលទី3	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
ឥណទានផ្តល់ដល់អតិថិជន៖					
ចរន្ត	77,745,930	-	-	77,745,930	316,814,665

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018				
	ដំណាក់កាលទី1	ដំណាក់កាលទី2	ដំណាក់កាលទី3	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
ឥណទានផ្តល់ដល់អតិថិជន៖					
ចរន្ត	44,011,704	-	-	44,011,704	176,839,026

តារាងខាងក្រោមវិភាគពីចលនានៃសំវិធានធនការបាត់បង់ក្នុងឆ្នាំ នៃឥណទានផ្តល់ដល់អតិថិជនតាមតម្លៃដករំលស់៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019				
	ដំណាក់កាលទី1	ដំណាក់កាលទី2	ដំណាក់កាលទី3		
	12 ខែ	អាយុកាល	អាយុកាល		
	ECL	ECL	ECL	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
សំវិធានធនលើការខាតបង់ គិតត្រឹមថ្ងៃទី 1 ខែ មករា ឆ្នាំ2019	510	-	-	510	2,078
បម្រែបម្រួលសំវិធានធនលើ ការខាតបង់					
- ការផ្ទេរទៅដំណាក់កាលទី1	-	-	-	-	-
- ការផ្ទេរទៅដំណាក់កាលទី2	-	-	-	-	-
- ការផ្ទេរទៅដំណាក់កាលទី3	-	-	-	-	-
ទ្រព្យសកម្មហិរញ្ញវត្ថុថ្មីដែលកើតឡើង	600	-	-	600	2,445
ការវាស់វែងឡើងវិញលើសំវិធានធនសុទ្ធ និងចលនាផ្សេងៗ	(220)	-	-	(220)	(897)
សំវិធានធនលើការខាតបង់ គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	890	-	-	890	3,626

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.២ ការវិភាគគុណភាពឥណទាន(ត)

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018				
	ដំណាក់កាលទី1	ដំណាក់កាលទី2	ដំណាក់កាលទី3		
	12 ខែ	អាយុកាល	អាយុកាល		
	ECL	ECL	ECL	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
សំវិធានធនលើការខាតបង់					
គិតត្រឹមថ្ងៃទី 1 ខែ មករា ឆ្នាំ2018	59,995	-	-	59,995	241,060
បម្រែបម្រួលសំវិធានធនលើ ការខាតបង់					
- ការផ្ទេរទៅដំណាក់កាលទី1	-	-	-	-	-
- ការផ្ទេរទៅដំណាក់កាលទី2	-	-	-	-	-
- ការផ្ទេរទៅដំណាក់កាលទី3	-	-	-	-	-
ទ្រព្យសកម្មហិរញ្ញវត្ថុថ្មីដែលកើតឡើង	360	-	-	360	1,446
ការវាស់វែងឡើងវិញលើសំវិធានធនសុទ្ធ និងចលនាផ្សេងៗ	(59,845)	-	-	(59,845)	(240,457)
សំវិធានធនលើការខាតបង់					
គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	510	-	-	510	2,049

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.២ ការវិភាគគុណភាពឥណទាន(ត)

តារាងខាងក្រោមវិភាគពីចលនានៃតម្លៃយោងដុលនៃឥណទានផ្តល់ដល់អតិថិជនតាមតម្លៃដករំលស់ក្នុងឆ្នាំដែលចូលរួមចំណែកធ្វើឲ្យមានការប្រែប្រួលនៃសំវិធានធនខាតបង់។

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019				
	ដំណាក់កាលទី1	ដំណាក់កាលទី2	ដំណាក់កាលទី3		
	12 ខែ	អាយុកាល	អាយុកាល		
	ECL	ECL	ECL	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
តម្លៃយោងដុល					
គិតត្រឹមថ្ងៃទី 1 ខែ មករា ឆ្នាំ 2019	44,011,704	-	-	44,011,704	179,347,694
បម្រែបម្រួលតម្លៃយោងដុល					
- ការផ្ទេរទៅដំណាក់កាលទី1					
- ការផ្ទេរទៅដំណាក់កាលទី2	-	-	-	-	-
- ការផ្ទេរទៅដំណាក់កាលទី3	-	-	-	-	-
ទ្រព្យសកម្មហិរញ្ញវត្ថុថ្មីដែលកើតឡើង	45,188,120	-	-	45,188,120	184,141,589
ចលនាសុទ្ធ	(11,453,894)	-	-	(11,453,894)	(46,674,618)
តម្លៃយោងដុល					
គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	77,745,930	-	-	77,745,930	316,814,665

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019				
	ដំណាក់កាលទី1	ដំណាក់កាលទី2	ដំណាក់កាលទី3		
	12 ខែ	អាយុកាល	អាយុកាល		
	ECL	ECL	ECL	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
តម្លៃយោងដុល					
គិតត្រឹមថ្ងៃទី 1 ខែ មករា ឆ្នាំ 2018	33,948,838	-	-	33,948,838	136,406,431
បម្រែបម្រួលតម្លៃយោងដុល					
- ការផ្ទេរទៅដំណាក់កាលទី1					
- ការផ្ទេរទៅដំណាក់កាលទី2	-	-	-	-	-
- ការផ្ទេរទៅដំណាក់កាលទី3	-	-	-	-	-
ទ្រព្យសកម្មហិរញ្ញវត្ថុថ្មីដែលកើតឡើង	22,891,451	-	-	22,891,451	91,977,850
ចលនាសុទ្ធ	(12,828,585)	-	-	(12,828,585)	(51,545,255)
តម្លៃយោងដុល					
គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	44,011,704	-	-	44,011,704	176,839,026

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.៣ ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL

ត) សមាសធាតុ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃការថយចុះតម្លៃ

ធនាគារបានទទួលស្គាល់សំវិធានធនលើការបាត់បង់ ECL ចំពោះឧបករណ៍ហិរញ្ញវត្ថុដែលមិនបានវាស់វែងតាម FVTPL ដូច ខាងក្រោម៖

- សមតុល្យជាមួយធនាគារនានា
- ឧបករណ៍ហិរញ្ញវត្ថុជាបំណុល

ចំពោះការវិនិយោគក្នុងឧបករណ៍ហិរញ្ញវត្ថុជាទ្រព្យម្ចាស់ គឺមិនត្រូវបានធ្វើការវាយតម្លៃលើការបាត់បង់នោះទេ។

ធនាគា វាស់វែងសំវិធានធនលើការបាត់បង់ តាមចំនួនដែលស្មើនឹង ECL ពេញមួយអាយុកាលលើកលែងតែការវាស់វែងតាម ECL ១២ខែ ដូចខាងក្រោម៖

- សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា ដែលត្រូវបានកំណត់ថាមានហានិភ័យឥណទានទាបនា កាលបរិច្ឆេទរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ដែលហានិភ័យឥណទានមិនបានកើនឡើងខ្លាំង ចាប់តាំងពីការទទួលស្គាល់ លើកដំបូង។

ធនាគារមិនបានអនុវត្តការលើកលែងឥណទានមានហានិភ័យទាប ចំពោះឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតទេ។

ECL12ខែគឺជាផ្នែកនៃECLដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល12ខែ បន្ទាប់ពី កាលបរិច្ឆេទរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាម ELC 12 ខែ ត្រូវបានចាត់ទុកជា "ឧបករណ៍ ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី1"។

ECL មួយអាយុកាល (Lifetime ECL) គឺជា ECL ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ ក្នុងរយៈពេលនៃអាយុកាលរំពឹងទុក (expected life) នៃឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាមECL ពេញមួយអាយុកាល ប៉ុន្តែមិនមែនជាឥណទានមានការថយចុះ (credit-impaired) ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិត ក្នុងដំណាក់កាលទី២" ។

ទ្រព្យសកម្មហិរញ្ញវត្ថុមានការថយចុះតម្លៃ

តាមកាលបរិច្ឆេទរាយការណ៍នីមួយៗ ធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានកត់ត្រាតាម តម្លៃដករំលស់ (amortised cost) ហើយមានការថយចុះតម្លៃ ត្រូវបានចាត់ទុកជា "ទ្រព្យសកម្មហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី៣"។ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថាមាន "ការថយចុះតម្លៃ" នៅពេលមានព្រឹត្តិការណ៍មួយឬច្រើន បានកើតឡើង ដែលនាំឱ្យមានផលប៉ះពាល់អវិជ្ជមានដល់លំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងទុក នៃទ្រព្យសម្បត្តិហិរញ្ញវត្ថុ។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសម្បត្តិហិរញ្ញវត្ថុមានការថយចុះតម្លៃ រួមបញ្ចូលនូវទិន្នន័យដែលអាចអង្កេតបាន ដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃការផ្តល់ឥណទានដល់អតិថិជន ដែលធនាគារមិនយល់ព្រម
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី

ឥណទានដែលត្រូវបានរៀបចំឡើងវិញ ដោយសារតែភាពមិនប្រក្រតីនៅក្នុងលក្ខខណ្ឌរបស់អតិថិជន ត្រូវបាន ចាត់ទុកជាឥណទានមានការថយចុះតម្លៃលុះត្រាតែមានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរ សាច់ប្រាក់តាមកិច្ចសន្យាបានថយចុះជាសំខាន់ និងមិនមានសូចនាករផ្សេងទៀតដែលនាំឱ្យមានការថយចុះតម្លៃ។ ផ្អែកទៅតាមការសន្មតដែលអាចបដិសេធបាន នៃស្តង់ដា CIFRS ឥណទានមានរយៈពេលវែងដែលហួសកាលកំណត់សងលើសពី ៩០ថ្ងៃ និង៣០ថ្ងៃ សម្រាប់ឥណទានរយៈពេលខ្លី ត្រូវបានចាត់ទុកជាឥណទានមានការថយចុះតម្លៃ ទោះបីជានិយមន័យនៃការហួសកាលកំណត់សងដែលច្បាប់បានកំណត់ផ្សេងគ្នាក៏ដោយ។

ផ្អែកតាមប្រព័ន្ធចាត់ថ្នាក់ហានិភ័យឥណទានរបស់ ធនាគារ ឥណទានផ្តល់ដល់អតិថិជនដែលចាត់ទុកថាមាន ការថយចុះតម្លៃ ជាឥណទានទាំងឡាយណាដែលមានចំណាត់ថ្នាក់ ក្រោមស្តង់ដា សង្ស័យ និងបាត់បង់។

ការចាត់ថ្នាក់ហានិភ័យឥណទាន

ធនាគារបានបែងចែកការប៉ះពាល់ទៅតាមការចាត់ថ្នាក់ហានិភ័យឥណទាន ស្របទៅតាមនិយមន័យរបស់ ធនាគារជាតិនៃកម្ពុជា ដោយផ្អែកទៅតាមចំនួនថ្ងៃនៃការហួសកំណត់សង ដែលជាលក្ខណៈវិនិច្ឆ័យដោយប្រុងប្រយ័ត្ន ដូចខាងក្រោម៖

1. ធម្មតា
2. ឃ្លាំមើល
3. ក្រោមស្តង់ដា
4. សង្ស័យ
5. បាត់បង់

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.៣ ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL(ត)

ទ្រព្យសកម្មហិរញ្ញវត្ថុមានការថយចុះតម្លៃ(ត)

ការប៉ះពាល់ត្រូវបានតាមដានជាប្រចាំ ដែលការប៉ះពាល់អាចធ្វើឱ្យមានការផ្លាស់ប្តូរដល់ការចាត់ថ្នាក់ហានិភ័យ ឥណទាន។ ជាទូទៅការតាមដាននេះជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ទិន្នន័យដូចខាងក្រោម៖

- ប្រវត្តិទូទាត់សង
- ស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី
- ចក្ខុវិស័យអាជីវកម្ម និងការព្យាករណ៍លំហូរសាច់ប្រាក់
- លទ្ធភាព និងឆន្ទៈទូទាត់សង
- ស្ថានភាពសេដ្ឋកិច្ច និង
- គុណភាពនៃសំណុំឯកសារ

(i) ការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទាន

ធនាគារពិចារណាអំពីការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទានជាពីរដំណាក់កាលដូចខាងក្រោម៖

<u>ការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទានស្ថិតក្នុងដំណាក់កាលទី2</u>

ការផ្លាស់ប្តូរកម្រិតនៃហានិភ័យឥណទាន ទៅលើ អាយុកាល ដែលរំពឹងទុក នៃឧបករណ៍ហិរញ្ញវត្ថុ ត្រូវបាន វាយតម្លៃតាមរយៈការប្រៀបធៀបហានិភ័យឥណទាន តាមកាលបរិច្ឆេទរាយការណ៍នីមួយៗ ជាមួយនឹងហានិភ័យឥណទាន នៃឧបករណ៍ហិរញ្ញវត្ថុនៅពេលទទួលស្គាល់លើកដំបូង។ ការវា ស់វែងទៅលើគុណភាព និងបរិមាណក្នុង ការកំណត់ថាតើ ការកើនឡើងជាសំខាន់នូវហានិភ័យឥណទានដែល បានកើតឡើងត្រូវបានបង្ហាញដូចខាងក្រោម៖

- ការខកខានសងចំនួន 30 ថ្ងៃ ជាបង្គោល (backstop) សម្រាប់ឥណទានមានរយៈពេលវែង និង15 ថ្ងៃ សម្រាប់ឥណទាន មានរយៈពេលខ្លី
- ការប្រើសូចនាករគុណភាពផ្សេងៗទៀត

ធនាគារប្រើបាស្រ័ការខកខានសងចំនួន 30 ថ្ងៃ ជាបង្គោល និង15ថ្ងៃជាបង្គោល និងអនុវត្តការ សន្មតដែលអាចបដិសេធបានដោយ កំណត់ថាហានិភ័យឥណទានលើទ្រព្យសម្បត្តិហិរញ្ញវត្ថុ បានកើនឡើងគួរឲ្យកត់សម្គាល់ចាប់តាំងពីការទទួលស្គាល់លើកដំបូងនៅពេលដែលការទូទាត់តាមកិច្ចសន្យា មានការខកខានសងលើសពី 30 ថ្ងៃ ឬ15 ថ្ងៃ។ លើសពីនេះ ទៀត ឥណទានផ្តល់ដល់ អតិថិជនដែលត្រូវ បានរៀបចំឡើងវិញ និងត្រូវបានចាត់ថ្នាក់ក្នុងឃ្លាំមើល ត្រូវបានផ្លាស់ប្តូរពីដំណាក់ កាលទី1 ទៅដំណាក់កាលទី2។

<u>ការកើនឡើង គួរឲ្យកត់សម្គាល់នៃហានិភ័យឥណទានស្ថិតក្នុងដំណាក់កាលទី3</u>

ឧប ក រណ៍ហិរញ្ញវត្ថុ ដែល ត្រូវបានចាត់ទុកជាឥណទានមានការថយចុះតម្លៃចាប់តាំងពីពេលដំបូង ឬពីពេលទិញ ត្រូវចាត់ថ្នាក់ដោយស្វ័ យប្រវត្តិ ជាឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី3។ ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្ម ហិរញ្ញវត្ថុមានការថយចុះតម្លៃរួមមានទិន្នន័យ ដែលអាចអង្កេតបានទាក់ទងទៅនឹងព្រឹត្តិការណ៍ ដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី
- ការបាត់បង់ទីផ្សារសកម្មសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដោយសារតែបញ្ហាហិរញ្ញវត្ថុ ដូចជាស្ថានភាពជំនួញ កូនបំណុលស្ថិតក្នុងដំណើរការវិវាទ ភាពញឹកញាប់នៃការរៀបចំបំណុលឡើងវិញជាដើម។
- កូនបំណុលដែលក្លែងបន្លំ
- ការលក់ ឬការលុបដោយចោលឥណទានខូចដោយផ្នែក
- មរណៈភាព
- ការរៀបចំឡើងវិញនូវបំណុលដែលមានបញ្ហា (Trouble Debt Restructuring) ដោយមិនជោគជ័យ

ធនាគារបានអនុវត្តការខកខានសងចំនួន ៩០ ថ្ងៃ ជាបង្គោលសម្រាប់ឥណទានមានរយៈពេលវែង និង ៣០ថ្ងៃជាបង្គោលសម្រាប់ឥណទាន មានរយៈពេលខ្លី ក្នុងការផ្លាស់ប្តូរឧបករណ៍ហិរញ្ញវត្ថុ ពីដំណាក់កាលទី2 ទៅដំណាក់កាលទី៣ និងចាត់ទុកឧបករណ៍ហិរញ្ញវត្ថុនោះថាមានការថយចុះតម្លៃ។ លើសពីនេះទៀត ឥណទានផ្តល់ដល់អតិថិជនដែលត្រូវបានរៀបចំឡើងវិញ និងបានចាត់ថ្នាក់ក្នុងក្រោមស្តង់ដា សង្ស័យ និងបាត់បង់ ត្រូវបាន ផ្លាស់ប្តូរពីដំណាក់កាលទី2 ទៅដំណាក់កាលទី3។

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.៣ ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL(ត)

(ii) និយមន័យនៃការខកខានសង

ធនាគារចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការខកខានសងនៅពេលដែល៖

- អ្នកខ្ចីមិនមានលទ្ធភាពសងចំពោះកាតព្វកិច្ចឥណទានរបស់ខ្លួនទៅ ធនាគារទាំងស្រុងវិញ ដោយមិនពឹងផ្អែកទៅលើការលក់ទ្រព្យដាក់ធានាដោយធនាគារដើម្បីទូទាត់សង (ប្រសិនបើមានទ្រព្យដាក់ធានា) ឬ
- អ្នកខ្ចីស្ថិតលើកាតព្វកិច្ចសងឥណទានមក ធនាគារន ឬ
- អ្នកខ្ចីនឹងកែសំរួលទ្រព្យសម្បត្តិរបស់ខ្លួនដែលជាលទ្ធផលនៃការក្ស័យធន ដោយសារមិនមានលទ្ធភាពសងកាតព្វកិច្ចឥណទានរបស់ ខ្លួន។

(iii) ការបញ្ចូលព័ត៌មានព្យាករណ៍នាពេលអនាគត

ធនាគារវិភាគព័ត៌មានព្យាករណ៍នាពេលអនាគត ដោយប្រើម៉ូឌែលស្ថិតិនៃនិន្នាការនាពេលអនាគត ក្នុង

ការវាយតម្លៃថាតើហានិភ័យឥណទានលើឧបករណ៍ហិរញ្ញវត្ថុ បានកើនឡើងជាសំខាន់ ដើម្បីធ្វើការវាស់វែង ECL។

ធនាគារបានបង្កើតសេណារីយ៉ូសេដ្ឋកិច្ច ចំនួនបី៖ កម្រិតមូលដ្ឋាន ដែលជាសេណារីយ៉ូមធ្យម ត្រូវបានកំណត់ប្រូបាប៊ីលីតេនៃការកើត ឡើងចំនួន 35% និងសេណារីយ៉ូពីរទៀតដែលកម្រកើតឡើង គឺ មួយជាកម្រិតឡើង 25% និងមួយជាកម្រិតចុះមានប្រូបាប៊ីលីតេនៃការកើតឡើងចំនួន 40%។ ករណីមូលដ្ឋានត្រូវបានដាក់ចូលជាមួយព័ត៌មានដែលបានប្រើដោយធនាគារ ក្នុងគោលបំណងផ្សេងទៀត ដូចជាការរៀបចំផែនការយុទ្ធសាស្ត្រ និងការចំណាយ ថវិការ។ ព័ត៌មានខាងក្រៅដែលទាក់ទងរួមមាន ទិន្នន័យសេដ្ឋកិច្ច និងការព្យាករណ៍ដែលបោះពុម្ពផ្សាយដោយស្ថាប័ន រដ្ឋាភិបាល (ធនាគារជាតិនៃកម្ពុជា) និងស្ថាប័នអន្តរជាតិ ដូចជា ធនាគារពិភពលោក និង Bloomberg។

សេណារីយ៉ូទំងន់	ផ្អែកលើ	អាក្រក់	ល្អ
	35%	40%	25%

ផ្អែកលើការវិភាគព្យាករណ៍ថ្ងៃអនាគត ធនាគារប្រើប្រាស់នូវរង្វាស់ព្យាករណ៍ថ្ងៃអនាគតក្នុងមួយឆ្នាំ (1.42) សម្រាប់ 12-ខែ និង អាយុកាល ECL។

2019	2020	2021
1.05	1.07	1.05

(iv) ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ

ធនាគារធ្វើការចរចាឡើងវិញនូវឥណទានផ្តល់ដល់អតិថិជនដែលមានផលលំបាកផ្នែកហិរញ្ញវត្ថុ (សំដៅដល់ សកម្មភាពរៀប ចំឥណទានឡើងវិញ) ដើម្បីបង្កើនឱកាសអតិបរិមាក្នុងការប្រមូលត្រលប់វិញ និងកាត់បន្ថយហានិភ័យនៃការខកខានសង។ ផ្អែកទៅតាមគោលនយោបាយរបស់ធនាគារឥណទានរៀបចំឡើងវិញ ត្រូវបាន ផ្តល់ជូនដោយ ផ្អែកលើមូលដ្ឋានជ្រើសរើស ប្រសិនបើកូនបំណុលមានការខកខានសងនាពេលបច្ចុប្បន្ន ឬប្រសិនបើមាន ហានិភ័យ ខ្ពស់នៃការខកខានសង និងមានភស្តុតាងបង្ហាញថាកូនបំណុលពិតជាបានខិត ខំប្រឹងប្រែងសងទូទាត់បំណុលទៅតាម លក្ខខណ្ឌនៃកិច្ចសន្យាដើម និងរំពឹងថាកូនបំណុលនឹងអាចបំពេញតាមល័ក្ខខណ្ឌដែលបានកែប្រែ។ លក្ខខណ្ឌដែលបានកែប្រែ ជាធម្មតារួមបញ្ចូលទាំងការពន្យារពេលកំណត់ ការផ្លាស់ប្តូររយៈពេលនៃការទូទាត់សងការប្រាក់ និងការកែប្រែលក្ខខណ្ឌនៃកិច្ចព្រមព្រៀងឥណទាន។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ ទៅតាមគោលនយោបាយនៃការរៀបចំឥណទានឡើងវិញរបស់ ធនាគារ ការព្យាករណ៍ PD ឆ្លុះបញ្ចាំងការកែប្រែត្រូវបានកែលម្អ ឬស្តារឡើងវិញនូវលទ្ធភាពរបស់ ធនាគារក្នុងការប្រមូល ការប្រាក់ និងប្រាក់ដើមទៅតាមបទពិសោធន៍ធនាគារធ្លាប់មាន។ ជាផ្នែកមួយនៃដំណើរការនេះ ធនាគារធ្វើការវាយតម្លៃលទ្ធភាពទូទាត់សងរបស់កូនបំណុលធៀបទៅនឹងលក្ខខណ្ឌកិច្ចសន្យាដែលបានកែប្រែ និងពិចារណាទៅលើ សូចនាករអាកប្បកិរិយាជាច្រើនផ្សេងទៀត។

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.៣ ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL(ត)

ជាទូទៅ ការរៀបចំឡើងវិញ គឺជាសូចនាករគុណភាពនៃការកើនឡើងជាសំខាន់នូវហានិភ័យឥណទាន ដែលការរៀបចំឡើងវិញត្រូវបានចាត់ទុកថាមានភស្តុតាងដែលបញ្ជាក់ពីផលប៉ះពាល់នៃឥណទានមានការថយចុះតម្លៃ។ អតិថិជន ត្រូវបង្ហាញឥរិយាបថបង់ប្រាក់ល្អជាប់លាប់ក្នុងរយៈពេលមួយ មុនពេលដែលការប៉ះពាល់មិនត្រូវបានចាត់ទុកថាមាន ការថយចុះតម្លៃ/មិនមានលទ្ធភាពសង ឬ PD ត្រូវបានចាត់ទុកថាបានថយចុះ ដោយសមរិធានធនការខាតបង់ត្រូវបាន វាស់វែងតាមចំនួនទឹកប្រាក់ដូចក្នុងដំណាក់កាលទី១។

(v) ការវាស់វែង ECL

ECL គឺជាការប៉ាន់ស្មានប្រូបាប៊ីលីតេទម្ងន់នៃការបាត់បង់ឥណទាន។ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានការថយចុះតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះ សាច់ប្រាក់ទាំងអស់ (ពោលគឺភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដែលជំពាក់ធនាគារស្របតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែល ធនាគាររំពឹង ទុកថានឹងទទួលបាន)។

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការថយចុះតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃដុល និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលរំពឹងទុកនាពេលអនាគត។
  មានវិធីសាស្ត្រពីរ ដែលត្រូវបានកំណត់សម្រាប់ការគណនា ECL៖

- ភាពជឿនលឿន៖ វិធីសាស្ត្រ PD / LGD ។ ជារៀងរាល់ឆ្នាំពេញមួយអាយុកាលរបស់ឧបករណ៍ហិរញ្ញវត្ថុការប៉ាន់ស្មាន PD. LGD និង EAD ត្រូវបានប៉ាន់ប្រមាណ។ ការប៉ាន់ស្មានត្រូវបានគុណនឹងគ្នាដើម្បីប៉ាន់ប្រមាណការខាតបង់សម្រាប់ឆ្នាំនីមួយៗ។បន្ទាប់មក បន្ទាប់មកការប៉ាន់ប្រមាណត្រូវបានបញ្ចុះត្រឡប់ទៅកាលបរិច្ឆេទរាយការណ៍ដោយប្រើអត្រា EIR ឬប្រូក ស៊ីដែលជាអត្រាបញ្ចុះតម្លៃ

- សាមញ្ញ៖ វិធីសាស្ត្រភាគរយ ECL។ អាចមានករណីលើកលែងក្នុងករណីផលប័ត្រមួយចំនួនដូចជាប្រាក់បញ្ញើនិងការដាក់។ ដោយពិចារណាលើអាយុកាលដែលរំពឹងទុកគុណភាពឥណទានរបស់អ្នករួមផ្សំនៃទ្រព្យសម្បត្តិទាំងនេះវិធីសាស្ត្រភាគរយ ECL នឹងត្រូវ បានប្រើ។

  ធនាគារគណនា ECL ដោយប្រើតម្លៃយោងដុលនៃទ្រព្យសកម្មគុណនឹងអត្រាប្រូបាប៊ីលីតេនៃការខកខានក្នុងការសង (PD) សរុបនៃដំណាក់កាលនីមួយៗជាមួយនឹងកត្តាសម្របសម្រួលហានិភ័យ។

- ការខាតបង់ឥណទានដែលរំពឹងទុក ECL គឺជាតម្លៃបច្ចុប្បន្ននៃសាច់ប្រាក់លើអាយុកាលដែលនៅសល់ ធ្វើអប្បហារនៅ EIR។ នៅឆ្នាំនីមួយៗក្នុងអាយុកាលឧបករណ៍ហិរញ្ញវត្ថុ ការព្យាករណ៍នាពេលអនាគតនៃ PD LGD និង EAD ត្រូវបានធ្វើការប៉ាន់ស្មាន។ ការប៉ាន់ស្មានទាំងនេះត្រូវបានគុណនឹងគ្នាដើម្បីស្មានការខាតបង់នៃឆ្នាំនីមួយៗ។ បន្ទប់មកការស្មានទាំងនេះត្រូវបានធ្វើការអប្បហារទៅរកកាលបរិច្ឆេទរាយការណ៍ដោយប្រើ EIR ជាអត្រាអប្បហារ។

- ធនាគារប្រើឥណទានសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម (SME) និងឥណទានគេហដ្ឋានម៉ូដែលក្នុងគណនា ព្រោះពួកវាមានលក្ខណៈដូចគ្នាច្រើន។ ពួកវាទាំងនេះជាឥណទានមានកាលកំណត់ជាមួយកាលកំណត់ដែលបានកំណត់ទុកមុន និងការវិភាគសងប្រាក់ដែលបានគណនាទុករបស់ប្រាក់ដើម និងការប្រាក់។

- ECL តំណាងត្រូវបានគណនាដោយប្រើរូបមន្តដូចខាងក្រោម៖

ដំណាក់កាល	ការគណនា ECL តំណាង
1	តម្លៃយោងដុល_(ដំណាក់កាលទី1)×អត្រាអាចទទួលបានវិញ_(ដំណាក់កាលទី1) × ការសម្របសម្រួលហានិភ័យ_(ដំណាក់កាលទី1)
2	តម្លៃយោងដុល_(ដំណាក់កាលទី2)×អត្រាអាចទទួលបានវិញ_(ដំណាក់កាលទី2) × ការសម្របសម្រួលហានិភ័យ_(ដំណាក់កាលទី2)
3	តម្លៃយោងដុល_(ដំណាក់កាលទី3)×អត្រាអាចទទួលបានវិញ_(ដំណាក់កាលទី3) × ការសម្របសម្រួលហានិភ័យ_(ដំណាក់កាលទី3)

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.៣ ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL(ត)

ក) សមាសធាតុ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃការថយចុះតម្លៃ (ត)

អត្រាអាចទទួលបានវិញរួមមាន PD and LGD ដែល PD ស្ពាន ទទួលបានពី %ECL សម្ព័ន្ធធនាគារ។ PD ស្ពានគឺគណនាដោយប្រើរូបមន្តខាងក្រោម៖

PD ស្ពាន = ចំនួន ECL / (EAD x LGD%)
ដែលចំនួន ECL គណនាដោយសម្ព័ន្ធធនាគារដោយគិតបញ្ចូលតម្លៃពេលវេលានៃសាច់ប្រាក់។

ខ) សំវិធានធនខាតបង់

តារាងខាងក្រោមសង្ខេបអំពីសំវិធានធនខាតបង់ គិតត្រឹមការិយបរិច្ឆេទបញ្ចប់ឆ្នាំតាមថ្នាក់នៃ ការខកខាន/ទ្រព្យសកម្ម។

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សំវិធានធនខាតបង់តាមថ្នាក់				
សមតុល្យជាមួយធនាគារនានា	12,801	52,164	321,231	1,290,706
ឥណទានផ្តល់ដល់អតិថិជន	890	3,627	510	2,049
	13,691	55,791	321,741	1,292,755

នៅក្រោមនិតិវិធីត្រួតពិនិត្យរបស់ធនាគារ ការកើនឡើងជាសារវន្តនៃហានិភ័យឥណទានត្រូវបានកំណត់មុនពេលវាត្រូវបានខកខាន និងយ៉ាងយឺតបំផុតនៅពេលទ្រព្យសកម្មផុតកំណត់រយៈពេល 30 ថ្ងៃ។ ករណីនេះកើតឡើងជាពិសេសសម្រាប់ឥណទានផ្តល់ដល់អតិថិជន។ តារាងខាងក្រោមបង្ហាញអំពីការវិភាគនៃតម្លៃយោងដុលរបស់ឥណទានផ្តល់ដល់អតិថិជនគិតតាមថ្នាក់នៃថ្ងៃផុតការកំណត់សង។

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	តម្លៃយោងដុល	សំវិធានធន ខាតបង់	តម្លៃយោងដុល	សំវិធានធន ខាតបង់
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ឥណទានផ្តល់ដល់អតិថិជន				
0 – 29 ថ្ងៃ	77,745,930	(890)	44,011,704	(510)
គិតជាពាន់រៀល	316,814,665	(3,627)	176,839,027	(2,049)

២៨. ប្រតិបត្តការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.៤ ការផ្តោតលើហានិភ័យឥណទាន

ធនាគារបានធ្វើការត្រួតពិនិត្យការផ្តោតលើហានិភ័យឥណទានតាមវិស័យនីមួយៗ។ ការវិភាគការផ្តោតលើហានិភ័យឥណទានផ្តល់ដល់អតិថិជន ត្រូវបានបង្ហាញនៅក្នុងតារាងដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
តម្លៃយោង	77,745,040	316,811,038	44,011,194	176,836,977	33,608,083	135,675,831
ការផ្តោតលើហានិភ័យតាមវិស័យ						
កម្ចីផ្ទាល់ខ្លួន	11,104,226	45,249,719	26,138,241	105,023,453	21,310,421	86,030,169
ការសាងសង់	19,826,455	80,792,806	7,096,142	28,512,298	3,223,916	13,014,947
សកម្មភាព អចលនទ្រព្យ	9,397,622	38,295,309	5,455,659	21,920,838	5,240,313	21,155,145
ការជួញដូរលក់រាយ	9,000,446	36,676,816	3,143,830	12,631,910	1,629,479	6,578,205
សណ្ឋាគារ និងភោជនីយដ្ឋាន	1,008,103	4,108,019	759,204	3,050,480	128,082	517,066
ការជួញដូរលក់ដុំ	1,773,110	7,225,422	516,445	2,075,077	205,433	829,334
ការដឹកជញ្ជូននិងរក្សាទុក	693,723	2,826,923	334,234	1,342,952	93,375	376,957
កសិកម្ម	577,021	2,351,361	265,367	1,066,244	1,313,993	5,304,589
សកម្មភាពប្រតិបត្តិការជួល	1,731,463	7,055,710	188,305	756,611	203,518	821,602
សកម្មភាពមិនមែនសេវាកម្មហិរញ្ញវត្ថុផ្សេងៗ	22,587,195	92,042,820	113,767	457,114	222,263	897,276
ទឹក-ភ្លើង	45,676	186,133	-	-	37,290	150,541
	77,745,040	316,811,038	44,011,194	176,836,977	33,608,083	135,675,831

២៨. ប្រតបត្តការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.៥ ការប្រៀបធៀបគិតត្រឹមថ្ងៃទី 31 ខែ 2017 ក្រោម IAS 39

ក).ការគ្រប់គ្រងហានិភ័យឥណទាន
ធនាគារបានបង្កើតគោលការណ៍ហានិភ័យឥណទានស្នូល (Core Credit Risk Policy) ដែលរៀបចំឡើងដើម្បីអភិបាលសកម្មភាពក្នុងការគ្រប់គ្រងហានិភ័យ។ ការបន្តឥណទានត្រូវបានអភិបាលដោយកម្មវិធីឥណទាន ដែលបានរៀបចំគម្រោងសម្រាប់ផលិតផល ឬសំពៀតឥណទានពិសេស រាប់ទាំងទីផ្សារគោលដៅ កាលកំណត់ និងលក្ខខណ្ឌ ឯកសារសម្អាង និងនីតិវិធីនៅក្រោមផលិតផលឥណទានដែលនឹងត្រូវបានវាស់វែង និងផ្តល់ឲ្យ។

អត្រាហានិភ័យត្រូវបានត្រួតពិនិត្យនិងធ្វើបច្ចុប្បន្នកម្មតាមមូលដ្ឋានប្រចាំឆ្នាំ និងនៅក្នុងហេតុការណ៍ផ្សេងៗ ដូចជា (i) មានការផ្លាស់ប្តូររយៈពេល និងលក្ខខណ្ឌឥណទាន រួមទាំងការពន្យារឥណទាន (ii) ការសងប្រាក់មិន ទៀងទាត់ឬការខកខានមិនបានសងប្រាក់ និង (iii) ព័ត៌មាន ឬប្រតិបត្តិការមិនល្អពាក់ព័ន្ធនឹងអ្នកខ្ចីប្រាក់។

ខ) ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍បន្ថយហានិភ័យ
ធនាគារធ្វើប្រតិបត្តិការ និងផ្តល់ឥណទានទៅឲ្យឯកត្តជន ឬសហគ្រាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារគ្រប់គ្រងកម្រិត និងត្រួតពិនិត្យការប្រមូលផ្តុំហានិភ័យឥណទាន នៅពេលដែលវាត្រូវបានគេរកឃើញ។ ធនាគារជាតិនៃកម្ពុជាបានកំណត់និយមន័យហានិភ័យធំ ថាជាហានិភ័យឥណទានទូទៅចំពោះអ្នកទទួលផលជាឯកត្តបុគ្គលដែលលើសពី 10% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

យោងតាមលក្ខខណ្ឌនៃប្រកាសលេខ ធ7-06-226 ប្រ.ក. របស់ធនាគារជាតិនៃកម្ពុជា ធនាគារចាំបាច់ត្រូវរក្សាគ្រប់ពេលវេលានូវអនុបាតអតិបរមាចំនួន 20% រវាងហានិភ័យឥណទានទូទៅរបស់ធនាគារធៀបនឹងអ្នកទទួលផលឯកត្តជនណាមួយ និងមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។ ហានិភ័យឥណទានធំៗសរុប មិនត្រូវលើសពី 300% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារទេ។

ធនាគារប្រើប្រាស់គោលការណ៍និងការអនុវត្តជាច្រើន ដើម្បីកាត់បន្ថយហានិភ័យឥណទាន។ គោលការណ៍ដែលមានប្រសិទ្ធភាពបំផុតក្នុងចំណោមគោលការណ៍ទាំងអស់នេះ គឺការធានាដោយការដាក់វត្ថុបញ្ចាំ ចំពោះ ឥណទានអតិថិជនដែលជាការអនុវត្តទូទៅមួយ។ ធនាគារអនុវត្តគោលការណ៍ស្តីពីការទទួលយកបាននូវចំណាត់ថ្នាក់ជាក់លាក់នៃវត្ថុបញ្ចាំ ឬការបន្ថយហានិភ័យឥណទាន។ ប្រភេទនៃវត្ថុបញ្ចាំសំខាន់ៗ ដើម្បីធានាឥណទានផ្តល់ដល់អតិថិជនមានដូចជាវត្ថុបញ្ចាំលើទ្រព្យសម្រាប់តាំងទីលំនៅ(មានដីធ្លីអគារ និងទ្រព្យផ្សេងៗ)។

គ) គោលការណ៍សំវិធានធន និងឱនភាព
វិធីសាស្ត្រឱនភាពរបស់ធនាគារសម្រាប់ទ្រព្យសកម្មនៅតាមតម្លៃដករំលស់រួមមាន៖

- ការខាតបង់ឱនភាពជាក់លាក់សម្រាប់ការខកខានក្នុងការសងជាសារវន្តនីមួយៗ ឬសារវន្តជាការកំណត់ជាក់លាក់
- ឱនភាពរួមនៃការខកខានក្នុងការសងនីមួយៗ ឬការខកខានក្នុងការសងជាសារវន្ត

ការខាតបង់ឱនភាពជាក់លាក់សម្រាប់ការខកខានក្នុងការសងជាសារវន្តនីមួយៗ ឬសារវន្តជាការកំណត់ជាក់លាក់

សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុនៅតម្លៃដករំលស់ (ដូចជា សាច់ប្រាក់ពីធនាគារ និងឥណទានផ្តល់ដល់ អតិថិជន) ធនាគារធ្វើការត្រួតពិនិត្យថាតើគោងបំណងវត្ថុតាងនៃឱនភាពកើតមានសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលជាសារវន្តដោយឡែក ឬជាការងារជាក់លាក់តាមគណៈគ្រប់គ្រង។

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.៥ ការប្រៀបធៀបគិតត្រឹមថ្ងៃទី 31 ខែ 2017 ក្រោម IAS 39

គ) គោលការណ៍សំវិធានធន និងឱនភាព (ត)

វាជាគោលការណ៍របស់ធនាគារដើម្បីតាមដានប្រភេទឥណទាន។ ការកំណត់បង្ហាញឱនភាពរួមមានៈ អត្រាខ្ទីផ្ទៃក្នុងបង្ហាញពីដល់កំណត់ ឬជិតដល់កំណត់ អ្នកខ្ចីស្នើឲ្យមានមូលនិធិអាសន្នពីធនាគារ អ្នកខ្ចីមានបំណុលទៅម្ចាស់បំណុលសាធារណៈ ឬបុគ្គលិក ការថយចុះជាសារវន្តនៃតម្លៃទ្រព្យតម្កល់ដែលការលក់នៃទ្រព្យសកម្មហិរញ្ញវត្ថុតម្រូវឲ្យសងឥណទាន ការថយចុះជាសារវន្តនៃផលទទួលបានរបស់ អ្នកខ្ចីឬអតិថិជនសំខាន់ ការថយចុះជាសារវន្តនៃការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់ថ្ងៃអនាគត ហ្វាស៊ីលីធីជាសារវន្តរបស់ម្ចាស់បំណុលធ្លាប់លើសកាលកំណត់ 90 ថ្ងៃ ការមិនលើកលែងពីធនាគារ ម្ចាស់បំណុល (ឬ អង្គភាពស្របច្បាប់ក្នុងក្រុមម្ចាស់បំណុល) ដាក់ឯកសារ/ការពារសម្រាប់ក្ស័យធន និង/ឬ បំណុលឬមូលធនរបស់ម្ចាស់បំណុលផ្អាកនៅពេលប្តូរដំបូង ព្រោះពាក្យចរចាមអារ៉ាម ឬការពិតអំពីការលំបាកហិរញ្ញវត្ថុ។ ប្រសិនមានវត្ថុតាងដែលបង្ហាញពីការខាតបង់ឱនភាពដែលបានកើតឡើង ចំនួននៃការខាតបង់វាស់វែងតាមភាពខុសគ្នានៃតម្លៃយោងនៃទ្រព្យសកម្ម និងតម្លៃបច្ចុប្បន្ននៃប៉ាន់ស្មានសាច់ប្រាក់ថ្ងៃអនាគត (មិនរួមបញ្ចូលការខាតបង់ឥណទានដែលមិនទាន់កើតមាន)។ តម្លៃយោងនៃទ្រព្យសកម្មត្រូវបានកាត់បន្ថយតាមការប្រើនៃគណនី សំវិធានធន និងចំនួននៃការខាតបង់ត្រូវបានទទួលស្គាល់ក្នុងចំណាយឥណទានខាតបង់នៅក្នុងរបាយការណ៍ចំណេញឬខាត និងរបាយការណ៍ចំណូលលម្អិត។ ចំណូលការប្រាក់បន្តឲ្យបង្ករនៅតាមការកាត់បន្ថយតម្លៃយោង និងត្រូវបង្ករដោយប្រើអត្រាការប្រាក់សម្រាប់អប្បហារសាច់ប្រាក់ថ្ងៃអនាគត ក្នុងគោលបំណងវាស់វែងសំវិធានធនខាត បង់។ ចំណូលការប្រាក់ត្រូវបានកត់ត្រាជាផ្នែកនៃការប្រាក់និងចំណូលប្រហែលនេះ។

ឥណទានរួមនឹងសំវិធានធនពាក់ព័ន្ធត្រូវបានលុបចោល នៅពេលមិនមានភាពជាក់លាក់ក្នុងការប្រមូលវិញ និងទ្រព្យតម្កល់ត្រូវបានទទួលស្គាល់ ឬត្រូវបានផ្ទេរទៅធនាគារ។ ប្រសិននៅឆ្នាំបន្ទាប់ ចំនួននៃការប៉ាន់ស្មានការខាតបង់ឱនភាពកើនឡើង ឬថយចុះ ព្រោះហេតុការណ៍កើតឡើងក្រោយឱនភាពត្រូវបានទទួលស្គាល់ មិនទទួលស្គាល់ការខាតបង់ឱនភាពកើនឬថយ (ប៉ុន្តែត្រឹមតម្លៃយោងមានឱនភាពមិនទាន់ទទួលស្គាល់) ដោយសម្រួលគណនី សំវិធានធន។ ប្រសិនការលុបចោល ក្រោយមកអាចប្រមូលបានវិញ ការប្រមូលមកវិញត្រូវបានគិតចូលទៅ "ចំណាយឥណទានខាតបង់"។

តម្លៃបច្ចុប្បន្ននៃការប៉ានស្មានលំហូរសាច់ប្រាក់ថ្ងៃអនាគតត្រូវបានធ្វើអប្បហារដោយ EIR ដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ការគណនានៃតម្លៃបច្ចុប្បន្ននៃការប៉ានស្មានលំហូរសាច់ប្រាក់ថ្ងៃអនាគតនៃទ្រព្យសកម្មហិរញ្ញវត្ថុមានទ្រព្យតម្កល់បង្ហាញលំហូរសាច់ប្រាក់ដែលកើតពីរឹបអូស ដកតម្លៃទទួលនិងលក់ទ្រព្យតម្កល់ ទោះការរឹបអូសអាចឬមិនអាច។

ឱនភាពរួមនៃការខកខានក្នុងការសងនីមួយៗ ឬការខកខានក្នុងការសងជាសារវន្ត

ប្រភេទទាំងនេះត្រូវបានចាត់ថ្នាក់ឡើងវិញទៅតាមផ្នែកផ្សេងៗគ្នា តាមភាពដូចគ្នានៃលក្ខណៈនៃហានិភ័យឥណទាន ដោយប្រើប្រភពនៃចំណូលជាគោលវិនិច្ឆ័យ និងប្រើប្រូបាប៊ីលីតេនៃការខកខាន (PD) មធ្យមធម្មតា និង ការខាតបង់នៃការខកខានក្នុងការសង (LGD) សម្រាប់រយៈពេលចុងក្រោយចាប់តាំងពីខែ តុលា ឆ្នាំ 2013 (ថ្ងៃនៃការបង្កើតឡើង)។ ជាទូទៅ ឱនភាពនៅក្នុងប្រភេទទាំងនេះធ្វើឲ្យកើតមានឡើង នៅពេលវាដល់កម្រិតដែលបានកំណត់ទុក (ឧទាហរណ៍ អ្នកខ្ចីៈហួសកាលកំណត់សង 90 ថ្ងៃនៃកិច្ចសន្យា (សាច់ប្រាក់ដើម ឬការប្រាក់)។

លំហូរសាច់ប្រាក់ថ្ងៃអនាគតរបស់ក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលវិភាគរួមសម្រាប់ឱនភាព ដែលសន្មតទៅតាមប្រវត្តិនៃការខាតបង់សម្រាប់ទ្រព្យសកម្មជាមួយលក្ខណៈហានិភ័យឥណទានដែលដូចគ្នានឹងក្រុម។ ប្រវត្តិនៃការខាតបង់គឺសម្រួលទៅតាមទិន្នន័យដែលអាច ពិនិត្យបាននៅបច្ចុប្បន្នដើម្បីបង្ហាញពីផលនៃលក្ខណៈបច្ចុប្បន្ន ដែលប្រវត្តិនៃការខាតបង់ផ្អែកទៅលើ និងដើម្បីដកចេញនូវផលនៃលក្ខណៈពេលអតីតដែលមិនបានកើតមាន។

ការសន្មតនៃការប្រែប្រួលរបស់លំហូរសាច់ប្រាក់នាពេលអនាគតដែលបង្ហាញ និងស្របតាមការប្រែប្រួលដែលពាក់ព័ន្ធទិន្នន័យត្រួតពិនិត្យពីមួយពេលទៅមួយពេល (ដូចជាការប្រែប្រួលនៃអត្រាមិនមានការងារធ្វើ បំណុលឯកជន តម្លៃទ្រព្យតម្កល់ រួមមានតម្លៃទ្រព្យសម្រាប់បញ្ចាំ តម្លៃក្នុងស្រុក ការបង់ប្រាក់ ឬកត្តាដែលជាការបង្ហាញការខាតបង់ក្នុងក្រុម និងកម្រិតរបស់វា)។ មធ្យោបាយ និងការសន្មតត្រូវបានប្រើសម្រាប់ការសន្មតលំហូរសាច់ប្រាក់ថ្ងៃអនាគតដែលត្រួតពិនិត្យជាប្រចាំដើម្បីកាត់បន្ថយភាពខុសគ្នា។

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.៥ ការប្រៀបធៀបគិតត្រឹមថ្ងៃទី 31 ខែ 2017 ក្រោម IAS 39

ឃ) ការខកខានជាអតិបរមានៃហានិភ័យឥណទានមុនពេលដាក់ទ្រព្យបញ្ចាំ ឬការជំរុញឥណទានផ្សេងៗ

	ថ្ងៃទី 31 ខែ ធ្នូ 2017	
	ដុល្លារអាមេរិក	ពាន់រៀល
ហានិភ័យឥណទានការខកខានក្នុងការសងពាក់ព័ន្ធទៅនឹងតារាងតុល្យការទ្រព្យសកម្ម៖		
សមតុល្យជាមួយធនាគារនានា	125,234	505,570
ឥណទានផ្តល់អតិថិជន	33,608,083	135,675,831
	33,733,317	136,181,401

តារាងខាងលើបង្ហាញពីស៊ីណារីយ៉ូអាក្រក់បំផុតនៃហានិភ័យឥណទានការខកខានក្នុងការសង ទៅធនាគារនៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 ដោយមិនរួមបញ្ចូលទ្រព្យតម្កល់ ឬភ្ជាប់ជាមួយឥណទានហានិភ័យផ្សេងៗ។ សម្រាប់លើតារាង តុល្យកាលទ្រព្យសកម្ម ការខកខានក្នុងការសងត្រូវបានបង្ហាញជាតម្លៃយោងសុទ្ធ។

ដូចដែលបានបង្ហាញខាងលើ 99% នៃការខកខានក្នុងការសងសរុបជាអតិប្បមាដែលបានមកពីឥណទាន ផ្តល់ដល់អតិថិជន។

គណៈគ្រប់គ្រងមានការជឿជាក់ក្នុងលទ្ធភាពក្នុងការបន្តគ្រប់គ្រង និងរក្សាការខកខានក្នុងការសងជា អប្បបរមានៃហានិភ័យឥណទានទៅធនាគារដែលបានមកពីឥណទានផ្តល់ដល់អតិថិជនដូចខាងក្រោម៖

- ប្រហែលជា 93% នៃឥណទានផ្តល់ដល់អតិថិជនរបស់ធនាគារមានទ្រព្យតម្កល់។ ឥណទានផ្តល់ដល់អតិថិជនត្រូវបានផ្តល់ឲ្យអតិថិជនមិនលើពី 60% នៃតម្លៃរបស់ទ្រព្យតម្កល់។
- ធនាគាររក្សានូវការវិភាគឥណទានតឹងរឹងក្នុងការផ្តល់ឥណទានដល់អតិថិជន។

ង) ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជនត្រូវបានសង្ខេបដូចខាងក្រោម៖

	ថ្ងៃទី 31 ខែ ធ្នូ 2017	
	ដុល្លារអាមេរិក	ពាន់រៀល
ឥណទានផ្តល់ដល់អតិថិជនដែលមិនហួសកាលកំណត់សងឬខាតបង់	33,948,838	137,051,459
ឥណទាន និងការប្រាក់នឹងទទួលបានដុលសរុប	33,948,838	137,051,459
សំវិធានធនសម្រាប់ឥណទានអាក្រក់ និងសង្ស័យ	(340,755)	(1,375,628)
ឥណទានផ្តល់ដល់អតិថិជនសុទ្ធ	33,608,083	135,675,831

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.១ ហានិភ័យឥណទាន(ត)

២៨.១.៥ ការប្រៀបធៀបគិតត្រឹមថ្ងៃទី 31 ខែ 2017 ក្រោម IAS 39

ង) ឥណទានផ្តល់ដល់អតិថិជន (ត)

i).ឥណទានផ្តល់ដល់អតិថិជនដែលមិនហួសកាលកំណត់សងឬខាតបង់

ឥណទានផ្តល់ដល់អតិថិជនដែលមិនហួសកាលកំណត់សងឬខាតបង់ លើកលែងតែមានព័ត៌មានដែលបង្ហាញផ្សេងពីនេះ។

ii).ឥណទានផ្តល់ដល់អតិថិជនដែលហួសកាលកំណត់សង តែមិនខាតបង់

ឥណទានផ្តល់ដល់អតិថិជនដែលហួសកាលកំណត់សងតិចជាង 90 ថ្ងៃ មិនចាត់ទុកថាខាតបង់ទេ លើកលែងតែមានមានព័ត៌មានដែលបង្ហាញផ្សេងពីនេះ។ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 ឥណទានផ្តល់ដល់អតិថិជនមិនមានចំនួនដុលដែលហួសកាលកំណត់សងតែមិនខាតបង់នោះទេ។

iii).ឥណទានខាតបង់រៀងៗខ្លួន

ឥណទានផ្តល់ដល់អតិថិជនដែលហួសកាលកំណត់សង 90 ថ្ងៃ ឬច្រើនជាង ត្រូវបានចាត់ទុកថាជាចំនុចកាត់ ផ្តាច់ ឬជាចំនុចដែលមិនអាចត្រលប់បានដោយផ្អែកលើទិន្នន័យប្រវត្តិនៃការហួសកំណត់សងឥណទាន និងការ ប្រមូល។ ទាំងនេះ គឺនៅពេលត្រូវបានកំណត់ 100% ប្រូបាប៊ីលីតេនៃការខកខាន។

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 មិនមានឥណទានដែលហួសកាលកំណត់សង និងមិនខាតបង់នោះទេ។

ច).ទ្រព្យតម្កល់កាន់កាប់ឡើងវិញ

នៅក្នុងឆ្នាំ ធនាគារមិនមានទទួលនូវកាន់កាប់នៃទ្រព្យតម្កល់ជាសន្តិសុខទេ។

ទ្រព្យតម្កល់កាន់កាប់ឡើងវិញតម្រូវឲ្យលក់ក្នុងរយៈពេលមួយឆ្នាំដោយធនាគារជាតិនៃកម្ពុជា។ ទ្រព្យតម្កល់កាន់កាប់ឡើងវិញត្រូវចាត់ថ្នាក់នៅក្នុងតារាងតុល្យការជាទ្រព្យរបស់ បើមាន។

ឆ) ការផ្តោតលើទ្រព្យសកម្មហិរញ្ញវត្ថុយជាមួយការប្រឈមនឹងហានិភ័យឥណទាន

វិស័យភូមិសាស្ត្រ

ធនាគារប្រតិបត្តិការតែនៅប្រទេសកម្ពុជា ដូច្នេះវាមិនមានការប្រឈមឥណទានដោយតំបន់ភូមិសាស្ត្រគិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017។

២៨.២ ហានិភ័យសន្ទនីយភាព

ហានិភ័យសន្ទនីយភាពសំដៅទៅលើហានិភ័យដែលក្រុមហ៊ុនមិនអាចបំពេញកាតព្វកិច្ចហិរញ្ញវត្ថុ ឬមិនអាច សងបំណុល ឬដោះស្រាយជំហរ ក្នុងស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាក់លាក់ និងស្ថានភាពទីផ្សារ។ ហានិភ័យ សន្ទនីយភាពកើតឡើងពីភាពមិនត្រូវគ្នានៃកាលកំណត់ និងបរិមាណលំហូរសាច់ប្រាក់ ដែលមានជាប់ជាមួយប្រតិបត្តិការ និងការវិនិយោគរបស់ធនាគារ។

២៨.២.១ ការគ្រប់គ្រងហានិភ័យសន្ទនីយភាព

ធនាគារបានបង្កើតគោលនយោបាយនិងក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយសម្រាប់គ្រប់គ្រងហានិភ័យ សាច់ប្រាក់ងាយរងគ្រោះ។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្មនិងបំណុលរបស់សម្ព័ន្ធក្រុមហ៊ុន (ALCO) ទទួលខុសត្រូវក្នុងការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួលរបស់ធនាគារ តាមរយៈការរួមបញ្ចូលគ្នានៃការបង្កើតគោលនយោបាយការពិនិត្យឡើងវិញ និងអភិបាលកិច្ចការវិភាគការធ្វើតេស្តស្ត្រេសការកម្រិតនិងការត្រួតពិនិត្យ។ ដើម្បីគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយរងគ្រោះធនាគារ៖

- រក្សាផលប័ត្រទ្រព្យសកម្មដែលអាចដូរយកប្រាក់បានដែលមានកំរិតខ្ពស់ក្នុងរូបិយប័ណ្ណនិងភតិសន្យា
- ធានាថាមានភាពចម្រុះនៅក្នុងមូលដ្ឋានមូលនិធិរបស់ខ្លួន
- តាមដានលក្ខណៈអាកប្បកិរិយានៃទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុ
- តាមដានរបាយការណ៍សាច់ប្រាក់ងាយស្រួលដោយវិភាគលើទម្រង់កាលកំណត់នៃទ្រព្យសកម្មនិងបំណុល
- បង្កើតសូចនាករព្រមានដំបូងៗ អំពីព្រឹត្តិការណ៍ស្ត្រេសងាយៗងាយៗនិងធានាថាមានទ្រព្យសកម្មដែលអាចប្រើជាវត្ថុបញ្ចាំប្រសិនបើចាំបាច់
- ធ្វើតេស្តស្ត្រេសទៀងទាត់ និង
- រក្សានូវផែនការថវិកាយថាភាពដែលត្រូវបានរៀបចំឡើង ដើម្បីផ្តល់នូវក្របខ័ណ្ឌមួយដែលភាពតានតឹងនៃសាច់ប្រាក់អាចត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.២ ហានិភ័យសន្ទនីយភាព(ត)

២៨.២.១ ការគ្រប់គ្រងហានិភ័យសន្ទនីយភាព (ត)

មុខងារធនាគារអនុវត្តយុទ្ធសាស្ត្រសាច់ប្រាក់ងាយស្រួល និងមូលនិធិរបស់ធនាគារក្នុងការសហប្រតិបត្តិការជាមួយអង្គភាពអាជីវកម្មផ្សេងទៀតរបស់សម្ព័ន្ធក្រុមហ៊ុន។ យុទ្ធសាស្ត្រសាច់ប្រាក់ងាយស្រួលនិងមូលនិធិរបស់ធនាគារត្រូវបានកំណត់ស្របតាមតម្រូវការបទប្បញ្ញត្តិក្នុងស្រុកដែលពាក់ព័ន្ធ។ ប្រតិបត្តិការបរទេសរបស់ធនាគារកំណត់នូវយុទ្ធសាស្ត្រសាច់ប្រាក់ងាយស្រួលក្នុងស្រុកដែលត្រូវការឱ្យស្របទៅនឹងក្របខ័ណ្ឌបទប្បញ្ញត្តិក្នុងស្រុក និងគោលនយោបាយកណ្តាលរបស់ធនាគារ។

មានការត្រួតពិនិត្យប្រចាំថ្ងៃដើម្បីកំណត់និងតាមដានការអះអាងបញ្ជាក់ពីការប្រតិបត្តិហានិភ័យសន្ទនីយភាពតាមចំណង់របស់ធនាគារ។ ឆន្ទៈលក្ខណៈគោលដែលប្រើគឺជាលទ្ធផលនៃការធ្វើស្ត្រេសតេស្តរបស់ធនាគារជម្រុញដោយ លទ្ធផលនៃកត្តាអនុបាតក្របខ័ណ្ឌរួមមានទំហំអនុបាតសន្ទនីយភាព (ដែលវាស់វែងគុណភាពអនុបាតសន្ទនីយភាពនៃសាច់ប្រាក់ងាយស្រួលមានគុណភាពខ្ពស់ទៅខាងក្រៅនៅក្នុងកំឡុងពេល៣០ថ្ងៃទិដ្ឋភាពស្ត្រេស) និងសមាមាត្រស្ថេរភាពមូលនិធិ (ដែលស្វែងរកដើម្បីបង្កើនភាពឋិតថេរនៃកាលកំណត់រចនាសម្ព័ន្ធរបស់សមតុល្យថវិកា។

ការធ្វើស្ត្រេសតេស្តសន្ទនីយភាព ត្រូវបានធ្វើឡើងនៅក្រោមទិដ្ឋភាពផ្សេងៗ ដែលគ្របដណ្តប់ទាំង លក្ខខណ្ឌ ទីផ្សារធម្មតា និងធ្ងន់ធ្ងរ។ ទិដ្ឋភាពត្រូវបានបង្កើតឡើងដោយពិចារណាលើព្រឹត្តិការណ៍ជាក់លាក់របស់ ធនាគារ (ឧទាហរណ៍ ការបន្ទាបចំណាត់ថ្នាក់) និងព្រឹត្តិការណ៍ទាក់ទងនឹងទីផ្សារ (ឧទាហរណ៍ ភាពមិនច្បាស់លាស់ លើទីផ្សារ ការកាត់បន្ថយរូបិយប័ណ្ណ គ្រោះមហន្តរាយធម្មជាតិ ឬគ្រោះមហន្តរាយផ្សេងៗទៀត)។ លើសពីនេះទៀត ទិដ្ឋភាពភាពតានតឹង អាចផ្អែកលើព្រឹត្តិការណ៍នាពេលកន្លងមក (historical scenario) ដែលបានកត់សម្គាល់ ចំពោះ ស្ថាប័នផ្ទាល់ ឬទូទៅ លើស្ថានភាពវិបត្តិសេដ្ឋកិច្ចដែលត្រូវបានអង្កេតដោយស្ថាប័នផ្សេងទៀត ដែលមានទំហំ ម៉ូឌែល និងតំបន់អាជីវកម្មស្រដៀងគ្នា។ ជាញឹកញាប់ ធនាគារក៏បានបញ្ចូលធាតុនៃវិបត្តិនានាពីព្រឹត្តិការណ៍នាពេលកន្លងមក ដើម្បីបង្កើតជាសម្មតិកម្ម ប៉ុន្តែជាទិដ្ឋភាពវិបត្តិដែលអាចជឿជាក់បាន ដែលសមស្របទៅនឹងម៉ូឌែល អាជីវកម្ម និងទម្រង់ការប៉ះពាល់បច្ចុប្បន្នរបស់ធនាគារ ។

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.២ ហានិភ័យសន្ទនីយភាព(ត)

២៨.២.២ ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ

តារាងខាងក្រោមបង្ហាញពីអាយុកាលទៅតាមកិច្ចសន្យាជាក់ស្តែងដែលនៅសល់ នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ធនាគារ។

	តម្លៃយោង	រហូតដល់ ១ខែ	> 1 – 3ខែ	> 3 – 12ខែ	> 1 – 5ឆ្នាំ	លើសពី 5ឆ្នាំ	មិនមានអាយុកាល
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019							
បំណុលហិរញ្ញវត្ថុតាមប្រភេទ							
បំណុលមិនមែននិស្សន្ទ							
ប្រាក់បញ្ញើរបស់អតិថិជន	26,220,095	4,335,094	1,090,479	19,622,621	873	1,171,029	0
បំណុលភតិសន្យា	1,644,788	26,534	53,424	246,398	928,036	390,395	-
បំណុលផ្សេងៗ	112,737	112,737	-	-	-	-	-
បំណុលហិរញ្ញវត្ថុតាមប្រភេទសរុប	27,977,620	2,770,914	549,051	19,311,844	707,730	1,415,953	2,499,953
សមមូលជាពាន់រៀល	114,008,801	11,291,476	2,237,384	78,695,763	2,883,998	5,770,009	10,187,309
ទ្រព្យសកម្មហិរញ្ញវត្ថុតាមប្រភេទ							
ទ្រព្យសកម្មមិនមែននិស្សន្ទ							
សាច់ប្រាក់ក្នុងដៃ	2,844,371	-	-	-	-	-	2,844,371
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	19,045,026	8,523,729	-	-	3,000,880	7,520,417	-
សមតុល្យនៅធនាគារនានា	608,585	608,585	-	-	-	-	-
ឥណទានផ្តល់ដល់អតិថិជន	77,745,040	-	-	-	5,536,427	72,208,613	-
ទ្រព្យសកម្មផ្សេងៗ	174,714	-	-	-	-	-	174,714
ទ្រព្យសកម្មហិរញ្ញវត្ថុតាមប្រភេទសរុប	100,417,735	9,132,314	-	-	8,537,307	79,729,030	3,019,085
សមមូលជាពាន់រៀល	409,202,272	37,214,179	-	-	34,789,527	324,895,795	12,302,771

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.២ ហានិភ័យសន្ទនីយភាព(ត)

២៨.២.២ ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ

តារាងខាងក្រោមបង្ហាញពីអាយុកាលទៅតាមកិច្ចសន្យាជាក់ស្តែងដែលនៅសល់ នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ធនាគារ។

	តម្លៃយោង	រហូតដល់ ១ខែ	> 1 – 3ខែ	> 3 – 12ខែ	> 1 – 5ឆ្នាំ	លើសពី 5ឆ្នាំ	មិនមានអាយុកាល
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018							
បំណុលហិរញ្ញវត្ថុតាមប្រភេទ							
បំណុលមិនមែននិស្សន្ទ							
ប្រាក់បញ្ញើរបស់អតិថិជន	2,435,707	1,749,015	255,062	279,673	5,105	146,851	-
បំណុលភតិសន្យា	-	-	-	-	-	-	-
បំណុលផ្សេងៗ	83,457	83,457	-	-	-	-	-
បំណុលហិរញ្ញវត្ថុតាមប្រភេទសរុប	2,519,164	1,832,472	255,062	279,673	5,105	146,851	-
សមមូលជាពាន់រៀល	10,122,001	7,362,873	1,024,840	1,123,725	20,514	590,048	-
ទ្រព្យសកម្មហិរញ្ញវត្ថុតាមប្រភេទ							
ទ្រព្យសកម្មមិនមែននិស្សន្ទ							
សាច់ប្រាក់ក្នុងដៃ	2,508,273	-	-	-	-	-	2,508,273
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	14,294,434	-	6,434,336	100,000	-	7,523,441	236,657
សមតុល្យនៅធនាគារនានា	15,402,227	-	12,370,506	2,938,200	-	602	92,919
ឥណទានផ្តល់ដល់អតិថិជន	44,011,193	-	6,423	3,315,476	2,897,891	37,791,402	-
ទ្រព្យសកម្មផ្សេងៗ	533,200	-	-	--	-	-	533,200
ទ្រព្យសកម្មហិរញ្ញវត្ថុតាមប្រភេទសរុប	76,749,327	-	18,811,265	6,353,676	2,897,891	45,315,446	3,371,049
សមមូលជាពាន់រៀល	308,378,798	-	75,583,663	25,529,072	11,643,727	182,077,461	13,544,875

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.២ ហានិភ័យសន្ទនីយភាព(ត)

២៨.២.២ ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ(ត)

ការប្រៀបធៀបគិតត្រឹមថ្ងៃទី 31 ខែ 2017 ក្រោម IAS 39

	តម្លៃយោង	រហូតដល់ ១ខែ	> 1 – 3ខែ	> 3 – 12ខែ	> 1 – 5ឆ្នាំ	លើសពី 5ឆ្នាំ	មិនមានអាយុកាល
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017							
បំណុលហិរញ្ញវត្ថុតាមប្រភេទ							
បំណុលមិនមែននិស្សន្ទ							
បំណុលផ្សេងៗ	68,307	-	-	-	-	-	68,307
សមមូលជាពាន់រៀល	275,755	-	-	-	-	-	275,755
ទ្រព្យសកម្មហិរញ្ញវត្ថុតាមប្រភេទ							
ទ្រព្យសកម្មមិនមែននិស្សន្ទ							
សាច់ប្រាក់ក្នុងដៃ	97,295	-	-	-	-	-	97,295
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	40,101,474	32,593,504	-	-	-	-	7,507,970
សមតុល្យនៅធនាគារនានា	125,234	125,234	-	-	-	-	-
ឥណទានផ្តល់ដល់អតិថិជន	33,608,083	-	1,125,221	6,006,352	3,010,182	23,466,328	-
ទ្រព្យសកម្មផ្សេងៗ	24,127	-	-	-	-	-	24,127
ទ្រព្យសកម្មហិរញ្ញវត្ថុតាមប្រភេទសរុប	73,956,213	32,718,738	1,125,221	6,006,352	3,010,182	23,466,328	7,629,392
សមមូលជាពាន់រៀល	298,561,232	132,085,545	4,542,516	24,247,644	12,152,106	94,733,565	30,799,856

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.២ ហានិភ័យសន្ទនីយភាព(ត)

២៨.២.២ ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ចំនួនទឹកប្រាក់ក្នុងតារាងខាងលើត្រូវបានចងក្រងដូចខាងក្រោម៖

ប្រភេទនៃឧបករណ៍ហិរញ្ញវត្ថុ	វិធានដែលបរិមាណត្រូវបានចងក្រង
បំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុមិនមែននិស្សន្ទ	លំហូរសាច់ប្រាក់ពុំបានអប្បហារ ដែលរួមបញ្ចូលនូវការប្រាក់ប៉ាន់ស្មាន ដែលត្រូវទូទាត់

ជាផ្នែកមួយនៃការគ្រប់គ្រងហានិភ័យសន្ទនីយភាពដែលកើតចេញពីបំណុលហិរញ្ញវត្ថុ សម្ព័ន្ធក្រុមហ៊ុនមានទ្រព្យសកម្មដែលអាចប្តូរជាសាច់ប្រាក់ងាយស្រួលបាន រួមមានសាច់ប្រាក់ និងសាច់ប្រាក់សមមូល ដែលមានភាព ងាយស្រួល ក្នុងការបំពេញតាមតម្រូវការ។ លើសពីនេះទៀត ធនាគារបានចុះកិច្ចព្រមព្រៀងលើកម្រិតឥណទានជាមួយធនាគារ ផ្សេងទៀត។

តារាងខាងក្រោមកំណត់ពីតម្លៃតាមកិច្ចសន្យា របស់ទ្រព្យសកម្មហិរញ្ញវត្ថុមិនមែននិស្សន្ទ និងបំណុលហិរញ្ញវត្ថុមិនមែននិស្សន្ទ ដែលរំពឹងថានឹងត្រូវទទួលបាន ឬទូទាត់ក្នុងរយៈពេលតិចជាង១២ខែ គិតចាប់ពីកាលបរិច្ឆេទនៃរបាយការណ៍នេះ។

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្មហិរញ្ញវត្ថុ				
សាច់ប្រាក់ក្នុងដៃ	2,844,371	11,590,812	2,508,273	10,078,241
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	8,523,729	34,734,196	6,770,993	27,205,850
សមតុល្យនៅធនាគារនានា	608,585	2,479,983	15,401,625	61,883,728
ឥណទានផ្តល់ដល់អតិថិជន	-	-	3,321,900	13,347,394
ទ្រព្យសកម្មផ្សេងៗ	174,714	711,960	533,200	2,142,398
	12,151,399	49,516,951	28,535,991	114,657,611
បំណុលហិរញ្ញវត្ថុ				
ប្រាក់បញ្ញើរបស់អតិថិជន	25,048,193	102,071,388	2,283,750	9,176,108
បំណុលភតិសន្យា	326,357	1,329,905	-	-
បំណុលផ្សេងៗ	112,737	459,403	83,457	335,330
	25,487,287	103,860,696	2,367,207	9,511,438

២៨. ប្រតបត្តការ និងសមតុល្យភាគពាក់ព័ន្ធ(ត)

២៨.២ ហានិភ័យសន្ទនីយភាព(ត)

២៨.២.២ ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

តារាងខាងក្រោមកំណត់ពីតម្លៃតាមកិច្ចសន្យា របស់ទ្រព្យសកម្មហិរញ្ញវត្ថុមិនមែននិស្សន្ទ និងបំណុលហិរញ្ញវត្ថុមិនមែននិស្សន្ទ ដែលរំពឹងថានឹងត្រូវទទួលបាន ឬទូទាត់ក្នុងរយៈពេលច្រើនជាង 12 ខែ គិតចាប់ពីកាលបរិច្ឆេទនៃ របាយការណ៍នេះ។

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្មហិរញ្ញវត្ថុ				
សាច់ប្រាក់ក្នុងដៃ	-	-	-	-
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	10,521,297	42,874,285	7,523,441	30,229,186
សមតុល្យនៅធនាគារនានា	-	-	602	2,420
ឥណទានផ្តល់ដល់អតិថិជន	77,745,040	316,811,037	40,689,294	163,489,582
ទ្រព្យសកម្មផ្សេងៗ	-	-	-	-
	88,266,337	359,685,322	48,213,337	193,721,188
បំណុលហិរញ្ញវត្ថុ				
ប្រាក់បញ្ញើរបស់អតិថិជន	1,171,902	4,775,501	151,957	610,562
បំណុលភតិសន្យា	1,318,431	5,372,606	-	-
បំណុលផ្សេងៗ	-	-	-	-
	2,490,333	10,148,107	151,957	610,562

២៨.២.៣ ប្រាក់បម្រុងសន្ទនីយភាព

តារាងខាងក្រោមបង្ហាញពីសមាសធាតុនៃប្រាក់បម្រុងសន្ទនីយភាពរបស់ធនាគារ។

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017	
	តម្លៃយោង	តម្លៃសមស្រប	តម្លៃយោង	តម្លៃសមស្រប	តម្លៃយោង	តម្លៃសមស្រប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
សាច់ប្រាក់ក្នុងដៃ	2,844,371	2,844,371	2,508,273	2,508,273	97,295	97,295
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	19,045,026	19,045,026	14,294,434	14,294,434	40,101,474	40,101,474
សមតុល្យនៅធនាគារនានា	608,585	608,585	15,402,227	15,402,227	125,234	125,234
ប្រាក់បម្រុងសន្ទនីយភាពសរុប	22,497,982	22,497,982	32,204,934	32,204,934	40,324,003	40,324,003
សមមូលជាពាន់រៀល	91,679,277	91,679,277	129,399,425	129,399,425	162,788,000	162,788,000

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.៣ ហានិភ័យទីផ្សារ

"ហានិភ័យទីផ្សារ" គឺជាហានិភ័យដែលផ្លាស់ប្តូរតាមតម្លៃទីផ្សារ (ឧទាហរណ៍ដូចជាអត្រាការប្រាក់ និងអត្រាប្តូរ ប្រាក់បរទេស) ដែលអាច ធ្វើឱ្យប៉ះពាល់ចំណូលរបស់ធនាគារ ឬតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុដែលធនាគារកាន់កាប់។ គោលបំណងនៃការគ្រប់គ្រងហានិភ័យទីផ្សារ គឺធនាគារត្រូវគ្រប់គ្រង និងត្រួតពិនិត្យការប៉ះពាល់នៃហានិភ័យទីផ្សារ នៅក្នុងប៉ារ៉ាម៉ែត្រដែលអាចទទួលយកបាន ដើម្បីធានាបានសាធនភាព ក៏ដូចជាកាត់បន្ថយហានិភ័យរបស់ធនាគារ។

២៨.៣.១ ការគ្រប់គ្រងហានិភ័យទីផ្សារ

សិទ្ធទាំងមូលលើហានិភ័យទីផ្សារគឺវិនិយោគក្នុង ARBC នៅថ្នាក់អភិបាល និង ALRMC ថ្នាក់គ្រប់គ្រង។ ARBC រៀបចំឡើងការកំណត់លើផ្នែកនីមួយនៃហានិភ័យទាំងមូល និងសម្រាប់ប្រភេទ (ប្រភេទទាំងនេះជាប្រភេទមិនមានជួញដូរ)។ ផ្នែកហានិភ័យឥណទាន និងទីផ្សារនៅផ្នែកហានិភ័យទទួលខុសត្រូវសម្រាប់ការអភិវឌ្ឍន៍លម្អិតនៃវិធានការការគ្រប់គ្រងហានិភ័យ (សម្រាប់ការពិនិត្យដោយ ARBC និង អនុញ្ញាត្តិដោយក្រុមព្រឹក្សាភិបាល)។ ផ្នែកធនធានអនុវត្ត និងគ្រប់គ្រងហានិភ័យទីផ្សារប្រចាំថ្ងៃនៅក្នុងសកម្មភាពប្រចាំថ្ងៃ។

(i) ហានិភ័យអត្រាការប្រាក់

ហានិភ័យប្រាក់ដើម ដែលផលប័ត្រពាណិជ្ជកម្មមិនត្រូវបានបង្ហាញ គឺហានិភ័យនៃការបាត់បង់ពីលំហូរសាច់ប្រាក់នាពេលអនាគត ឬតម្លៃ សមរម្យនៃឧបករណ៍ហិរញ្ញវត្ថុ ឬតម្លៃសេដ្ឋកិច្ចនៃទ្រព្យម្ចាស់ហ៊ុនរបស់ធនាគារដោយសារការផ្លាស់ប្តូរអត្រាការប្រាក់ទីផ្សារ។ ហានិភ័យអត្រាការប្រាក់ គឺគ្រប់គ្រងជាគោលដោយតាមដានកម្លៀតអត្រាការប្រាក់ និងដោយកំណត់ថ្នាក់ដាក់តម្លៃឡើងវិញជាមុន។ ធនាគារបានធ្វើការផ្លាស់ផ្តូរអត្រាការប្រាក់ និងមូលនិធិរយៈពេលវែង ដើម្បីគ្រប់គ្រងការប្រឈមនឹងហានិភ័យអត្រាការប្រាក់។ ALMRC គឺជាទ្រង់ទ្រាយត្រួតពិនិត្យស្របតាមការកំណត់ទាំងនេះ និងគាំទ្រដោយផ្នែកធនធាននៅក្នុងការត្រួតពិនិត្យសកម្មភាពប្រចាំថ្ងៃ។ សកម្មភាពប្រចាំថ្ងៃទាំងនេះរួមមាន ការត្រួតពិនិត្យការប្រែប្រួលការប្រឈមនឹងហានិភ័យអត្រាការប្រាក់របស់ធនាគារ ដែលមានការប៉ះពាល់នៃការព្យាករណ៍កាតព្វកិច្ចនៅសល់របស់ធនាគារ។

ARBC និង ALMRC ទទួលខុសត្រូវសម្រាប់ការរៀបបចំផែនការហានិភ័យទាំងមូលរបស់ធនាគារ។ ផ្នែកធនធានទទួលខុសត្រូវសម្រាប់ការអនុវត្តផែនការទាំងនោះដោយដាក់ការរៀបចំហានិភ័យនីមួយៗ។

តារាងខាងក្រោមសង្ខេបអំពីចំហាគម្លាតអត្រាការប្រាក់របស់ធនាគារ។ តារាងគម្លាតកំណត់តម្លៃអត្រា ការប្រាក់ធ្វើការវិភាគទៅលើរចនាសម្ព័ន្ធពេញលេញនៃអត្រាការប្រាក់មិនស៊ីគ្នា រវាងធាតុនៅក្នុងតារាងតុល្យការរបស់ធនាគារផ្អែកលើអាយុកាលកំណត់។

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.៣ ហានិភ័យទីផ្សារ (ត)

២៨.៣.២ ការប្រឈមនឹងហានិភ័យទីផ្សារ

(i) ហានិភ័យអត្រាការប្រាក់(ត)

	រហូតដល់ 1 ខែ	> 1 – 3 ខែ	> 3 – 12 ខែ	> 1 – 5 ឆ្នាំ	លើសពី 5 ឆ្នាំ	មិនមានការប្រាក់	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019							
ទ្រព្យសកម្មហិរញ្ញវត្ថុ							
សាច់ប្រាក់ក្នុងដៃ	-	-	-	-	-	2,844,371	2,844,371
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	8,523,729	-	-	3,000,880	7,520,417	-	19,045,026
សមតុល្យនៅធនាគារនានា	608,585	-	-	-	-	-	608,585
ឥណទានផ្តល់ដល់អតិថិជន	-	-	-	5,536,427	72,208,613	-	77,745,040
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	9,132,314	-	-	8,537,307	79,729,030	2,844,371	100,243,022
បំណុលហិរញ្ញវត្ថុ							
ប្រាក់បញ្ញើរបស់អតិថិជន	4,335,094	1,090,479	19,622,621	873	1,171,029	-	26,220,095
បំណុលភតិសន្យា	26,534	53,424	246,398	928,036	390,395	-	1,644,788
បំណុលផ្សេងៗ	-	-	-	-	-	112,737	112,737
បំណុលហិរញ្ញវត្ថុសរុប	4,361,628	1,143,903	19,869,020	928,909	1,561,424	112,737	27,977,620
គម្លាតអត្រាការប្រាក់ដាក់តម្លៃឡើងវិញសរុប	4,770,686	(1,143,903)	(19,869,020)	7,608,398	78,167,605	2,731,634	72,265,401
សមមូលជាពាន់រៀល	19,440,546	(4,661,405)	(80,966,255)	31,004,224	318,532,991	11,131,409	294,481,509

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.៣ ហានិភ័យទីផ្សារ (ត)

២៨.៣.២ ការប្រឈមនឹងហានិភ័យទីផ្សារ

(i) ហានិភ័យអត្រាការប្រាក់(ត)

	រហូតដល់ 1 ខែ	> 1 – 3 ខែ	> 3 – 12 ខែ	> 1 – 5 ឆ្នាំ	លើសពី 5 ឆ្នាំ	មិនមានការប្រាក់	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018							
ទ្រព្យសកម្មហិរញ្ញវត្ថុ							
សាច់ប្រាក់ក្នុងដៃ	-	-	-	-	-	2,508,273	2,508,273
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	-	6,434,336	100,000	-	7,523,441	236,657	14,294,434
សមតុល្យនៅធនាគារនានា	-	12,370,506	2,938,200	-	602	92,919	15,402,227
ឥណទានផ្តល់ដល់អតិថិជន	-	6,423	3,315,476	2,897,891	37,791,402	-	44,011,194
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	-	18,811,265	6,353,676	2,897,891	45,315,446	2,837,849	76,216,128
បំណុលហិរញ្ញវត្ថុ							
ប្រាក់បញ្ញើរបស់អតិថិជន	1,749,015	255,062	279,673	5,105	146,851	-	2,435,707
បំណុលភតិសន្យា	-	-	-	-	-	-	-
បំណុលផ្សេងៗ	-	-	-	-	-	83,459	83,459
បំណុលហិរញ្ញវត្ថុសរុប	1,749,015	255,062	279,673	5,105	146,851	83,459	2,519,166
កម្លៀតអត្រាការប្រាក់ដាក់តម្លៃឡើងវិញសរុប	(1,749,015)	18,556,203	6,074,004	2,892,786	45,168,594	2,754,390	73,696,961
សមមូលជាពាន់រៀល	(7,027,543)	74,558,823	24,405,347	11,623,213	181,487,412	11,067,139	296,114,391

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.៣ ហានិភ័យទីផ្សារ (ត)

២៨.៣.២ ការប្រឈមនឹងហានិភ័យទីផ្សារ

(i) ហានិភ័យអត្រាការប្រាក់(ត)

	រហូតដល់ 1 ខែ	> 1 – 3 ខែ	> 3 – 12 ខែ	> 1 – 5 ឆ្នាំ	លើសពី 5 ឆ្នាំ	មិនមានការប្រាក់	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017							
ទ្រព្យសកម្មហិរញ្ញវត្ថុ							
សាច់ប្រាក់ក្នុងដៃ	-	-	-	-	-	97,295	97,295
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	32,593,504	-	-	-	-	7,507,970	40,101,474
សមតុល្យនៅធនាគារនានា	125,234	-	-	-	-	-	125,234
ឥណទានផ្តល់ដល់អតិថិជន	-	1,125,221	6,006,352	3,010,182	23,466,328	-	33,608,083
ទ្រព្យសកម្មផ្សេងៗ	-	-	-	-	-	24,127	24,127
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	32,718,738	1,125,221	6,006,352	3,010,182	23,466,328	7,629,392	73,956,213
បំណុលហិរញ្ញវត្ថុ							
បំណុលផ្សេងៗ	-	-	-	-	-	68,307	68,307
បំណុលហិរញ្ញវត្ថុសរុប	-	-	-	-	-	68,307	68,307
គម្លាតអត្រាការប្រាក់ដាក់តម្លៃឡើងវិញសរុប	32,718,738	1,129,460	6,028,981	3,021,523	23,554,736	7,536,958	73,990,396
សមមូលជាពាន់រៀល	132,085,545	4,559,630	24,338,996	12,197,888	95,090,469	30,426,699	298,699,229

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.៣ ហានិភ័យទីផ្សារ (ត)

២៨.៣.២ ការប្រឈមនឹងហានិភ័យទីផ្សារ

(ii) ហានិភ័យលើការប្តូររូបិយប័ណ្ណបរទេស

ធនាគារធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងធ្វើប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗ ហើយត្រូវប្រឈមនឹងហានិភ័យរូបិយប័ណ្ណផ្សេងៗជាពិសេសប្រាក់រៀលខ្មែរ ប្រាក់ដុល្លារអាមេរិក និងប្រាក់ដុល្លារហុងកុង។

ហានិភ័យប្តូររូបិយប័ណ្ណបរទេសកើតឡើងពីប្រតិបត្តិការពាណិជ្ជកម្មនាពេលអនាគត និងទ្រព្យសម្បត្តិ និងបំណុលដែលត្រូវបានទទួលស្គាល់ជារូបិយប័ណ្ណដែលមិនមែនជារូបិយប័ណ្ណមុខងាររបស់សម្ព័ន្ធក្រុមហ៊ុន។

គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 និង ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 សមតុល្យទ្រព្យសកម្ម និងបំណុលដែលជា រូបិយប័ណ្ណផ្សេងៗ ក្រៅពីដុល្លារអាមេរិកគឺមិនគួរឲ្យកត់សម្គាល់ទេ។ ដូច្នេះ មិនមានការវិភាគភាពប្រែប្រួលសម្រាប់ហានិភ័យនៃអត្រាប្តូរប្រាក់បរទេសត្រូវបានបង្ហាញឡើយ។

២៨.៤ ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ

"ហានិភ័យប្រតិបត្តិការ" គឺហានិភ័យនៃការបាត់បង់ផ្សេងៗដោយផ្ទាល់ ឬដោយប្រយោល ដែលកើតចេញពី ដំណើរការផ្ទៃក្នុងរបស់ធនាគារ ធនធានមនុស្ស បច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងកត្តា ហានិភ័យខាងក្រៅផ្សេងៗ ក្រៅពីហានិភ័យឥណទាន ហានិភ័យទីផ្សារ និងហានិភ័យសន្ទនីយភាព មានដូចជាហានិភ័យដែលកើតចេញពីការតម្រូវផ្នែកច្បាប់ និងបទប្បញ្ញត្តិ និងស្តង់ដារសាជីវកម្មដែលទទួលស្គាល់។ ហានិភ័យប្រតិបត្តិការ គឺអាចកើតចេញពី រាល់សកម្មភាពប្រតិបត្តិការទាំងអស់របស់ធនាគារ។

គោលបំណងរបស់ធនាគារក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិការ គឺដើម្បីរក្សាតុល្យភាពពីការបញ្ចៀសការបាត់បង់ហិរញ្ញវត្ថុ និងការខូចខាតកេរ្តិ៍ឈ្មោះរបស់ធនាគា ប្រកបដោយប្រសិទ្ធភាព និង ភាពថ្លៃប្រឹខិត។ រាល់គោលនយោបាយរបស់ធនាគាទាំងអស់ គឺត្រូវអនុលោមទៅតាមការតម្រូវផ្នែកច្បាប់ និងបទប្បញ្ញត្តិ។

ហានិភ័យទទួលខុសត្រូវចំពោះការអភិវឌ្ឍន៍ និងការអនុវត្តនៃការគ្រប់គ្រងដើម្បីកំណត់ហានិភ័យប្រតិបត្តិការ។ ទំនួលខុសត្រូវនេះត្រូវបានគាំទ្រដោយការអភិវឌ្ឍន៍នៃស្តង់ដារធនាគារទាំងមូល សម្រាប់ការគ្រប់គ្រងនៃហានិភ័យប្រតិបត្តិការក្នុងផ្នែកខាងក្រោម៖

- តម្រូវការសម្រាប់ការបែងចែកតួនាទី រួមមានការត្រួតពិនិត្យលើប្រតិបត្តិការដោយឯករាជ្យ
- តម្រូវការសម្រាប់ការសម្របសម្រួល និងតាមដានលើប្រតិបត្តិការ
- ស្របតាមច្បាប់ និងតម្រូវការផ្នែកច្បាប់ផ្សេងៗ
- ការកត់ត្រាលើការគ្រប់គ្រង និងនិតិវិធី
- តម្រូវការសម្រាប់ការវិភាគលើហានិភ័យប្រតិបត្តិការ និងភាពពេញលេញនៃការគ្រប់គ្រង និងនិតិវិធីដើម្បីកំណត់ហានិភ័យប្រតិបត្តិការ
- តម្រូវការសម្រាប់ការរាយការណ៍ការខាតបង់នៃប្រតិបត្តិការ និងស្នើវិធានការកែប្រែ
- ការអភិវឌ្ឍន៍នៃផែនការមិនច្បាស់លាស់
- ការរឹកហាត់ និងការអភិវឌ្ឍន៍វិជ្ជាជីវៈ
- ព័ត៌មានបច្ចេកវិទ្យា និងហានិភ័យអ៊ីនធើណែត និង
- ហានិភ័យកាត់បន្ថយ រួមមានធានារ៉ាប់រងដែលចំណាយមានប្រសិទ្ធភាព។

២៨. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ(ត)

២៨.៥ ហានិភ័យដើមទុន

ហានិភ័យដើមទុន គឺជាហានិភ័យដែលធនាគារមិនមានធនធានដើមទុនគ្រប់គ្រាន់ ដើម្បីបំពេញទៅតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ក្នុងការគាំទ្រចំណាត់ថ្នាក់ឥណទាន និងការរៀបចំផែនការយុទ្ធសាស្ត្ររបស់ធនាគារ។

យុទ្ធសាស្ត្ររបស់ធនាគារ គឺរក្សាឱ្យបានមូលដ្ឋានដើមទុនឱ្យរឹងមាំ ដើម្បីរក្សាទំនុកចិត្តទីផ្សារ និងដើម្បីរក្សា និរន្តរភាពនៃការអភិវឌ្ឍន៍បន្ថែមលើអាជីវកម្ម។ ផលប៉ះពាល់នៃកម្រិតដើមទុនលើប្រាក់ចំណូលរបស់ម្ចាស់ភាគហ៊ុន ត្រូវបានទទួលស្គាល់ ហើយធនាគារត្រូវ រក្សាឱ្យមានតុល្យភាពរវាងប្រាក់ចំណូលខ្ពស់ដែលនឹងអាចធ្វើទៅបាន មានការគ្រប់គ្រង ដើមទុនល្អ និងមានសុវត្ថិភាព ដែលមានជំហរដើមទុនរឹងមាំ។

ធនាគារជាតិនៃកម្ពុជា ដែលជានិយ័តករសំខាន់ជាងគេ បានកំណត់ និងតាមដានការតម្រូវលើដើមទុនសម្រាប់ធនាគារទាំងមូល។

២៨.៥.១ ការគ្រប់គ្រងហានិភ័យដើមទុន

ដូចទៅនឹងហានិភ័យសន្ទនីយភាព និងហានិភ័យទីផ្សារ ARBC និង ALRMC ទទួលខុសត្រូវក្នុងការគ្រប់គ្រង ប្រកបដោយប្រសិទ្ធភាពលើហានិភ័យដើមទុនរបស់សម្ព័ន្ធក្រុមហ៊ុនទាំងមូល។

ហានិភ័យដើមទុនត្រូវបានវាស់វែង និងត្រួតពិនិត្យតាមដាន ដោយយកម្រិតកំណត់ដែលត្រូវបានគណនាស្រប តាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

នៅថ្ងៃទី 22 ខែ កុម្ភៈឆ្នាំ 2018 ធនាគារជាតិនៃកម្ពុជា បានចេញប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុន (Capital Buffer) សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ យោងតាមមាត្រា 22 នៃប្រកាសនេះគ្រឹះស្ថានទាំងអស់ ត្រូវគោរពតាមបទប្បញ្ញត្តិទាក់ទងនឹងការរក្សាទ្រនាប់ដើមទុនយ៉ាងហោចណាស់ឱ្យបាន 50% នៃដើមទុនសរុបគិតត្រឹម ថ្ងៃទី 1 ខែមករា ឆ្នាំ 2019 និងអនុវត្តឱ្យបានយ៉ាងពេញលេញ គិតត្រឹមថ្ងៃទី 1 ខែ មករា ឆ្នាំ 2020។

នៅថ្ងៃទី 7 ខែ មីនា ឆ្នាំ 2018 ធនាគារជាតិនៃកម្ពុជា បានចេញសារាចរណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុនសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលបានកំណត់អនុបាតនៃទ្រនាប់ដើមទុនខានធើស៊ីឃ្លីខល (Countercyclical Capital Buffer) ចំនួន 0% រហូតដល់មានការជូនដំណឹងជាថ្មី។

ធនាគារបានអនុលោមទៅតាមការតម្រូវដើមទុនដែលត្រូវបានកំណត់យ៉ាងពេញលេញក្នុងឆ្នាំ។.

២៩. រយៈពេលខ្លី និងរយៈពេលវែង

គណៈគ្រប់គ្រងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុផ្អែកលើសន្ទនីយភាព។ ព័ត៌មានអំពីរយៈពេលខ្លី ឬវែង របស់ ទ្រព្យសកម្ម និងបំណុលត្រូវបាន បង្ហាញនៅក្នុងផ្នែកនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ។ ទ្រព្យសម្បត្តិ និងបរិក្ខារ សិទ្ធក្នុងការប្រើទ្រព្យសកម្ម ទ្រព្យសកម្មអរូបី និងពន្ធពន្យារជាទ្រព្យសកម្ម ជាទ្រព្យសកម្មរយៈពេលវែង។ សំវិធានធនជាបំណុលរយៈពេលវែង។

៣០. ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទរបាយការណ៍

នៅថ្ងៃទី 30 ខែ មករា ឆ្នាំ 2020 អង្គការសុខភាពពិភពលោក(WHO)ប្រកាសភាពអាសន្នចំពោះសុខភាពទូទាំងពិភពលោក ដោយ ការរាលដាលនៃវីរុស COVID-19។ ចាប់តាំងពីថ្ងៃទី 11 ខែ មីនា ឆ្នាំ 2020 WHO បានកំណត់ការរាលដាលCOVID-19 នេះជាជំងឺរាតត្បាតជាសកល។ ផលប៉ះពាល់ហិរញ្ញវត្ថុនៃវីរុស COVID-19 ទៅលើស្ថានភាពធនាគារ និងសកម្មភាពធនាគារនាថ្ងៃអនាគត និងលទ្ធផលមិនអាចធ្វើការប៉ាន់ស្មានជាក់លាក់បានទេ ដោយសារវាផ្អែកយ៉ាងខ្លាំងលើការអភិវឌ្ឍន៍នៅថ្ងៃអនាគត។

មិនមានហេតុការណ៍ណាជាសារវន្តដែលកើតឡើងក្រោយការិយបរិច្ឆេទរបាយការណ៍ ដែលត្រូវឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬតម្រូវឲ្យកត់ត្រា ឬបង្ហាញនៅពេលនេះទេ។

ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក
CHIEF BANK

www.chiefbank.com.kh 023 900 878